ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ម៉ូឌុលទី ២ ស្វ័យប្រសិទ្ធភាព



## កម្មវិធីសិក្សា Gap Inc. P.A.C.E.
សម្រាប់សិស្សពេញវ័យ (អាយុ១៤ ដល់ ១៧ឆ្នាំ)

P.A.C.E.
Gap Inc.

គាំទ្រដោយក្រុមហ៊ុន Gap Inc.
រៀបចំដោយ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

# កម្មវិធីសិក្សា Gap Inc. P.A.C.E.

# ការដាក់ទុនលើជំនាញថ្មីដើម្បីអនាគត

Personal Advancement and Career Enhancement

## កម្មវិធីសម្រាប់ក្មេងស្រីពេញវ័យ

## (អាយុ១៤ ដល់ ១៧ឆ្នាំ)

ស្បៀវភៅណែនាំសម្រាប់គ្រូបង្រៀន

# មាតិកា


សេចក្តីណែនាំស្តីពីការប្រើប្រាស់សៀវភៅ ........ i

ម៉ូឌុលទី២ ៖ ស្វ័យប្រសិទ្ធភាព ........ 1

ជំពូកទី១ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ........ 2

មេរៀនទី១ ៖ ការប្រាស្រ័យទាក់ទងដោយពាក្យសម្តី ........ 4

មេរៀនទី២ ៖ ការប្រាស្រ័យទាក់ទងដោយប្រើកាយវិការ ........ 18

មេរៀនទី៣ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង ........ 27

ជំពូកទី២ ៖ ទំនាក់ទំនងល្អ ........ 38

មេរៀនទី៤ ៖ តើនរណាជាអ្នកមានអំណាច ? ........ 39

ជំពូកទី៣ ៖ ការយល់ដឹងពីអំពើហិង្សា ........ 46

មេរៀនទី៥ ៖ តើអំពើហិង្សាជាអ្វី ? ........ 48

មេរៀនទី៦ ៖ តើវាពិតដែរឬទេ ? ........ 59

មេរៀនទី៧ ៖ ការផ្លាស់ប្តូរដែលយើងចង់ឃើញ ........ 69

ឧបសម្ព័ន្ធទី១ ៖ សន្លឹកកិច្ចការសិស្ស ........ 74

ឧបសម្ព័ន្ធទី២ ៖ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន ........ 87

# សេចក្ដីណែនាំស្ដីពីការប្រើប្រាស់សៀវភៅ

## ១. សេចក្ដីផ្ដើម

សៀវភៅម៉ូឌុលទី២សម្រាប់ក្មេងស្រីពេញវ័យ(អាយុពី១៤-១៧ឆ្នាំ)មានគោលបំណងជួយសិស្សក្នុងការសិក្សាពីរបៀបដែលយេនឌ័រអាចកំណត់ពីការប្រាស្រ័យទាក់ទង និងរបៀបដែលគេបង្កើតបំណិនទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងកាន់តែរឹងមាំ។ សិស្សក៏សិក្សាផងដែរពីអំណាច និងទំនាក់ទំនង និងការយល់ដឹងពីអំពើហិង្សា។ ម៉ូឌុលនេះមាន៣ជំពូកគឺ ៖ ១) ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធិភាព ២) ទំនាក់ទំនងល្អ និង ៣) ការយល់ដឹងពីអំពើហិង្សា ដោយជំពូកនីមួយៗមានមេរៀនដាច់ៗដោយឡែកពីគ្នាចំនួន៧មេរៀន។ ជំពូកនីមួយៗមានកំណត់ពីលទ្ធផលសិក្សាដែលរំពឹងទុកសម្រាប់សិស្សរៀងៗខ្លួន។

ជំពូកស្ដីពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជួយក្មេងស្រីឱ្យកសាងបំណិនប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមូលដ្ឋាន។ ជំពូកស្ដីពីការទំនាក់ទំនងល្អជួយសិស្សឱ្យយល់ពីរបៀបដែលយេនឌ័រ និងអំណាចមានឥទ្ធិពលលើការប្រាស្រ័យទាក់ទងរវាងបុគ្គលនានា។ ចំពោះជំពូកស្ដីពីការយល់ដឹងពីអំពើហិង្សាជួយក្មេងស្រីឱ្យយល់ដឹងកាន់តែទូលំទូលាយថែមទៀតពីអំពើហិង្សា និងទម្រង់ខុសៗគ្នានៃអំពើហិង្សា កំណត់ពីអំពើហិង្សានៅជុំវិញខ្លួនរបស់គេ និងឱ្យពួកគេមានលទ្ធភាពប្រមើលមើលការផ្លាស់ប្ដូរដែលអាចមាននៅក្នុងរចនាសម្ព័ន្ធមូលដ្ឋានរបស់សង្គមបច្ចុប្បន្ន។

## ២. វត្ថុបំណងរបស់ម៉ូឌុល

នៅចុងបញ្ចប់នៃម៉ូឌុលនេះសិស្ស ៖

- មានលទ្ធភាពប្រាស្រ័យទាក់ទងពីបំណងប្រាថ្នាផ្សេងៗឱ្យមានប្រសិទ្ធភាព។
- មានលទ្ធភាពបង្ហាញពីភាពម៉ឺងម៉ាត់ និងធ្វើការសម្រេចចិត្ត និងជ្រើសរើសជម្រើសរបស់ខ្លួនដោយឯករាជ្យ។
- យល់ពីផលជះរបស់អំណាចនៅក្នុងទំនាក់ទំនងរបស់ខ្លួន។
- យល់ពីអ្វីដែលរួមចំណែកដល់ទំនាក់ទំនងល្អមួយ។

- អាចកំណត់ពីទម្រង់ខុសៗគ្នានៃអំពើហិង្សា និងដែលបង្កឱ្យមានអំពើហិង្សា។

## ៣. សេចក្ដីពន្យល់ពីការប្រើប្រាស់ម៉ូឌុល

សៀវភៅនេះគឺជាសៀវភៅសម្រាប់គ្រូដែលបានរៀបចំរួចជាស្រេចនូវផែនការ ឬលំនាំនៃការបង្រៀនសម្រាប់ជំនួយដល់គ្រូក្នុងការបង្រៀនសិស្ស។ វាចែកចេញជា៦ផ្នែកធំៗតាមលំដាប់លំដោយពោលគឺ ១) ផ្នែក ២) ម៉ូឌុល ៣) ជំពូក ៤) មេរៀន ៥) ឧបសម្ព័ន្ធទី១ សន្លឹកកិច្ចការសិស្ស និង ៦) ឧបសម្ព័ន្ធទី២ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន។ នៅក្នុងម៉ូឌុលមាន បែកចែកជាជំពូកធំៗចំនួន៣ ហើយនៅក្នុងជំពូកនីមួយៗមានចំនួនមេរៀនជាក់លាក់ទៅតាមភាពចាំបាច់របស់ជំពូក។

**ផ្នែកនៃម៉ូឌុល** ផ្ដល់នូវការណែនាំទូទៅទាក់ទងនឹងខ្លឹមសារទាំងមូលនៃប្រធានបទ ជំពូក និងមេរៀន។ ដូច្នេះនៅក្នុងផ្នែកនេះ បានដាក់បញ្ចូលនូវៈ ទិដ្ឋភាពទូទៅនៃម៉ូឌុល រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងរបស់ម៉ូឌុលដើម្បីឱ្យគ្រូបង្រៀនយល់ដឹងបានទូលំទូលាយពីខ្លឹមសារទូទៅរបស់ប្រធានបទទាំងមូល។

**ផ្នែកនៃជំពូក** ផ្ដល់នូវការណែនាំជាក់លាក់សម្រាប់ប្រធានបទរួមរបស់មេរៀនទាំងមូលនៅក្នុងជំពូកនីមួយៗ។ ដូចគ្នានឹងផ្នែកម៉ូឌុលដែរ បានដាក់បញ្ចូលនូវៈ ទិដ្ឋភាពទូទៅ រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងដាច់ដោយឡែកសម្រាប់ជំពូកនីមួយៗដើម្បីឱ្យគ្រូបង្រៀនយល់ដឹងពីខ្លឹមសារទូទៅរបស់ជំពូកនីមួយៗ។

**ផ្នែកនៃមេរៀន** ផ្ដល់នូវព័ត៌មានលម្អិតសម្រាប់ការងាររៀបចំជាមុនរបស់គ្រូបង្រៀន។ នៅក្នុងមេរៀននីមួយៗមានកំណត់ និងរៀបចំទៅតាមលំដាប់លំដោយនូវៈ វត្ថុបំណង រយៈពេល សារសំខាន់ៗ សម្ភារៈដែលត្រូវការ សេចក្ដីណែនាំ និងចំណុចសម្រាប់ការពិភាក្សា។ នៅខាងដើមនៃសកម្មភាពនីមួយៗក៏បានបញ្ចូលនូវ«គន្លឹះសម្រាប់គ្រូបង្រៀន»ដើម្បីជាជំនួយដល់គ្រូបង្រៀនផងដែរ។

**ផ្នែកឧបសម្ព័ន្ធទី១** សន្លឹកកិច្ចការសិស្សមានបញ្ជាក់ច្បាស់លាស់ពីកិច្ចការសម្រាប់សិស្សដែលត្រូវបំពេញនៅក្នុងថ្នាក់ និងកិច្ចការផ្ទះផងដែរ។

**ផ្នែកឧបសម្ព័ន្ធទី២** ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀនគឺជាទម្រង់ស្ទង់ដារដែលសិស្សត្រូវបំពេញមុនពេលរៀន និងក្រោយពេលបញ្ចប់ម៉ូឌុល ដើម្បីឱ្យគ្រូងាយស្រួលក្នុងការពិនិត្យមើលលទ្ធផលសិក្សារបស់សិស្សក្រោយពេលបញ្ចប់ម៉ូឌុលនេះ។

- **ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស**

មានព័ត៌មានទាក់ទងនឹងរបៀបចាប់ផ្ដើមបង្រៀនសិស្ស ឬផ្នែកដែលទាក់ទងនឹងសកម្មភាពនៃការបង្រៀន និងរៀន។ វាក៏ផ្ដល់នូវការណែនាំពីការរៀបចំសម្ភារៈ និងឯកសារដែលគ្រូបង្រៀនត្រូវការសម្រាប់ការបង្រៀន និងរៀន។

- **សម្ភារឧបទ្ទេស**

ផ្នែកនេះផ្ដល់នូវសេចក្ដីសង្ខេបពីសម្ភារឧបទ្ទេស ដែលភាគច្រើនជាសម្ភារៈមូលដ្ឋានដូចជា ក្ដារខៀន ដីស ឬហ្វឺត ស្កុត កន្ត្រៃ ប៊ិក សៀវភៅ ក្រដាសទំហំផ្សេងៗគ្នា ក្រដាសព័ត៌មាន ឬឯកសារផ្សេងៗជាដើម។ សម្ភារៈ ឯកសារផ្សេងៗទៀតនៅក្នុងសៀវភៅនេះក៏ត្រូវផ្ដល់ឱ្យសិស្សសម្រាប់អនុវត្តដៃតាមរយៈសន្លឹកកិច្ចការសម្រាប់សិស្សដែលមានភ្ជាប់នៅក្នុងសៀវភៅនេះ។

- **វត្ថុបំណង**

ផ្ដល់នូវឃ្លា ឬប្រយោគជាក់លាក់មួយចំនួនពីអ្វីដែលត្រូវសម្រេចឱ្យបាន។ សម្រាប់ចំណុចនេះ វត្ថុបំណងចែកចេញជា៣ផ្នែកធំៗដូចរៀបរាប់ខាងលើ ពោលគឺ ៖ ១) វត្ថុបំណងទូទៅដែលមានកំណត់នៅក្នុងផ្នែកនៃម៉ូឌុល ២) វត្ថុបំណងដែលមានលក្ខណៈជាក់លាក់ដែលមានកំណត់នៅក្នុងផ្នែកនៃជំពូក និង ៣) វត្ថុបំណងជាក់លាក់សម្រាប់មេរៀននីមួយៗ។

- **ជំហាន និងលំនាំនៃការបង្រៀន និងរៀន**

នេះជាផ្នែកមេរៀនពិតប្រាកដ។ នៅក្នុងផ្នែកនេះមានផ្ដល់ព័ត៌មានទាក់ទងនឹងរយៈពេលបង្រៀន និងរៀន វត្ថុបំណង សារសំខាន់ៗ សម្ភារៈដែលត្រូវការ សេចក្ដីណែនាំនិងគន្លឹះសម្រាប់គ្រូបង្រៀន ដែលជាផ្នែកដ៏សំខាន់សម្រាប់គ្រូបង្រៀនក្នុងការធ្វើសកម្មភាពក្នុងពេលបង្រៀន និងរៀន។ នៅក្នុងផ្នែកនៃ«សេចក្ដីណែនាំ»មានបញ្ជាក់នូវសកម្មភាពដែលគ្រូបង្រៀនត្រូវធ្វើសំណួរបំផុសគំនិត ឧទាហរណ៍ និងព័ត៌មានផ្សេងៗទៀត។ ដូចដែលបានបញ្ជាក់ពីខាងលើ «គន្លឹះសម្រាប់គ្រូបង្រៀន»ដែលមាននៅក្នុងមេរៀននីមួយៗ ក៏ផ្ដល់នូវការណែនាំបន្ថែមសម្រាប់ដំណើរការបង្រៀន និងរៀន និងខ្លឹមសារផ្សេងៗដែលគ្រូបង្រៀនអាចណែនាំ និងពន្យល់សិស្សបន្ថែមទៀតទៅលើខ្លឹមសារមេរៀន។

- **ការប្រើប្រាស់និមិត្តសញ្ញា**

និមិត្តសញ្ញាមួយចំនួនត្រូវបានគេដាក់បញ្ចូលនៅក្នុងសៀវភៅនេះដើម្បីឱ្យគ្រូបង្រៀនមានការចាប់អារម្មណ៍ និងងាយស្រួលយល់ និងប្រើប្រាស់។ និមិត្តសញ្ញាទាំងនោះរួមមាន ៖

- **វត្ថុបំណងម៉ូឌុល ឬជំពូក** ៖ ចំណេះដឹងក្រោយរបស់សិស្សដែលទទួលបាននៅក្នុងម៉ូឌុលទាំងមូល និងជំពូកនីមួយៗ។
  ☺ ចំណេះដឹងលម្អិតនីមួយៗដែលសិស្សទទួលបាន។
- **ចំនួនលំនាំបង្រៀន** ៖ ចំនួនលំនាំបង្រៀនសរុបសម្រាប់ជំពូកនីមួយៗ។
- **រយៈពេល** ៖ ចំនួនម៉ោងសម្រាប់មេរៀននីមួយៗ។
- **វត្ថុបំណងមេរៀន** ៖ លទ្ធផលសិក្សាដែលសិស្សសម្រេចបានក្រោយពីបញ្ចប់មេរៀននីមួយៗ។
- **សារសំខាន់ៗ** ៖ ខ្លឹមសារសង្ខេបរបស់មេរៀននីមួយៗដែលគ្រូបង្រៀនត្រូវបញ្ជាក់ប្រាប់សិស្ស។
  ខ្លឹមសារសង្ខេបនីមួយៗ។
- **សម្ភារៈដែលត្រូវការ** ៖ មានសរសេរនៅក្នុងមេរៀននីមួយៗដែលតម្រូវឱ្យគ្រូបង្រៀនរៀបចំទុកជាមុន។
- **សេចក្ដីណែនាំ** ៖ ចំណុចនានាដែលគ្រូបង្រៀនត្រូវអនុវត្តជាទូទៅក្នុងពេលបង្រៀន និងរៀន។
  ☞ ចំណុចនីមួយៗដែលគ្រូបង្រៀនត្រូវធ្វើ។
- **ចំណុចសម្រាប់ការពិភាក្សា** ៖ បញ្ជាក់ពីចំណុចសម្រាប់ការពិភាក្សាក្រុមតូច ឬក្រុមធំ។
  សំណួរបំផុសគំនិត ឬពិភាក្សាក្នុងពេលបង្រៀន និងរៀន
  ចម្លើយសម្រាប់សំណួរនីមួយៗ ឬការពន្យល់ទូទៅ។
- **គន្លឹះសម្រាប់គ្រូបង្រៀន** ៖ ចំណុចបន្ថែមដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្ត ឬពន្យល់បន្ថែមក្នុងពេលបង្រៀន និងរៀន។
  ចំណុចនីមួយៗដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្ត ឬពន្យល់បន្ថែម។
- **កិច្ចការផ្ទះ** ៖ កិច្ចការដែលគ្រូបង្រៀនដាក់ឱ្យសិស្សបំពេញនៅផ្ទះ។
- **កិច្ចការក្នុងថ្នាក់** ៖ កិច្ចការដែលគ្រូបង្រៀនដាក់ឱ្យសិស្សបំពេញនៅក្នុងថ្នាក់។

## ៤. សន្លឹកកិច្ចការសិស្ស

នៅខាងក្រោយនៃសៀវភៅនេះមានដាក់បញ្ចូលនូវសន្លឹកកិច្ចការសិស្ស*(ឧបសម្ព័ន្ធទី១)*។ មេរៀនមួយចំនួនក្នុងចំណោមមេរៀនទាំងនេះមានឯកសារ និងលំហាត់សម្រាប់សិស្ស។ តាមការដាក់ស្តែងគ្រូអាចថតចម្លងលំហាត់ ឬអាចរៀបចំសន្លឹកកិច្ចការសិស្សនីមួយៗសម្រាប់ចែកជូនដល់សិស្ស។ តាមការអនុវត្តជាក់ស្តែង និងលក្ខណៈពិសេសរបស់ម៉ូឌុល សន្លឹកកិច្ចការសិស្សគប្បីដាក់បញ្ចូលគ្នាទាំង៤ម៉ូឌុលដើម្បីឱ្យសិស្សអាចមើលឡើងវិញបាននៅពេលដែលត្រូវការ ព្រោះថាម៉ូឌុលទាំង៤ពាក់ព័ន្ធនឹងការប្រតិបត្តិល្អច្រើនក្នុងជីវិតប្រចាំថ្ងៃ។

## ៥. ខ្លឹមសារសង្ខេបរបស់ម៉ូឌុល

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបរបស់មេរៀនទាំង៧ដែលមាននៅក្នុងម៉ូឌុលនេះ ៖

| ចំណងជើងមេរៀន | រយៈពេល | សេចក្តីសង្ខេប |
|---|---|---|
| **ជំពូកទី១ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព** | | |
| ១. ការប្រាស្រ័យទាក់ទងដោយពាក្យសម្តី | ៤៥នាទី | - សិស្សសិក្សាពីសារៈសំខាន់នៃការប្រើប្រាស់ប្រយោគច្បាស់លាស់ និងខ្លីៗ និងការស្តាប់ប្រកបដោយប្រសិទ្ធភាពដែលជាចំណុចសំខាន់នៃការប្រាស្រ័យទាក់ទងដោយពាក្យសម្តីប្រកបដោយប្រសិទ្ធភាព។ |
| ២. ការប្រាស្រ័យទាក់ទងដោយប្រើកាយវិការ | ៤៥នាទី | - សិស្សយល់កាន់តែទូលំទូលាយពីការប្រាស្រ័យទាក់ទងដោយកាយវិការថាជាផ្នែកដ៏សំខាន់មួយនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងដើម្បីសិក្សាថាតើភាសាកាយវិការអាចបំពេញបន្ថែមទៅលើសមត្ថភាពរបស់នរណាម្នាក់ក្នុងការប្រាស្រ័យទាក់ទងល្អកម្រិតណា។ |
| ៣. យេនឌ័រ និងការប្រាស្រ័យទាក់ទង | ៤៥នាទី | - សិស្សយល់ពីរបៀបដែលការកំណត់ពីយេនឌ័រ និងអំណាចមានឥទ្ធិពលលើបំណិននៃការប្រាស្រ័យទាក់ទង។ |
| **ជំពូកទី២ ៖ ទំនាក់ទំនងល្អ** | | |
| ៤. តើនរណាជាអ្នកមានអំ ណាច? | ៤៥នាទី | - សិស្សយល់ដឹងពីរបៀបដែលអំណាចដំណើរការនៅក្នុងទំនាក់ទំនងនានា និងដើម្បីមានលទ្ធភាពកំណត់ពីអ្វីដែលរួមចំណែកដល់ទំនាក់ទំនងល្អ និងមិនល្អ។ |

| ជំពូកទី៣ ៖ ការយល់ដឹងពីអំពើហិង្សា | | |
|---|---|---|
| ៥. តើអំពើហិង្សាជាអ្វី? | ៤៥នាទី | - សិស្សកំណត់ និងយល់ពីទម្រង់ខុសៗគ្នានៃអំពើហិង្សាដែលគេជួបប្រទះ និងកត្តាទូទៅដែលស្ថិតនៅពីក្រោយអំពើហិង្សា។ |
| ៦. តើវាពិតដែរឬទេ? | ៤៥នាទី | ○ សិស្សរៀនពីរបៀបដែលអំពើហិង្សាលើស្ត្រីកើតឡើងនៅគ្រប់វណ្ណៈ ត្រកូល សាសនា និងវប្បធម៌។<br>○ សិស្សអាចកំណត់ពីជំនឿមិនត្រឹមត្រូវជុំវិញអំពើហិង្សាទៅលើស្ត្រី។ |
| ៧. ការផ្លាស់ប្តូរដែលយើងចង់ឃើញ | ៤៥នាទី | - សិស្សមានលទ្ធភាពមើលឃើញពីយេនឌ័រ យុត្តិធម៌សង្គម និងសមភាពសង្គម។ |

## ៦. ការវាយតម្លៃសិស្ស

នៅខាងចុងនៃសៀវភៅនេះមានដាក់បញ្ចូលនូវទម្រង់នៃការវាយតម្លៃសិស្ស*(ឧបសម្ព័ន្ធទី២)* ដែលទម្រង់នេះត្រូវបានរៀបចំឡើងសម្រាប់វាស់វែងចំណេះដឹងរបស់សិស្ស។ ការវាយតម្លៃនេះត្រូវធ្វើជាពីរដំណាក់កាល ពោលគឺ ការវាយតម្លៃមុនពេលបង្រៀន *(Pre-test)* និងក្រោយពេលបង្រៀន *(Post-test)* ដើម្បីពិនិត្យមើលលើការរីកចម្រើនផ្នែកចំណេះដឹងរបស់សិស្ស។

## ៧. ឯកសារយោង

នៅក្នុងមេរៀននីមួយៗមានបញ្ចូលនូវឯកសារយោង ឬបន្ថែមសម្រាប់ការអានរបស់សិស្ស និងការពន្យល់បន្ថែមរបស់គ្រូ។ ឯកសារទាំងនេះមានចំនួន២ប្រភេទគឺ «ឧបសម្ព័ន្ធ និងក្របខណ្ឌចំណេះដឹង»។ វាមានសារៈសំខាន់ណាស់ដែលគ្រូបង្រៀនត្រូវអានចំណុចទាំងនេះជាមុន ព្រោះវាផ្តល់នូវការពន្យល់ទូទៅនូវចំណេះដឹងមួយចំនួន។

# ម៉ូឌុលទី២ ៖ ស្វ័យប្រសិទ្ធភាព

**ទិដ្ឋភាពទូទៅ**

ម៉ូឌុលទី២របស់កម្មវិធីសិក្សា Gap Inc. P.A.C.E. សម្រាប់ក្មេងស្រីពេញវ័យផ្តោតការយកចិត្តទុកដាក់លើការជួយពួកគេក្នុងការសិក្សាពីរបៀបដែលយេនឌ័រអាចកំណត់ពីការប្រាស្រ័យទាក់ទង និងរបៀបដែលគេអាចបង្កើតបំណិនទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងកាន់តែរឹងមាំ។ សិស្សនឹងសិក្សាពីជំពូកស្តីពីអំណាច និងទំនាក់ទំនង ព្រមជាមួយនឹងការយល់ដឹងពីអំពើហិង្សា។ មេរៀននានានឹងជួយពួកគេឱ្យយល់ដឹងកាន់តែទូលំទូលាយ និងសិក្សាពីអន្តរកម្មនៃអំណាចក្នុងការប្រាស្រ័យទាក់ទងប្រចាំថ្ងៃរបស់ខ្លួន របៀបសម្គាល់អំពើហិង្សា និងកត្តាដែលបង្កឱ្យមានអំពើហិង្សាទាំងនោះក្នុងបរិបទរបស់ពួកគេ ព្រមទាំងរបៀបលើកកម្ពស់ការយល់ដឹងឱ្យកាន់តែទូលំទូលាយពីប្រធានបទនេះនៅក្នុងលក្ខណៈមួយដែលធ្វើឱ្យពួកគេកាន់តែមានភាពជឿជាក់ និងជំនឿចិត្តលើខ្លួនឯងក្នុងការដោះស្រាយបញ្ហានេះ។

**រយៈពេលរួមម៉ូឌុល** ៖ ៥ ម៉ោង ១៥នាទី

**ចំនួនលំនាំបង្រៀនសរុប** ៖ ៧មេរៀន

| **វត្ថុបំណង៖** |
|---|
| ១. ដើម្បីមានលទ្ធភាពប្រាស្រ័យទាក់ទងពីបំណងប្រាថ្នាផ្សេងៗឱ្យមានប្រសិទ្ធភាព។ |
| ២. ដើម្បីមានលទ្ធភាពបង្ហាញពីភាពម៉ឺងម៉ាត់ និងធ្វើការសម្រេចចិត្ត និងជ្រើសរើសជម្រើសរបស់ខ្លួនដោយឯករាជ្យ។ |
| ៣. ដើម្បីយល់ពីផលជះរបស់អំណាចនៅក្នុងទំនាក់ទំនងរបស់ខ្លួន។ |
| ៤. ដើម្បីយល់ពីអ្វីដែលរួមចំណែកដល់ទំនាក់ទំនងល្អមួយ។ |
| ៥. ដើម្បីសិក្សា និងអាចកំណត់ពីទម្រង់ខុសៗគ្នានៃអំពើហិង្សា និងដែលបង្កឱ្យមានអំពើហិង្សា។ |

# ជំពូកទី ១ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព



## ទិដ្ឋភាពទូទៅ

នៅពេលយើងពិចារណាលើពាក្យថា «ការប្រាស្រ័យទាក់ទង» ជារឿយៗ យើងគិតថា ពាក្យនេះគឺជាសកម្មភាពនៃការនិយាយដើម្បីនាំសារមួយទៅកាន់មនុស្សម្នាក់ ឬច្រើននាក់។ ប៉ុន្តែ ការប្រាស្រ័យទាក់ទងគឺមានលក្ខណៈស៊ីជម្រៅជាងនេះទៅទៀត។ ការប្រាស្រ័យទាក់ទងគឺជាការផ្លាស់ប្តូរគ្នានូវទស្សនៈ គំនិត ឬអារម្មណ៍ ហើយគេអាចបង្ហាញតាមរបៀបជាច្រើន (ពោលគឺ ជាពាក្យសម្តីតាមរយៈភាសា ឬជាសញ្ញាតាមរយៈភាសាកាយវិការ ឬជាអត្ថបទ)។

ការប្រាស្រ័យទាក់ទងបង្កើតឱ្យមានមូលដ្ឋានសម្រាប់រាល់អន្តរកម្មរបស់យើង ហើយវាជាបំណិនដ៏សំខាន់បំផុតមួយដែលកំណត់ពីរបៀបដែលយើងបង្ហាញពីខ្លួនរបស់យើង ទស្សនៈ អារម្មណ៍ តម្រូវការ និងបំណងប្រាថ្នារបស់យើងទៅកាន់ពិភពលោកខាងក្រៅ។ វាក៏បង្កើតមូលដ្ឋានសម្រាប់ដោះស្រាយបញ្ហា និងការចរចាប្រកបដោយប្រសិទ្ធភាពដែរ។ របៀបដែលយើងជ្រើសរើស ឬរបៀបដែលគេបង្រៀនយើងក្នុងការប្រាស្រ័យទាក់ទងជាញឹកញាប់ ត្រូវបានកំណត់ដោយសង្គមូបនីយកម្មរបស់យើង បទដ្ឋានទូទៅផ្នែកយេនឌ័រ ព្រមទាំងបរិបទផ្នែកវប្បធម៌ និងសង្គមនីមួយៗរបស់យើង។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលយេនឌ័រកំណត់ពីការប្រាស្រ័យទាក់ទង យើងអាចអភិវឌ្ឍបំណិនឱ្យកាន់តែរឹងមាំដើម្បីឱ្យមានប្រសិទ្ធភាពថែមទៀតនៅក្នុងមធ្យោបាយ ដែលយើងប្រាស្រ័យទាក់ទង។

ជំពូកទី១ស្តីពី «ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព» នៅក្នុងម៉ូឌុលទី២ ៖ ស្វ័យប្រសិទ្ធភាពនេះនឹងផ្តោតការយកចិត្តទុកដាក់លើការជួយក្មេងស្រីវ័យជំទង់ឱ្យកសាងបំណិនប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមូលដ្ឋានដែលរួមមានទាំងការសិក្សារៀនសូត្រពី ៖

- មូលហេតុដែលការប្រាស្រ័យទាក់ទងមានសារៈសំខាន់នៅក្នុងជីវិតរបស់យើង។
- របៀបដែលការប្រាស្រ័យទាក់ទងជាញឹកញាប់រងឥទ្ធិពលពីកត្តាសង្គម។
- របៀបដែលអំណាច និងយេនឌ័រដើរតួនាទីមួយក្នុងរបៀបដែលយើងប្រាស្រ័យទាក់ទង។

🕘 **រយៈពេលរួមជំពូក ៖ ២ ម៉ោង ២៥ នាទី**

🗍 **ចំនួនលំនាំបង្រៀនសរុប ៖ ៣មេរៀន**

| 🏆 **វត្ថុបំណង៖** |
|---|
| ១. ដើម្បីទទួលបានការយល់ដឹងមួយពីការរួមចំណែក និងធាតុផ្សំនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ |
| ២. ដើម្បីអាចយល់ដឹងពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ |
| ៣. ដើម្បីរៀនពីរបៀបដែលការបង្កើតយេនឌ័រ និងអំណាច ពេលខ្លះអាចមានឥទ្ធិពល និងរាំងស្ទះជំនាញប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ព្រមទាំងរបៀបដែលមនុស្សម្នាក់អាចជម្នះឧបសគ្គទាំងនោះបាន។ |
| ៤. ដើម្បីអាចបង្ហាញឱ្យបានច្បាស់ពីតម្រូវការ និងបំណងប្រាថ្នារបស់ពួកគេចំពោះគ្រួសារ និងសហគមន៍របស់គេក្នុងលក្ខណៈមួយច្បាស់លាស់ ប្រកបដោយភាពជឿជាក់ និងដោយសង្ខេប។ |

# មេរៀនទី១ ៖ ការប្រាស្រ័យទាក់ទងដោយពាក្យសម្ដី

➲ **វត្ថុបំណង ៖** ដើម្បីសិក្សាពីសារៈសំខាន់នៃការប្រើប្រាស់ប្រយោគច្បាស់លាស់ និងខ្លីៗ និងការស្ដាប់ប្រកបដោយប្រសិទ្ធភាពដែលជាចំណុចសំខាន់នៃការប្រាស្រ័យទាក់ទងដោយពាក្យសម្ដីប្រកបដោយប្រសិទ្ធភាព។

🕘 **រយៈពេលមេរៀន ៖** ៤៥ នាទី

✉ **សារសំខាន់ៗ ៖**

១. ការប្រាស្រ័យទាក់ទងល្អមានភាពចាំបាច់ និងសារៈសំខាន់សម្រាប់អត្តសញ្ញាណលទ្ធភាពស្វែងរកការងារធ្វើ និងភាពជោគជ័យរបស់ប្អូនៗនៅក្នុងជីវិត។ ការប្រាស្រ័យទាក់ទងគឺជាឧបករណ៍សំខាន់មួយសម្រាប់ការចរចា និងការដោះស្រាយបញ្ហា។

២. ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពទទួលបានជោគជ័យ នៅពេលដែលអ្នកទទួលទទួលបាន និងយល់ពីសារដែលអ្នកផ្ញើបានផ្ញើទៅឱ្យ។

៣. ការប្រាស្រ័យទាក់ទងមិនត្រឹមតែជាការនិយាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការស្ដាប់ដែរ។ វាជាការផ្លាស់ប្ដូរគំនិតគ្នា។

៤. ការបង្ហាញច្បាស់ៗ និងខ្លីៗមានន័យគ្រប់គ្រាន់នៅពេលប្រាស្រ័យទាក់ទងដោយពាក្យសម្ដីគឺជាបំណិនជីវិតដ៏សំខាន់មួយដែលគេចាំបាច់ត្រូវតែហាត់រៀន។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាស A4 ៣សន្លឹក ម៉ាស៊ីនថតចម្លង ក្ដារខៀន ហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះពណ៌ខ្មៅ១ដើម និងកន្ត្រៃ។

☞ សម្រាប់សិស្ស ៖ ក្រដាស A4 ១សន្លឹក និងសម្ភារៈសរសេរ *(សម្រាប់សិស្សមួយគូៗ)*។

**ការរៀបចំទុកជាមុន ៖**

☞ អានទិដ្ឋភាពទូទៅនៅក្នុងម៉ូឌុល២ ៖ ស្វ័យប្រសិទ្ធភាព ជំពូកទី១ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និង ឯកសារអំណានទី១ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

- ☞ សរសេរសារនៅលើក្រដាសតូចមួយ (សូមមើល ឯកសារអំណានទី២ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ បង្កើតបណ្ណរូបភាព (សូមមើលឯកសារអំណានទី៣នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ គូរដ្យាក្រាមស្តីពី «អ្នកបញ្ជូន និងអ្នកទទួលសារទទួលបានព័ត៌មានត្រលប់» នៅលើក្តារខៀន (សូមមើល ឯកសារអំណានទី៤ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ ប្រមូលសម្ភារៈដែលត្រូវការទាំងអស់ផ្សេងៗទៀត។
- ☞ សរសេរចំណងជើងមេរៀនដាក់នៅលើក្តារខៀន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សឱ្យចុះវត្តមាន នៅពេលពួកគេចូលមកក្នុងថ្នាក់រៀន។
- ឱ្យសិស្សប្រមូលសន្លឹកកិច្ចការរបស់ពួកគេ និងសម្ភារៈសរសេរមុនពេលចូលរៀន។
- មើលបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់រៀនឡើងវិញមុនពេលចាប់ផ្តើមបង្រៀន។

## ២. ដំណើរការបង្រៀន

**សេចក្តីណែនាំ**

- ☞ ស្វាគមន៍សិស្ស បន្ទាប់មកណែនាំប្រាប់ពួកគេឱ្យស្គាល់ ម៉ូឌុលទី២នៃកម្មវិធីសិក្សា Gap Inc. P.A.C.E. ដែលស្ថិតក្រោមផ្នែក «ការផ្តល់ភាពអង់អាច»។ ផ្តល់ឱ្យពួកគេនូវទិដ្ឋភាពសង្ខេបមួយពីអ្វីដែលម៉ូឌុលនេះនឹងគ្របដណ្តប់។ ណែនាំជំពូកទី១ក្នុងម៉ូឌុលទី២ ៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព (សូមមើលឯកសារអំណានទី១នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ អាន និងចង្អុលចំណងជើងមេរៀនដែលសរសេរនៅលើក្តារខៀន។ ឱ្យសិស្សទាយថា តើមេរៀនថ្ងៃនេះនិយាយពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុម។
- ☞ ប្រាប់សិស្សថា នៅថ្ងៃនេះពួកគេត្រូវផ្តោតលើរបៀបធ្វើការផ្លោះទៅរកការកែលម្អបំណិនប្រាស្រ័យទាក់ទងដើម្បីឱ្យពួកគេអាចបង្ហាញទស្សនៈរបស់ខ្លួនដោយមិនស្ទាក់ស្ទើរ និងធ្វើឱ្យអ្នកដទៃអាចស្តាប់ និងយល់ពីខ្លួនបានច្បាស់លាស់។

**សកម្មភាព ៖ ទូរសព្ទខូច**

☞ ប្រមូលសិស្សឱ្យបានច្រើនតាមដែលអាចធ្វើទៅបានឱ្យអង្គុយនៅជួរខាងមុខ មុនពេលចាប់ផ្ដើមសកម្មភាព។

☞ ចែករំលែកការណែនាំដូចខាងក្រោម ៖

- ខ្ញុំនឹងផ្ដល់ឱ្យសិស្សដែលអង្គុយនៅលើបង់ ឬជួរមុខគេនូវក្រដាសតូចមួយដែលមានសសេរសារមួយនៅក្នុងនោះ ។
- សិស្សដែលអង្គុយមុខគេត្រូវតែអានសារនោះស្ងាត់ៗ បន្ទាប់មកឱ្យក្រដាសនោះមកខ្ញុំវិញ។
- បន្ទាប់មកសិស្សនោះត្រូវខ្សឹបសារនោះដាក់ត្រចៀកសិស្សដែលអង្គុយបន្ទាប់ខ្លួន(សិស្សទី២)នៅលើបង់។
- សិស្សទី២ត្រូវស្ដាប់សារនោះ បន្ទាប់មកខ្សឹបដាក់ត្រចៀកសិស្សទី៣។
- តាមរយៈការធ្វើរបៀបនេះ សារត្រូវបញ្ជូនតាមជួរទៅកាន់សិស្សដែលអង្គុយចុងក្រោយបំផុតនៅលើបង់។
- សិស្សចុងក្រោយត្រូវស្ដាប់សារនោះ បន្ទាប់មកនិយាយពីសារនោះឮៗ។

**⊶ គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- កំណត់បទបញ្ជាផ្ទៃក្នុងមួយចំនួនសម្រាប់សកម្មភាពនេះមុនពេលចាប់ផ្ដើម។ បទបញ្ជាទាំងនោះរួមមានដូចខាងក្រោម ៖
  - គេចាំបាច់ត្រូវតែខ្សឹបសារនោះតិចៗ។ មិនត្រូវឱ្យនរណាម្នាក់ស្ដាប់ឮសារនោះទេ។
  - ប្អូនមានឱកាសតែម្ដងប៉ុណ្ណោះក្នុងការខ្សឹបប្រាប់សារនោះទៅឱ្យសិស្សដែលនៅបន្ទាប់ពីប្អូននៅលើបង់។ គេមិនអាចខ្សិបសារនោះឡើងវិញបានទេ។
  - សិស្សដែលទទួលសារមិនអាចនិយាយ ឬសួរសំណួរណាមួយបានទេ។ គេអាចត្រឹមតែស្ដាប់សារប៉ុណ្ណោះ។

☞ នៅពេលសិស្សចុងក្រោយនៅលើបង់និយាយពីសារនោះឮៗហើយ ចូរឱ្យក្រដាសសារនោះទៅឱ្យសិស្សទី១បន្ទាប់មកឱ្យគេអានសារឮៗនូវខ្លឹមសារដើមរបស់សារនោះឱ្យក្រុមទាំងមូលស្ដាប់។

☞ សួរសិស្សនូវសំណួរដូចខាងក្រោម ៖

◈ តើខ្លឹមសារដើមរបស់សារមានការផ្លាស់ប្ដូរដែរឬទេ នៅពេលដែលគេបញ្ជូនវាបន្តគ្នា?

☞ រង់ចាំឱ្យសិស្សឆ្លើយ បន្ទាប់មកប្រាប់ពួកគេដូចខាងក្រោម ៖

- អ្វីដែលយើងប្រាស្រ័យទាក់ទងគឺមិនមែនសុទ្ធតែអ្នកផ្សេងទៀតយល់ទាំងអស់ជានិច្ចទេ។

- មានចន្លោះប្រហោងមួយរវាងអ្វីដែលយើងនិយាយ និងអ្វីដែលគេស្តាប់ឮដែលនាំឱ្យមានការប្រាស្រ័យទាក់ទងខុស និងយល់ខុស។
- ការប្រាស្រ័យទាក់ទងមិនត្រឹមតែការនិយាយតែមួយមុខប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងការស្តាប់ផងដែរ។
- ការប្រាស្រ័យទាក់ទងអាចទាក់ទងនឹងពេលវេលាផងដែរ។ នៅពេលយើងពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការប្រាស្រ័យទាក់ទងពីអ្វីមួយ យើងត្រូវមានភាពច្បាស់លាស់ពីសារសំខាន់ៗដែលយើងចង់បញ្ជូន(ប្រាប់)។
- ការប្រាស្រ័យទាក់ទងជាប់ពាក់ព័ន្ធនឹងទិដ្ឋភាពមួយចំនួន។ ការប្រាស្រ័យទាក់ទងអាចជាពាក្យសម្តី ឬកាយវិការ ហើយអាចទទួលរងឥទ្ធិពលពីកត្តាផ្សេងៗជាច្រើន ដូចជាបុគ្គលិកលក្ខណៈរបស់យើង ពីយេនឌ័រ អំណាច និងបិតាធិបតេយ្យ ពីវប្បធម៌របស់យើង និងពីទំនាក់ទំនងបុគ្គលរបស់យើង។ល។

☞ សួរសំណួរដូចខាងក្រោម ៖

  ◈ ហេតុអ្វីបានជាការប្រាស្រ័យទាក់ទងមានសារៈសំខាន់?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកនូវចំណុចដូចខាងក្រោម ៖

- កិច្ចការជាច្រើនដែលយើងចង់ធ្វើនៅក្នុងជីវិតរបស់យើងអាស្រ័យលើថាតើយើងមានលទ្ធភាពប្រាស្រ័យទាក់ទងពីកិច្ចការនោះជាមួយគ្រួសារ មិត្តភក្តិ សហគមន៍ គ្រូបង្រៀន និងនិយោជករបស់យើងបានដែរឬទេ។ ការមានជំនាញប្រាស្រ័យទាក់ទងល្អមានសារៈសំខាន់ក្នុងការចែករំលែកពីទស្សនៈវិស័យ និងគំនិតរបស់មនុស្សម្នាក់។
- ទំនាក់ទំនងល្អមានសារៈសំខាន់សម្រាប់អត្តសញ្ញាណ លទ្ធភាពធ្វើការងារ និងភាពជោគជ័យរបស់យើងនៅក្នុងជីវិត។
- វាមានសារៈសំខាន់ណាស់ក្នុងការយល់ពីផលប្រយោជន៍នៃការប្រើការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងរបៀបដែលការប្រាស្រ័យទាក់ទងខុសគ្នាចំពោះ ដំណាក់កាលផ្ទាល់ខ្លួន វិជ្ជាជីវៈ និងភាពខុសៗគ្នារបស់យើងនៅក្នុងជីវិត។
- ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក៏ទាក់ទងដែរទៅនឹងសមត្ថភាពដោះស្រាយបញ្ហា ចរចា និងធ្វើការសម្រេចចិត្តផងដែរ។
- ប្រាប់សិស្សថា វគ្គសិក្សាចំនួន៣បន្ទាប់ទៀត ផ្តោតលើការបង្រៀនពួកគេពីប្រភេទខុសៗគ្នានៃការប្រាស្រ័យទាក់ទង របៀបកែលម្អ និងធ្វើឱ្យការប្រាស្រ័យទាក់ទងរបស់ពួកគេកាន់តែមានប្រសិទ្ធភាព ព្រមទាំងរបៀបប្រើប្រាស់ការប្រាស្រ័យទាក់ទងជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការចរចាពីរបាំង និងឧបសគ្គផ្អែកលើយេនឌ័រនៅក្នុងជីវិតរបស់ពួកគេ។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ចូលរួមស្តាប់យ៉ាងសកម្មនៅពេលអនុវត្តជំពូក និងសកម្មភាពទាំងនេះ។
- សកម្មភាព «ទូរសព្ទខូច» កំណត់បរិបទសម្រាប់គ្រូបង្រៀន ក្នុងការចាប់ផ្តើមបង្រៀន បំណិនប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដល់សិស្ស ។

- ចាប់ផ្តើមសកម្មភាព«ការប្រាស្រ័យទាក់ទងដោយបែរខ្នងដាក់គ្នា» ដោយឱ្យសិស្សចាប់ដៃគូគ្នា។
- ហៅសិស្សម្នាក់មកពីគូនីមួយៗបន្ទាប់មកឱ្យពួកគេរើសយកសន្លឹកក្រដាសតូចដែលមានរូបភាពវត្ថុនៅក្នុងក្រដាសនោះ។ សិស្សដែលមានសន្លឹកក្រដាសរូបភាព មិនត្រូវប្រាប់ឈ្មោះរូបភាពនៅក្នុងក្រដាសនោះដល់ដៃគូរបស់ខ្លួន ឬនរណាម្នាក់ផ្សេងទៀតឡើយ។
- សិស្សទី២មកពីគូនីមួយៗ ប្រមូលក្រដាស A4 មួយសន្លឹក និងដៃខ្មៅមួយដើម។
- ឱ្យដៃគូរបស់ក្រុមនីមួយៗអង្គុយទល់ខ្នងគ្នា។
- សម្រាប់សិស្សដែលមានក្រដាសរូបភាពត្រូវ ៖
  - ពណ៌នាពីរូបភាព នៅក្នុងក្រដាសនោះប្រាប់ដល់ដៃគូរបស់ខ្លួនមួយជំហានម្តងៗ។
  - ប្អូនមិនអាចអានសេចក្តីណែនាំ ឬប្រយោគនោះឡើងវិញលើសពីម្តងឡើយ។
  - ប្អូនមិនអាចដាក់ឈ្មោះវត្ថុនៅក្នុងក្រដាសរបស់ប្អូន ឬប្រាប់ដៃគូរបស់ប្អូនថាវាជាអ្វីទេ។
- សម្រាប់សិស្សដែលមានក្រដាស A4 ៖
  - ស្តាប់សេចក្តីណែនាំដែលដៃគូរបស់ប្អូនផ្តល់ឱ្យនិងគូរនូវអ្វីដែលដៃគូបានពណ៌នា។
  - ប្អូនមិនអាចនិយាយ ឬសួរសំណួរណាមួយដើម្បីបញ្ជាក់ឡើយ។
  - ប្អូនអាចត្រឹមតែស្តាប់ប៉ុណ្ណោះ បន្ទាប់មកគូរអ្វីដែលប្អូនយល់ពីការណែនាំនោះ។
- ប្រាប់សិស្សថា ពួកគេមានពេល៥នាទីដើម្បីអនុវត្តសកម្មភាពនេះ។
- នៅពេលចប់ ឱ្យដៃគូនីមួយៗប្រៀបធៀបរូបភាពវត្ថុនៅក្នុងក្រដាសជាមួយរូបដែលបានគូរ។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូ ៖

- ប្រសិនបើក្នុងថ្នាក់មានសិស្សច្រើន កម្រិតសំឡេងអាចនឹងកើនឡើង ហើយនឹងរំខានដល់សិស្សទូទៅ។ សូមធានាថា លោកគ្រូ អ្នកគ្រូរំឭកសិស្សជានិច្ចឱ្យនិយាយតិចៗល្មមដៃគូរបស់ខ្លួនស្តាប់បានហើយ ។

## ៣. ការពង្រឹងចំណេះដឹង

### 🗣 ចំណុចសម្រាប់ការពិភាក្សា

☞ សួរសិស្ស នូវសំណួរដូចខាងក្រោម ៖

- ◈ តើរូបភាពដែលគេបានគូរនោះដូចគ្នាទៅនឹងរូបភាពនៅក្នុងក្រដាសដែរឬទេ?
- ◈ តើដៃគូរបស់ប្អូនប្រាស្រ័យទាក់ទងជាមួយប្អូនយ៉ាងដូចម្ដេចពីអ្វីដែលចាំបាច់សម្រាប់ការគូររូបនោះ?
- ◈ តើប្អូនស្ដាប់ការណែនាំរបស់ដៃគូប្អូនដោយប្រុងប្រយ័ត្នដែរឬទេពេលប្អូនកំពុងគូររូបនោះ?
- ◈ ប្រសិនបើប្អូនធ្វើសកម្មភាពនេះម្ដងទៀត តើប្អូននឹងកែលម្អយ៉ាងដូចម្ដេចចំពោះការប្រាស្រ័យទាក់ទងរបស់ប្អូនដើម្បីសម្រេចបានលទ្ធផលល្អប្រសើរជាងនេះ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកនូវចំណុចដូចខាងក្រោម ៖

- ការប្រាស្រ័យទាក់ទងដោយពាក្យសម្ដី ៖ សម្រាប់អ្នកទាំងឡាយណាដែលអាចនិយាយបាន ការប្រាស្រ័យទាក់ទងដោយពាក្យសម្ដីមានការចាំបាច់ក្នុងជីវិតប្រចាំថ្ងៃដោយចាប់ផ្ដើមពីការប្រាស្រ័យទាក់ទងប្រចាំថ្ងៃជាមួយសមាជិកគ្រួសារ គ្រូបង្រៀន មិត្តភ័ក្តិ និងដៃគូ។ ដោយមានការបង្កើតការប្រាស្រ័យទាក់ទងនេះ វាមានសារៈសំខាន់ដែលយើងយល់ពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។
- វាមានសារៈសំខាន់ដែលត្រូវចងចាំថា ការប្រាស្រ័យទាក់ទងមិនមែនមានតែម្ខាងទេ ប៉ុន្តែវាជាដំណើរការដែលមានទាំងសងខាង។ នៅពេលប្អូននិយាយទៅកាន់នរណាម្នាក់ ពួកគេមិនអាចសុទ្ធតែយល់ពីការនិយាយដូចអ្វីដែលប្អូនចង់និយាយជានិច្ចនោះទេ ហើយហេតុដូច្នេះហើយប្អូនចាំបាច់ត្រូវប្រាកដថា មនុស្សដែលប្អូនកំពុងប្រាស្រ័យទាក់ទងជាមួយបានយល់ពីសារតាមលក្ខណៈដែលប្អូនមានបំណងឱ្យគេយល់នោះ។
- ការប្រាស្រ័យទាក់ទងដោយពាក្យសម្ដីប្រកបដោយប្រសិទ្ធភាព ជារឿយៗ មានន័យថា ជាការទទួលបានព័ត៌មានត្រលប់មួយរវាងអ្នកផ្ញើ និងអ្នកទទួល។

> **🗝 គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - ប្រើដ្យាក្រាមនៅលើក្ដារខៀនដើម្បីជួយសិស្សឱ្យយល់កាន់តែទូលំទូលាយថែមទៀត។

☞ ចង្អុលទៅកាន់ដ្យាក្រាមនៅលើក្ដារខៀន បន្ទាប់មកពន្យល់ពីដំណើរការនៃការផ្ដល់និងទទួលព័ត៌មានត្រលប់របស់អ្នកបញ្ជូន និងអ្នកទទួល។

☞ ចែករំលែកចំណុចដូចខាងក្រោម ៖

- នៅក្នុងការផ្ដល់ព័ត៌មានត្រលប់ អ្នកបញ្ជូនបានបញ្ជូនសារមួយទៅកាន់អ្នកទទួល បន្ទាប់មកអ្នកទទួលបានប្រាស្រ័យទាក់ទងមកអ្នកបញ្ជូន ឬផ្ដល់ព័ត៌មានត្រលប់។
- នៅក្នុងការផ្ដល់ព័ត៌មានត្រលប់នេះ វាអាចមានឧបសគ្គ ឬការរាំងស្ទះចំពោះការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដែលគេក៏អាចហៅវាថាជា «សំឡេងរំខាន» (សូមមើលឯកសារអំណានទី១ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន ដើម្បីពន្យល់ថាតើមានកត្តាអ្វីខ្លះដែលអាចដើរតួនាទី ជាសំឡេងរំខាននោះ)។

☞ សួរសិស្ស នូវសំណួរដូចខាងក្រោម ៖

- តើយើងកែលម្អការប្រាស្រ័យទាក់ទងជា ពាក្យសម្ដីរបស់យើងដោយរបៀបណា ដែលធ្វើឱ្យទាំងអ្នកបញ្ជូននិងអ្នកទទួលអាចយល់រឿងដូចគ្នា? តើយើងអាចធានាថាការណ៍នេះកើតឡើងយ៉ាងដូចម្ដេច?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចខាងក្រោម ៖

- ដើម្បីអាចឱ្យយល់កាន់តែច្បាស់ ការប្រាស្រ័យទាក់ទងដោយពាក្យសម្ដីចាំបាច់ត្រូវមានភាពច្បាស់លាស់និងខ្លីៗ។
- ដើម្បីអនុវត្តបំណិនប្រាស្រ័យទាក់ទងដោយពាក្យសម្ដីឱ្យមានប្រសិទ្ធភាពចំណុចខាងក្រោមនេះមានសារៈសំខាន់ណាស់ ៖

ពិចារណាពីទីកន្លែងដែលត្រូវនិយាយ អ្វីដែលប្អូនត្រូវនិយាយ និងនិយាយទៅកាន់នរណា (ពេលវេលាទីកន្លែង និងស្ថានភាព ឬបរិបទ)។ ឧទាហរណ៍ ប្រសិនបើប្អូនចង់ចុះឈ្មោះចូលរៀនថ្នាក់រាំរបាំបន្ទាប់ពីចេញពីសាលា ហើយប្អូនមានអារម្មណ៍ខ្លាចក្នុងការសុំអនុញ្ញាត វាគេជាភាពឆ្លាតវៃក្នុងការនិយាយជាមួយឪពុកម្ដាយរបស់ប្អូននៅពេលពួកគាត់មានពេលទំនេរ ព្រមទាំងនៅក្នុងទីកន្លែងឯកជន ឬដែលមានផាសុកភាពដូចជាផ្ទះរបស់ប្អូនជាដើម។ ប្រសិនបើប្អូនគិតថា ឪពុកម្ដាយរបស់ប្អូនអាចមិនយល់ព្រម វាគឺជាការប្រសើរបំផុតប្រសិនបើប្អូនពន្យល់ពីមូលហេតុដែលប្អូនចង់ចូលរៀនរាំរបាំនោះដែលផ្ទុយទៅនឹងការទទូចសុំការអនុញ្ញាតពីពួកគាត់។ ឪពុកម្ដាយអាចយល់ពីទស្សនៈរបស់ប្អូនប្រសិនបើប្អូនពន្យល់ពួកគាត់ដោយត្រជាក់ចិត្តមានហេតុផលត្រឹមត្រូវ និងនៅទីកន្លែងមានផាសុកភាព។

១. ដឹងពីពេលវេលាត្រូវនិយាយ ដោយចងចាំពីទីកន្លែង និងបរិបទនៃ «ពេលវេលា ទីកន្លែង និងស្ថានភាព ឬបរិបទ» ដែលជាយុទ្ធសាស្ត្រសំខាន់ក្នុងការចរចាប្រកបដោយប្រសិទ្ធភាពគួរជាទីពេញចិត្ត ជាពិសេសនៅក្នុងស្ថានភាពនានានៅពេលដែលប្អូនកំពុងប្រឈមជាមួយរចនាសម្ព័ន្ធ តាមឋានានុក្រម។

២. ការមានភាពច្បាស់លាស់ និងខ្លីៗចំពោះការប្រាស្រ័យទាក់ទងដោយពាក្យសម្ដីរបស់ប្អូនគឺជាបំណិនជីវិតដ៏សំខាន់មួយដែលគេចាំបាច់ត្រូវអនុវត្ត។

៣. ទិដ្ឋភាពសំខាន់បំផុតក្នុងការប្រាស្រ័យទាក់ទងដោយពាក្យសម្ដី គឺជាការបញ្ជាក់យ៉ាងច្បាស់លាស់និងប្រកបដោយប្រសិទ្ធភាព។ សម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព មនុស្សចាំបាច់ត្រូវអនុវត្តជំហានសំខាន់ៗមួយចំនួន (សូមមើលឯកសារអំណានទី១នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។

☞ ប្រសិនបើមានពេល សូមសរុបសេចក្ដីនៃមេរៀននេះ។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី១ ៖ ឯកសារអំណានសម្រាប់គ្រូបង្រៀន

**បរិបទចំណេះដឹង ៖ ការរាំងស្ទះចំពោះការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ៖ ឧបសគ្គ**

នៅក្នុងការផ្តល់ព័ត៌មានត្រលប់ អ្នកបញ្ជូនបញ្ជូនសារទៅកាន់អ្នកទទួល ហើយបន្ទាប់មកអ្នកទទួលប្រាស្រ័យទាក់ទងមកអ្នកបញ្ជូន ឬផ្តល់ព័ត៌មានត្រលប់មកវិញ។ នៅក្នុងការប្រាស្រ័យទាក់ទងនេះអាចមានការរំខាន ឬការរាំងស្ទះចំពោះការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដែលគេអាចហៅថាជា «ឧបសគ្គ» បានដែរ។ កត្តាណាមួយក្នុងចំណោមកត្តាខាងក្រោមនេះអាចជាឧបសគ្គមួយសម្រាប់ការប្រាស្រ័យទាក់ទង ៖

- **គម្លាតអាយុ** ៖ ជារឿយៗ មនុស្សដែលមានវ័យ(ជំនាន់)ខុសគ្នាមានទស្សនៈខុសគ្នា ហើយចំពោះករណីនៃការប្រាស្រ័យទាក់ទងដែលមិនមានប្រសិទ្ធភាពអាចធ្វើឱ្យពួកគេមិនអាចមើលឃើញពីទស្សនៈវិស័យរបស់គ្នាទៅវិញទៅមក។
- **ភាពខុសគ្នាផ្នែកវប្បធម៌** ៖ ប្រពៃណីវប្បធម៌នៅគ្រប់តំបន់ និងប្រទេសខុសៗគ្នាបង្ហាញពីរបៀបដែលយើងប្រាស្រ័យទាក់ទង និងធ្វើអន្តរកម្មទៅវិញទៅមក។ ឧទាហរណ៍ វិធីជាច្រើនដែលមនុស្សមានវប្បធម៌ខុសៗគ្នានៅទូទាំងសកលលោកស្វាគមន៍គ្នា។ នៅក្នុងប្រទេសកម្ពុជា ជាទូទៅប្រជាជនស្វាគមន៍គ្នាដោយការសំពះគ្នាទៅវិញទៅមក ហើយនិយាយថា «ជំរាបសួរ»។ នៅលោកខាងលិច ជាធម្មតាពួកគេចាប់ដៃគ្នារលាក់ ឬនិយាយថា «សួស្តី» ចំណែកនៅក្នុងប្រទេសជប៉ុនវិញ ពួកគេឱនដាក់គ្នានៅពេលស្វាគមន៍គ្នា និងគោរពគ្នា។ ដូច្នេះ វាសបញ្ជាក់ឱ្យឃើញថា វប្បធម៌មានឥទ្ធិពលលើការប្រាស្រ័យទាក់ទង ។
- **យេនឌ័រ** ៖ ជារឿយៗ របៀបដែលយើងប្រាស្រ័យទាក់ទងរងឥទ្ធិពលពីលក្ខខណ្ឌយេនឌ័រ និងសង្គមរបស់យើង ឧទាហរណ៍ របៀបដែលគេរំពឹងទុកថាស្ត្រី ឬក្មេងស្រីនិយាយ និងស្តាប់គឺខុសគ្នាយ៉ាងខ្លាំងពីរបៀបដែលសង្គមរំពឹងទុកពីការប្រាស្រ័យទាក់ទងរបស់បុរស ឬក្មេងប្រុស។
- **អំណាច ឬឋានានុក្រម** ៖ លទ្ធភាពក្នុងការប្រាស្រ័យទាក់ទងពីគំនិតរបស់យើងទទួលរងឥទ្ធិពលនៅពេលដែលមានអំណាចដែលមានលក្ខណៈជាមរតក ឬជាឋានានុក្រម (ឧទាហរណ៍ របៀបដែលយើងប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិយើងគឺមានលក្ខណៈខុសគ្នាពីរបៀបដែលយើងប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយ ឬនាយកសាលារបស់យើង)។

**បរិបទចំណេះដឹង ៖ ការប្រាស្រ័យទាក់ទងជាពាក្យសម្តី ៖ ការបញ្ចេញមតិប្រកបដោយប្រសិទ្ធភាព**

- **មានគំនិតច្បាស់លាស់ ៖** គិតឱ្យបានច្បាស់លាស់ពីអ្វីដែលប្អូនត្រូវនិយាយមុនពេលដែលប្អូននិយាយវា។ ជានិច្ចកាល ប្អូនត្រូវនិយាយពីគំនិតមួយរបស់ប្អូនឱ្យបានចប់សិនមុនពេលប្អូននិយាយគំនិតមួយទៀត។
- **ការនិយាយរៀបរាប់ និងសំឡេងច្បាស់លាស់ ៖** និយាយដោយប្រើពាក្យសាមញ្ញៗ។ ជ្រើសរើសពាក្យរបស់ប្អូនដោយប្រុងប្រយ័ត្ន និងនិយាយឡើងវិញពីព័ត៌មានសំខាន់ៗ។
- **សំឡេងសមល្មម និងអាចស្តាប់បាន ៖** សំឡេងនិយាយរបស់ប្អូនត្រូវឱ្យឮល្មម ដើម្បីឱ្យគេអាចស្តាប់ប្អូនបាន។ សម្រួលសំឡេងដែលប្អូននិយាយដើម្បីឱ្យអ្នកនៅជុំវិញប្អូន និងប្អូនស្តាប់បាន។
- **ការលើកដាក់សំឡេង និងការបញ្ជាក់ឱ្យបានសមស្រប ៖** នៅពេលនិយាយ ការលើកដាក់សំឡេងរបស់ប្អូនគឺជារឿងសំខាន់។ ប្អូនត្រូវតែដឹងថា ពាក្យណាខ្លះដែលប្អូនចង់សង្កត់ធ្ងន់។
- **រក្សាភាពស្ងប់ស្ងាត់ និងការគោរព ៖** ត្រូវតាំងចិត្តឱ្យស្ងប់ និងដោយគោរព នៅពេលប្អូននិយាយ។ ការណ៍នេះបង្កើតទំនាក់ទំនង និងបង្ហាញការគោរពចំពោះមនុស្សដែលប្អូនកំពុងប្រាស្រ័យទាក់ទងជាមួយ។
- **ការស្តាប់ដោយសកម្ម ៖** ការស្តាប់គឺជាបំណិនដ៏សំខាន់មួយនៅពេលប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយសារប្អូនអាចសិក្សាពីអ្វីដែលអ្នកដទៃទៀតចង់បាន និងចង់និយាយ។ ដើម្បីយល់ឱ្យបានច្បាស់លាស់ពីសារដែលគេចង់បញ្ជូនមកឱ្យ វាមានសារៈសំខាន់ណាស់ដែលប្អូនសួរសំណួរដើម្បីបញ្ជាក់ពីអត្ថន័យរបស់វាឱ្យបានច្បាស់។ វាក៏មានសារៈសំខាន់ដែរក្នុងការបញ្ជាក់ថា អ្នកផ្សេងទៀតក៏យល់ពីសាររបស់ប្អូនដែរ។ ប្អូនអាចបញ្ជាក់រឿងនេះបានតាមរយៈការសួរសំណួរផ្សេងៗ។
- **របៀបប្រាស្រ័យទាក់ទង ៖** របៀបប្រាស្រ័យទាក់ទងរបស់ប្អូនគួរពន្យល់ពីអ្វីដែលចង់និយាយទៅកាន់អ្នកដទៃទៀត ពោលគឺទាំងការនិយាយទៅកាន់មនុស្សដែលមានឋានៈខ្ពស់ជាង និងទាបជាងប្អូន។

## ឯកសារអំណានទី២ ៖ គំរូសារសម្រាប់រឿង «ទូរសព្ទខូច»

នីតា បណ្ដែតទូកពណ៌ប្រាក់នៅក្នុងកន្លែងដក់ទឹកភ្លៀងរាក់មួយនៅក្រោមដើមឈើមួយដើម។

រ៉ានី បានឈប់ រលាស់សក់នាង និងបោសដៃ និងជើងនាងដើម្បីឱ្យស្ងួតទឹកនៅពេលនាងរត់កាត់ភ្លៀងខ្លាំងទៅផ្ទះ។

ស៊ីណា និងបងស្រីនាងលក់ខ្យងសមុទ្រនៅមាត់សមុទ្រនៅពេលមេឃស្រឡះនៅរដូវក្ដៅ។

**សេចក្ដីណែនាំ ៖**

- ប្រើក្រដាសតូចៗ និងហ្វឺតដើម្បីសរសេរប្រយោគខាងលើសម្រាប់សកម្មភាពនេះ។
- ជ្រើសរើសប្រយោគណាមួយក្នុងចំណោមប្រយោគដែលគេផ្ដល់ឱ្យខាងលើ និងសរសេរនៅក្នុងក្រដាសតូច។
- ត្រូវសរសេរប្រយោគនោះឱ្យបានច្បាស់ និងងាយអាន។
- បត់និងយកក្រដាសតូចនេះតាមខ្លួនសម្រាប់សកម្មភាពនេះ។

**គន្លឹះសម្រាប់គ្រូបង្រៀន ៖** លោកគ្រូ អ្នកគ្រូអាចពិចារណាក្នុងការប្រើប្រាស់ប្រយោគផ្ទាល់ខ្លួនជំនួសឱ្យប្រយោគដែលគេផ្ដល់ឱ្យខាងលើ។ ប្រសិនបើលោកគ្រូ អ្នកគ្រូពិចារណាប្រើប្រាស់ប្រយោគផ្ទាល់ខ្លួន ចូរធានាថាប្រយោគរបស់លោកគ្រូ អ្នកគ្រូមានពាក្យជាអប្បបរមាពី ១០ ទៅ ១៥ពាក្យ។

## ឯកសារអំណានទី៣ ៖ បណ្ណរូបភាព ៖ សន្លឹកទី១



**គន្លឹះសម្រាប់គ្រូបង្រៀន ៖**

- ឯកសារអំណានទី៣ ផ្តល់ឱ្យលោកគ្រូ អ្នកគ្រូនូវរូបភាពរបស់វត្ថុផ្សេងៗសម្រាប់សកម្មភាពនេះ «ការប្រាស្រ័យទាក់ទងខ្នងទល់ខ្នង» ។ លោកគ្រូ អ្នកគ្រូមានបណ្ណរូបភាពទាំងអស់ចំនួន១៨សន្លឹក។ ត្រូវផ្តល់បណ្ណរូបភាពមួយសន្លឹងឱ្យសិស្ស២នាក់។
- ថតចម្លងបណ្ណរូបភាពទាំង២ទៅតាមចំនួនសិស្សជាក់ស្តែងនៅក្នុងថ្នាក់របស់លោកគ្រូ អ្នកគ្រូ។

**សេចក្តីណែនាំ ៖**

- ថតចម្លងបណ្ណរូបភាព និងកាត់រូបភាពនីមួយៗទៅតាមបន្ទាត់ដុតៗ។ បត់ក្រដាសរូបភាពនីមួយៗត្រឹមពាក់កណ្តាល។
- រៀបចំបណ្ណរូបភាពនេះឱ្យបានរួចរាល់សម្រាប់ប្រើនៅពេលអនុវត្តសកម្មភាពនេះ។

## បណ្ណរូបភាព ៖ សន្លឹកទី២



**សេចក្ដីណែនាំ ៖**

- ថតចម្លងបណ្ណរូបភាព។
- អនុវត្តតាមការណែនាំដូចមាននៅក្នុងឯកសារអំណានទី៣។

**ឯកសារអំណានទី៤ ៖ ដ្យាក្រាមស្តីពីព័ត៌មានត្រលប់រវាងអ្នកផ្ញើ និងអ្នកទទួល**




**សេចក្តីណែនាំ ៖**

– ថតចម្លងបណ្ណ(ដ្យាក្រាម)នេះមួយច្បាប់។
– ប្រើដ្យាក្រាមនេះជាឯកសារយោង នៅពេលគូរដ្យាក្រាមនេះនៅលើក្តារខៀន និងនៅពេលបំពេញឃ្លានៅពេលអនុវត្តសកម្មភាព។
– ជាជម្រើស លោកគ្រូ អ្នកគ្រូអាចប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀនបានដោយយោងទៅលើទំព័រនេះ។

# មេរៀនទី២ ៖ ការប្រាស្រ័យទាក់ទងដោយប្រើកាយវិការ

➲ **វត្ថុបំណងមេរៀន** ៖ ដើម្បីយល់ឱ្យកាន់តែទូលំទូលាយពីការប្រាស្រ័យទាក់ទងដោយកាយវិការ ថាជាផ្នែកដ៏សំខាន់មួយនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងដើម្បីសិក្សាថា តើភាសាកាយវិការអាចបំពេញបន្ថែមទៅលើសមត្ថភាពរបស់នរណាម្នាក់ក្នុងការប្រាស្រ័យទាក់ទងល្អកម្រិតណា។

🕒 **រយៈពេលមេរៀន** ៖ ៤៥ នាទី

✉ **សារសំខាន់ៗ** ៖

១. ការប្រាស្រ័យទាក់ទងដោយប្រើកាយវិការគឺជាផ្នែកមួយដែលមិនអាចខ្វះបានចំពោះការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ ការប្រាស្រ័យទាក់ទងមានលើសពីការប្រើប្រាស់ពាក្យសម្ដីទៅទៀត។ វាមានផ្នែកសំខាន់ៗផ្សេងៗទៀតដូចជាភាសាកាយវិការ ការលើកដាក់សំឡេង កាយវិការ អាកប្បកិរិយា និងជម្រើសនៃការប្រើពាក្យ។ សូរសំឡេងរបស់យើងរួមមាន រលកសំឡេងខ្ពស់ទាប ការលើកដាក់សំឡេង និងកម្រិតសំឡេងក៏ជាទម្រង់នៃការប្រាស្រ័យទាក់ទងជាកាយវិការដែរ។ ការប្រើភាសាសញ្ញា និងការប៉ះដើម្បីបង្ហាញ និងមានអារម្មណ៍ក៏ជាលក្ខណៈសំខាន់នៃការប្រាស្រ័យទាក់ទងដែរ។

២. ការប្រាស្រ័យទាក់ទងរវាងបុគ្គលនានាមានទាំងការបង្ហាញអត្ថន័យច្បាស់លាស់របស់ពាក្យនានា ព័ត៌មាន ឬសារដែលគេបញ្ជូន និងសារមិនច្បាស់លាស់ដែលគេបង្ហាញតាមរយៈអាកប្បកិរិយាមិនមែនពាក្យសម្ដី។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាសព័ត៌មាន២សន្លឹក ហ្វឺតពណ៌ខ្មៅមួយដើម ស្កុត កន្ត្រៃ បន្ទាត់ ផ្ទាំងរូបភាពដែលមានពពណ៌ខុសៗគ្នា ច្រាស់លាបថ្នាំដែលមានកម្រាសក្រាស់មួយដើម ខ្មៅដៃមួយដើម។

☞ សម្រាប់សិស្ស ៖ មិនមាន។

**ការរៀបចំទុកជាមុន ៖**

- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ឯកសារអំណានទី៥ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។
- បង្កើតបណ្ណពាក្យទាក់ទងនឹងអារម្មណ៍ និងសកម្មភាព(យោងទៅលើឯកសារអំណានទី៦នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- រៀបចំដ្យាក្រាមរាងមូល «ផ្នែកចំនួន៣នៃការប្រាស្រ័យទាក់ទង(យោងទៅលើឯកសារអំណានទី៧នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)»។
- បិទដ្យាក្រាមនៅលើជញ្ជាំងក្នុងបន្ទប់រៀន។
- ប្រមូលសម្ភារៈដែលចាំបាច់ទាំងអស់ផ្សេងៗទៀត។
- សរសេរចំណងជើងមេរៀនដាក់នៅលើក្ដារខៀន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្ស ឱ្យចុះវត្តមាន នៅពេលពួកចូលមកក្នុងថ្នាក់រៀន។
- ឱ្យពួកគេប្រមូលសន្លឹកកិច្ចការរបស់ខ្លួន និងសម្ភារៈសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

**សេចក្ដីណែនាំ**

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- អាន និងចង្អុលចំណងជើងនៅលើក្ដារខៀន។ ឱ្យសិស្សទាយថាមេរៀនថ្ងៃនេះនឹងរៀនពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុម។
- ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះនឹងផ្ដោតលើការប្រាស្រ័យទាក់ទងដោយកាយវិការ និងអត្ថន័យនៃការប្រាស្រ័យទាក់ទងដោយកាយវិការ។
- សួរសំណួរដូចខាងក្រោម ៖
  - តើយើងធ្វើការប្រាស្រ័យទាក់ទងដោយកាយវិការយ៉ាងដូចម្ដេច?
- ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– យើងប្រាស្រ័យទាក់ទងដោយកាយវិការតាមវិធីខុសគ្នាជាច្រើន (ឧទាហរណ៍ ការញញឹម ការសើច ការបក់ដៃ ការប្រើកាយវិការដៃ ការបង្ហាញទឹកមុខ និងរាងកាយ ការសរសេរ ការធ្វើសញ្ញាជាដើម)។
– ការប្រាស្រ័យទាក់ទងជាច្រើនរបស់យើងគឺធ្វើឡើងតាមរយៈកាយវិការ ដែលគេកំណត់ថា ជាការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យសម្ដី។ ការប្រាស្រ័យទាក់ទងទាំងនេះរួមមានអាកប្បកិរិយានានាដូចជា ការបង្ហាញទឹកមុខ ការប្រើក្រសែភ្នែកនិងចលនាភ្នែក ការស្ទាបឬប៉ះ ការលើកដាក់សំឡេងក៏ដូចជាសារដែលមានលក្ខណៈច្បាស់លាស់តិចតួចដូចជា សម្លៀកបំពាក់ កាយវិការ និងគម្លាតរវាងមនុស្សពីរឬច្រើននាក់។
– មនុស្សប្រើការប្រាស្រ័យទាក់ទងដោយកាយវិការដើម្បីបង្ហាញពីអារម្មណ៍ខុសៗគ្នាជាច្រើន ទាំងវិជ្ជមាន និងអវិជ្ជមាន (ឧទាហរណ៍ មនុស្សម្នាក់អាចប្រាស្រ័យទាក់ទងពីការយល់ព្រមដោយងក់ក្បាល ឬការមិនយល់ព្រមដោយគ្រវីក្បាល)។

☞ បែងចែកសិស្ស ទៅជាក្រុមតូចៗដោយក្នុងមួយក្រុមៗមានសមាជិក៥នាក់។

☞ ចែកបណ្ណចំនួន២ *(អារម្មណ៍ និង សកម្មភាព)* ឱ្យក្រុមនីមួយៗ។ ប្រាប់សិស្សថា មិនត្រូវប្រាប់ក្រុមផ្សេងទៀតពីពាក្យដែលពួកគេមាននៅក្នុងបណ្ណរបស់ខ្លួនឡើយ។

☞ ប្រាប់សិស្សថា ពួកគេមានពេល ៥នាទីដើម្បីអនុវត្តរបៀបដែលពួកគេនឹងប្រាស្រ័យទាក់ទងចំពោះពាក្យដែលមាននៅក្នុងបណ្ណទាំងពីររបស់ខ្លួនទៅដល់ក្រុមទាំងអស់ដោយប្រើការប្រាស្រ័យទាក់ទងដោយកាយវិការ។

☞ បន្ទាប់មកឱ្យក្រុមនីមួយៗប្ដូរវេនគ្នាឡើងបង្ហាញពាក្យនៅក្នុងបណ្ណរបស់ខ្លួនដោយស្ងៀមស្ងាត់។

☞ ក្រោយពីបង្ហាញពីពាក្យនីមួយៗរួចហើយ ឱ្យក្រុមផ្សេងទៀតទាយពីអារម្មណ៍ ឬសកម្មភាព។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្ស ឱ្យនិយាយតិចៗ នៅពេលអនុវត្ត ដើម្បីកុំឱ្យរំខានអ្នកដទៃ។

☞ ប្រមូលផ្ដុំគ្នាជាក្រុមធំវិញ។

☞ ប្រើដ្យាក្រាមរាងមូល (pie chart) ស្ដីពីការប្រាស្រ័យទាក់ទងដើម្បីពន្យល់ចំណុចដូចខាងក្រោម៖

– ការប្រាស្រ័យទាក់ទងមិនមែនគ្រាន់តែជាសកម្មភាពរាងកាយនោះទេ។ ដំណើរការនៃការប្រាស្រ័យទាក់ទងក៏មានផលប៉ះពាល់ផ្នែកចិត្តសាស្ត្រដែរ។

– របៀបដែលយើងប្រាស្រ័យទាក់ទង ជួយយើងឱ្យចែករំលែកពីគំនិតផ្ទាល់របស់យើងស្តីពីប្រធានបទណាមួយ។ យើងអាចមានឥទ្ធិពលលើអ្នកផ្សេងទៀតតាមលក្ខណ:ដែលយើងជ្រើសរើសធ្វើការប្រាស្រ័យទាក់ទង។
– ភាសាកាយវិការក៏ជាមធ្យោបាយមួយនៃការបង្ហាញពីអារម្មណ៍និងគំនិតរបស់មនុស្សដែរ។
– ភាសាកាយវិការរួមមានចលនារាងកាយ (ជើង ដៃ ប្រអប់ដៃ ក្បាល និងដងខ្លួន) អាកប្បកិរិយា ការដំឡើងសាច់ដុំ ការប្រើក្រសែភ្នែក ការឡើងពណ៌ស្បែក *(មុខឡើងក្រហម)* ចង្វាក់ដង្ហើម និងការបែកញើស។ ជាងនេះទៅទៀត ការលើកដាក់សំឡេង ល្បឿនក្នុងការនិយាយ និងសូរសំឡេងនិយាយទាំងអស់នេះបញ្ជាក់បន្ថែមពីលើពាក្យដែលគេនឹងនិយាយ។
– ការប្រាស្រ័យទាក់ទងដោយកាយវិការមានសារ:សំខាន់ណាស់ ហើយពិតណាស់វាមានចំនួន៩៣% នៃការប្រាស្រ័យទាក់ទងប្រចាំថ្ងៃទាំងអស់។
– ការស្រាវជ្រាវបង្ហាញថា ៧%នៃសារណាមួយត្រូវបានគេបញ្ជូនតាមរយ:ពាក្យសម្តី ៣៨% តាមរយ:សូរសំឡេងមួយចំនួន *(ការផ្លាស់ប្តូរសំឡេងរបស់យើង)* និង ៥៥%តាមរយ: កាយវិការ *(ការបង្ហាញទឹកមុខ កាយវិការ អាកប្បកិរិយាជាដើម)*។

☞ សួរសំណួរដូចខាងក្រោម៖

◈ តើពាក្យ «ភាសាកាយវិការ» មានន័យដូចម្តេចក្នុងបរិបទនៃការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យសម្តី?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– ជារឿយៗ មនុស្សប្រើភាសាកាយវិការជាទម្រង់មួយនៃការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យសម្តីដើម្បីបង្ហាញពីអារម្មណ៍ ឬបំណងមួយចំនួន។ ឧទាហរណ៍ទូទៅនៃភាសាកាយវិការរួមមាន អាកប្បកិរិយា កាយវិការ ការបង្ហាញទឹកមុខ និងការប្រើក្រសែភ្នែកដែលបង្ហាញឱ្យឃើញនូវសញ្ញាមួយចំនួនថាតើមនុស្សម្នាក់កំពុងមានអារម្មណ៍ពិតប្រាកដរបៀបណា។
– ភាសាកាយវិការល្អអាចបង្ហាញឱ្យឃើញថាតើមនុស្សម្នាក់មានភាពជឿជាក់កម្រិតណា។ ឧទាហរណ៍ មនុស្សដែលមានភាពជឿជាក់នឹងបង្ហាញពីប្រភេទភាសាកាយវិការដូចខាងក្រោម ៖
    - អាកប្បកិរិយា ៖ ឈរត្រង់ខ្លួន។
    - ភ្នែក ៖ ការប្រើក្រសែភ្នែកបានល្អ។
    - កាយវិការដោយប្រើប្រអប់ដៃ និងដៃ ៖ ដោយចេតនា និងមានគោលបំណងជាក់លាក់។
    - សម្តី ៖ យឺតៗ និងច្បាស់ៗ។
    - ការលើកដាក់សំឡេង ៖ ពីពួមធ្យមទៅពួតិចៗ។

## ៣. ការពង្រឹងចំណេះដឹង

### 🗣 ចំណុចសម្រាប់ការពិភាក្សា

☞ សួរសំណួរដូចខាងក្រោម ៖

- ◈ ហេតុអ្វីបានជាមនុស្សប្រើការប្រាស្រ័យទាក់ទងដោយកាយវិការជំនួសឱ្យការបង្ហាញពីគំនិតរបស់ខ្លួនជាពាក្យសម្តី?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចខាងក្រោម ៖

- ពេលខ្លះ វាមានភាពងាយស្រួលក្នុងការឆ្លើយតបតាមរយៈការប្រាស្រ័យទាក់ទងដោយប្រើកាយវិការជាងការនិយាយពីអ្វីដែលមនុស្សម្នាក់កំពុងគិត។
- គេអាចប្រើការប្រាស្រ័យទាក់ទងដោយកាយវិការជាឧបករណ៍មួយសម្រាប់ដោះស្រាយ ឬចរចា ជាពិសេសចំពោះរចនាសម្ព័ន្ធដែលពាក់ព័ន្ធខ្លាំងនឹងអំណាច (ឧទាហរណ៍ ចូរយើងក្រឡេកមើលនៅក្នុងថ្នាក់រៀនដែលសិស្សមិនចង់ស្តាប់គ្រូបង្រៀន ហើយឱនក្បាលចុះនៅលើតុរបស់ពួកគេ)។
- គេអាចប្រើប្រាស់ការប្រាស្រ័យទាក់ទងដោយកាយវិការនៅពេលដែលវាមានការលំបាកសម្រាប់មនុស្សមានអំណាចតិចតួចក្នុងការបដិសេធដោយប្រើពាក្យសម្តី ឬដោយបើកចំហនៅក្នុងស្ថានភាពជាក់លាក់មួយចំពោះមនុស្សមានអំណាចច្រើន។
- ការប្រាស្រ័យទាក់ទងដោយកាយវិការមិនមែនមានន័យថាជាការប្រើកាយវិការទាំងអស់ទេ។ ការរក្សាភាពស្ងៀមស្ងាត់ក៏ជាឧបករណ៍ដ៏មានអំណាចមួយដែរចំពោះការប្រាស្រ័យទាក់ទងដោយកាយវិការ។

☞ សួរសំណួរដូចខាងក្រោម ៖

- ◈ តើសារមិនមែនពាក្យសម្តីផ្តល់សញ្ញាអ្វីខ្លះ?

☞ ទទួលយកចម្លើយ។

☞ ប្រាប់សិស្សពីសញ្ញាអ្វីខ្លះដែលសារមិនមែនពាក្យសម្តីធ្វើឱ្យមនុស្សប្រាស្រ័យទាក់ទងគ្នាបាន (សូមមើលឯកសារអំណានទី៥នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។

☞ សួរសិស្សថា តើការប្រាស្រ័យទាក់ទងជាភាសាកាយវិការអាចផ្ទុយទៅនឹងការប្រាស្រ័យទាក់ទងដោយពាក្យសម្តីដែរឬទេ។

☞ ទទួលយកចម្លើយ បន្ទាប់មកប្រាប់ពួកគេថា វាអាចបាន។ ឧទាហរណ៍ មនុស្សម្នាក់អាចមើលទៅដូចជាកើតទុក្ខ ប៉ុន្តែបែរជានិយាយថា គេ «មិនអីទេ»។

☞ ប្រសិនបើមានពេល សរុបមេរៀននេះដោយភ្ជាប់ការរៀនសូត្រពីមេរៀនមុន។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី៨ ៖ ឯកសារអំណានសម្រាប់គ្រូបង្រៀន

**បរិបទចំណេះដឹង ៖ ការប្រាស្រ័យទាក់ទងដោយកាយវិការ**

**ការប្រាស្រ័យទាក់ទងដោយកាយវិការរួមមានចំណុចដូចខាងក្រោម ៖**

- ការបង្ហាញទឹកមុខ។
- ការលើកដាក់សំឡេង និងសូរសំឡេង។
- ឥរិយាបថដែលបង្ហាញតាមរយៈភាសាកាយវិការ។
- គម្លាត និងចន្លោះរវាងអ្នកប្រាស្រ័យទាក់ទង។

ការប្រើប្រាស់សញ្ញាដោយកាយវិការនៅពេលប្រាស្រ័យទាក់ទងផ្តល់ព័ត៌មានបន្ថែម និងបន្ថែមអត្ថន័យទៅលើការប្រាស្រ័យទាក់ទងដោយពាក្យសម្តីដែលគេកំពុងតែនិយាយ ឬពិភាក្សាគ្នា។

**សារជាកាយវិការអនុញ្ញាតឱ្យគេ ៖**

- សង្កត់ន័យពីពាក្យសម្តីដែលគេបាននិយាយ (ឧទាហរណ៍ មនុស្សអាចងក់ក្បាលច្រើនដងដើម្បីបញ្ជាក់ថា «យល់ព្រម» ចំពោះការឯកភាពជាមួយនឹងអ្នកដែលកំពុងប្រាស្រ័យទាក់ទងដោយពាក្យសម្តី)។
- ផ្តល់ព័ត៌មានត្រលប់ទៅកាន់មនុស្សផ្សេងទៀត។
- វាធ្វើឱ្យមានភាពងាយស្រួលចំពោះលំហូរនៃការប្រាស្រ័យទាក់ទង (ឧទាហរណ៍ តាមរយៈការប្រើប្រាស់កាយវិការដើម្បីឱ្យមនុស្សផ្សេងទៀតដឹងថាពួកគេបាននិយាយចប់ហើយ ឬបន្ទាប់មកចង់និយាយអ្វីមួយ)។

**ប្រភេទនៃការប្រាស្រ័យទាក់ទងដោយកាយវិការ**

គេហៅប្រភេទនៃការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកដោយមិនប្រើពាក្យសម្តីនៅក្នុងពេលកំពុងនិយាយថា ជាការប្រាស្រ័យទាក់ទងដោយកាយវិការ។ មានប្រភេទនៃការប្រាស្រ័យទាក់ទងដោយកាយវិការខុសៗគ្នាជាច្រើនដែលមានដូចខាងក្រោម៖

- **ចលនារាងកាយ ៖** ដូចជាកាយវិការដៃ ការងក់ក្បាល ឬការគ្រវីក្បាល។ល។
- **អាកប្បកិរិយា ៖** របៀបដែលអ្នកឈរ ឬអង្គុយ (ឧទាហរណ៍ ឱបដៃ ការឱន។ល។)។

- **ការប្រើក្រសែភ្នែក** ៖ ឧទាហរណ៍ ចំនួននៃការប្រើក្រសែភ្នែកជាទូទៅកំណត់ពីកម្រិតនៃការជឿទុកចិត្ត។ល។
- **ភាសាបង្កប់** (para-language) ៖ ផ្នែកផ្សេងទៀតនៃសំឡេងក្រៅពីពាក្យសម្ដី (ឧទាហរណ៍ សំឡេងឡើងខ្ពស់ ការលើកដាក់សំឡេង ល្បឿននៃការនិយាយ)។
- **ការខិតចូលជិតគ្នា** ៖ កំណត់កម្រិតនៃភាពស្និទ្ធស្នាល ឬគំរាមកំហែងដោយអាស្រ័យលើលក្ខណៈនៃការប្រាស្រ័យទាក់ទងដែលមាន។
- **ការបង្ហាញទឹកមុខ** ៖ ចំណុចនេះរួមមាន ៖ ការញញឹម ការជ្រួញចិញ្ចើម ការញាក់សាច់ដុំមុខ ការព្រិចភ្នែក។ល។ និងការផ្លាស់ប្តូរសរីរសាស្ត្រផងដែរ ដូចជាការបែកញើស ឬការព្រិចភ្នែកច្រើននៅពេលភ័យខ្លាំង។

**សារៈសំខាន់នៃការប្រាស្រ័យទាក់ទងដោយកាយវិការ**

នៅពេលយើងប្រាស្រ័យទាក់ទង សញ្ញាជាកាយវិការអាចមានសារៈសំខាន់ដូច ឬពេលខ្លះ មានសារៈសំខាន់ជាងអ្វីដែលយើងនិយាយទៅទៀត។ ការប្រាស្រ័យទាក់ទងដោយកាយវិការអាចមានផលជះដ៏សំខាន់មួយទៅលើអ្នកស្តាប់ និងលទ្ធផលនៃការប្រាស្រ័យទាក់ទង។

មនុស្សអាចមានការគ្រប់គ្រងដោយការដឹងខ្លួនតិចតួចបំផុតជុំវិញសារដែលបង្ហាញដោយកាយវិការរបស់ខ្លួនបើប្រៀបធៀបទៅនឹងអ្វីដែលពួកគេកំពុងនិយាយជាក់ស្តែង។ ចំណុចនេះគឺជាផ្នែកមួយដោយសារការប្រាស្រ័យទាក់ទងដោយកាយវិការបង្កប់នូវអារម្មណ៍ដែលមានលក្ខណៈធម្មជាតិច្រើនជាង ហើយហេតុដូច្នេះហើយទើបវាមានលក្ខណៈជាសភាវគតិច្រើនមែនទែន។ ប្រសិនបើមានភាពមិនស្របគ្នារវាងការប្រាស្រ័យទាក់ទងដោយពាក្យសម្ដី និងកាយវិការ គេទំនងជា ទុកចិត្តទៅលើសារដែលបង្ហាញតាមរយៈកាយវិការច្រើនជាងពាក្យសម្ដីដែលគេប្រើ។

ការពុំមានសារដោយកាយវិការក៏អាចជាសញ្ញាមួយនៃប្រភេទផ្សេងៗដែលបង្ហាញថា អ្នកនិយាយកំពុងគ្រប់គ្រងភាសាកាយវិការរបស់ខ្លួនដោយប្រុងប្រយ័ត្ន ហើយប្រហែលជាកំពុងព្យាយាមលាក់បាំងអារម្មណ៍ពិតប្រាកដរបស់ខ្លួន។

## ឯកសារអំណានទី៦ ៖ បណ្ណពាក្យទាក់ទងនឹងអារម្មណ៍ និងសកម្មភាព

| | | | |
|---|---|---|---|
| ខឹង | សប្បាយ | អស់កម្លាំង | មកទីនេះ |
| អន្ទះសា | មិនអីទេ | ឈប់ | រក្សាភាពស្ងៀមស្ងាត់ |
| ភ័យខ្លាច | ខកចិត្ត | មើលនោះ | រំភើប |
| កើតទុក្ខ | ឈប់និយាយ | អៀនខ្មាស | ជឿជាក់ |

៥០៨ ស.ម

៥០៨ ស.ម

**គន្លឹះសម្រាប់គ្រូបង្រៀន ៖** ចែកបណ្ណចំនួន១៦សន្លឹកទៅឱ្យសិស្សចំនួន៨ក្រុម។ ចែកបណ្ណដូចៗគ្នាប្រសិនបើត្រូវការ។

**សេចក្តីណែនាំ ៖**

– ប្រើក្រដាសនិងគូរការេចំនួន ១៦ ដែលមានទំហំ៥០៨ ស.ម x ៥០៨ ស.ម។

– សរសេរពាក្យនៅក្នុងការេនីមួយៗដូចបង្ហាញខាងលើ។

– ធានាថា អក្សរសរសេរច្បាស់ល្អ។

– កាត់ការេនីមួយៗចេញ។

– ទុកបណ្ណប្រើនៅពេលអនុវត្តសកម្មភាព។

## ឯកសារអំណានទី៧ ៖ ដ្យាក្រាមរាងមូល ៖ សមាសធាតុទាំង៣នៃការប្រាស្រ័យទាក់ទង




**សេចក្តីណែនាំ ៖**

- ប្រើក្រដាសដើម្បីគូរដ្យាក្រាមរាងមូលពី «សមាសធាតុទាំង៣នៃការប្រាស្រ័យទាក់ទង»។
- គូររង្វង់ដែលមានអង្កត់ផ្ចិត ៣០,៤៨ ស.ម ។
- គូររង្វង់តូចដែលមានអង្កត់ផ្ចិតប្រវែង ២០,៣២ ស.មនៅកណ្តាលរង្វង់ទី១។
- គូរបន្ទាត់ភ្ជាប់រង្វង់ទាំងពីរដើម្បីបង្កើតជាផ្នែកផ្សេងៗសម្រាប់បង្ហាញភាគរយនៃវិធីសាស្ត្រប្រាស្រ័យទាក់ទងខុសៗគ្នាដែលមនុស្សប្រើប្រាស់។ សូមមើលរូបខាងលើដើម្បីធ្វើឱ្យបានត្រឹមត្រូវ។
- ផាត់ពណ៌ចំនួន៣ពណ៌ខុសៗគ្នា បន្ទាប់មកបំពេញផ្នែកនីមួយៗដូចបង្ហាញនៅក្នុងរូបខាងលើ។
- បង្កើតការណែនាំសំខាន់មួយដូចបង្ហាញខាងលើ។
- គូររូបចតុកោណកែងផ្តេកចំនួន៣ (ទំហំ ១០,១៦ ស.ម x ៧,៦២ ស.ម) នៅចំហៀងម្ខាងនៃរូប។
- លាបពណ៌ចតុកោណកែងឱ្យដូចគ្នានៅក្នុងដ្យាក្រាមរាងមូល។ សូមមើលរូបខាងលើ។
- សរសេរពាក្យដែលគេផ្តល់ឱ្យលើចតុកោណកែងនីមួយៗដូចមានបង្ហាញ។
- បិទដ្យាក្រាមរបស់លោកគ្រូ អ្នកគ្រូនៅក្នុងថ្នាក់រៀន។

# មេរៀនទី៣ ៖ យេនឌ័រ និងការប្រាស្រ័យទាក់ទង[1]

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីយល់ពីរបៀបដែលការកំណត់ពីយេនឌ័រ និងអំណាចមានឥទ្ធិពលលើបំណិន នៃការប្រាស្រ័យទាក់ទង។

🕒 **រយៈពេលមេរៀន ៖** ៤៥នាទី

✉ **សារសំខាន់ៗ ៖**

១. ផ្នត់គំនិតយេនឌ័រ និងឥទ្ធិពលនៃអំណាចដែលមានស្រាប់ ជារឿយៗមានឥទ្ធិពលលើលក្ខណៈ ដែលស្ត្រី ឬក្មេងស្រីជ្រើសរើស ឬត្រូវគេអនុញ្ញាតឱ្យបង្ហាញពីអារម្មណ៍ខ្លួនឯង។ ដើម្បីជម្នះ ឧបសគ្គទាំងនេះយើងត្រូវមានលទ្ធភាពវិនិច្ឆ័យលើឥទ្ធិពលនៃអំណាចដែលមានស្រាប់ និង ត្រូវមានភាពច្បាស់លាស់ពីសារដែលយើងមានបំណងប្រាស្រ័យទាក់ទងមុនពេលបង្ហាញពី អារម្មណ៍ខ្លួនឯង។

២. ស្ត្រី ឬក្មេងស្រីគួរយល់ថា ឧបសគ្គទាំងនេះត្រូវបានសង្គមលើកឡើងដោយសារតែវិសមភាព យេនឌ័រ ហើយឧបសគ្គទាំងនោះមិនមានអ្វីទាក់ទងនឹងបញ្ហា ឬសមត្ថភាពរបស់ស្ត្រីឡើយ។

៣. វាមានភាពចាំបាច់ដែលត្រូវសិក្សាពីបំណិនប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដើម្បី ផ្លាស់ប្តូរផ្នត់គំនិតផ្ទាល់របស់មនុស្សម្នាក់ចំពោះសមត្ថភាពរបស់ខ្លួន និងដើម្បីមានលទ្ធភាព ចរចាជាមួយអ្នកដទៃទៀត។

៤. ដើម្បីឱ្យការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាព មនុស្សម្នាក់ត្រូវចងចាំក្នុងចិត្តនូវរឿងចំនួន៣ គឺពេលវេលា ទីកន្លែង និងស្ថានភាពដែលមាន ឬបរិបទ បន្ទាប់មកត្រូវធ្វើការប្រាស្រ័យ ទាក់ទងទៅតាមនោះ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូបង្រៀន ៖ ម៉ាស៊ីនថតចម្លង សន្លឹកក្រដាស A4 មួយសន្លឹក ក្តារខៀន និងហ្វឺត ឬដីស។

☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការក្នុងថ្នាក់ទំព័រទី៧៨ និងកិច្ចការផ្ទះទំព័រទី៧៨-៨០ សម្ភារៈសរសេរ។

---

[1] ដកស្រង់ពីកម្មវិធីសិក្សា PACE- «ការដាក់ទុនលើជំនាញថ្មីដើម្បីអនាគត»នៃ GAP Inc.s

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
☞ អានឯកសារអំណានទី៨ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។
☞ ថតចម្លងផ្នែក «ការកំណត់របៀបប្រាស្រ័យទាក់ទង ៖ ស្ត្រី និងបុរស» បន្ទាប់មកប្រើវាជាឯកសារយោងដើម្បីគូរតារាងនៅលើក្តារខៀនក្នុងថ្នាក់ (សូមមើលឯកសារអំណានទី៩ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
☞ ប្រមូលសម្ភារៈដែលត្រូវការទាំងអស់ផ្សេងទៀត។
☞ សរសេរចំណងជើងមេរៀនដាក់នៅលើក្តារខៀន។

> **គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - រំឭកសិស្ស ឱ្យចុះវត្តមាននៅពេលពួកគេចូលមកក្នុងថ្នាក់រៀន។
> - ឱ្យពួកគេប្រមូលសន្លឹកកិច្ចការរបស់ខ្លួន និងសម្ភារៈសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

**សេចក្តីណែនាំ**

☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
☞ ចាប់ផ្តើមដោយហៅសិស្សស្ម័គ្រចិត្តចំនួន២នាក់។ ឱ្យពួកគេទៅម្ខាង បន្ទាប់មកចែកសេចក្តីណែនាំដូចខាងក្រោមឱ្យពួកគេ ៖

- រៀបចំការសម្តែងតួសម្រាប់រយៈពេល២នាទីដែលប្អូននឹងបង្ហាញដល់សិស្សផ្សេងទៀតនៅក្នុងថ្នាក់។
- ការសម្តែងតួចាំបាច់ត្រូវតែជាការសន្ទនាមួយរវាងបុរសម្នាក់ និងស្ត្រីម្នាក់។
- ប្អូនមានជម្រើសក្នុងការជ្រើសរើសប្រធានបទណាមួយដែលប្អូនចូលចិត្តពីបទពិសោធន៍នៃជីវិតប្រចាំថ្ងៃរបស់ប្អូន។
- ប្អូនមានពេល៥នាទីដើម្បីរៀបចំ។
- ចេញពីក្នុងថ្នាក់ ដើម្បីកុំឱ្យអ្នកផ្សេងទៀតមើលប្អូនអនុវត្ត។

☞ នៅពេលសិស្សស្ម័គ្រចិត្តរៀបចំការសម្តែង សូមឱ្យសិស្ស ២-៣នាក់សង្ខេបអ្វីដែលពួកគេបានសិក្សាពីមេរៀនមុន។

☞ អាន និងចង្អុលចំណងជើងមេរៀនដែលសរសេរនៅលើក្ដារខៀន។ ឱ្យសិស្សទាយពីមេរៀនដែលត្រូវរៀននៅថ្ងៃនេះ។ ឱ្យសិស្ស ស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុមធំ។

☞ ហៅសិស្សស្ម័គ្រចិត្ត២នាក់ឱ្យចូលមកវិញ។ មុនពេលការសម្ដែងចាប់ផ្ដើម ចូរប្រាប់សិស្សក្នុងថ្នាក់ថា ពួកគេត្រូវធ្វើជាអ្នកសង្កេតការណ៍ និងកំណត់ពីអត្តសញ្ញាណអ្នកសម្ដែងម្នាក់ៗថាតើនរណាដើរតួជាបុរស និងនរណាដើរតួជាស្ត្រីក្នុងការសម្ដែងនោះ។ ឱ្យសិស្សស្ម័គ្រចិត្តធ្វើការសម្ដែងតួ។

☞ ប្រមូលគ្នាចូលក្រុមធំវិញដើម្បីពិភាក្សាដោយសង្ខេប។ សួរសំណួរដូចខាងក្រោម ៖

- តើប្អូនអាចកំណត់បានទេថាតើក្នុងចំណោមសិស្សស្ម័គ្រចិត្តទាំង២នាក់ដែលកំពុងសម្ដែងតួនោះ មួយណាសំដែងតួជាស្ត្រី និងមួយណាសម្ដែងតួជាបុរស?
- តើប្អូនមានកត់សម្គាល់ឃើញភាពខុសគ្នាណាមួយដែរឬទេចំពោះរបៀបប្រាស្រ័យទាក់ទងរបស់បុរស និងរបៀបប្រាស្រ័យទាក់ទងរបស់ស្ត្រីនៅពេលសម្ដែង? ប្រសិនបើមាន តើមានអ្វីខ្លះ?

☞ ទទួលយកចម្លើយ។

> **🗝 គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូ ៖
>
> - ការសម្ដែងតួកំណត់ពីបរិបទសម្រាប់សិស្ស ដើម្បីភ្ជាប់ទៅនឹងពិភពលោកពិតរបស់ពួកគេ និងរបៀបប្រាស្រ័យទាក់ទងខុសៗគ្នាជាច្រើននៅក្នុងស្ថានភាពផ្សេងៗគ្នា។ សន្លឹកកិច្ចការជួយសិស្សឱ្យយល់កាន់តែទូលំទូលាយពីរបៀបដែលការកំណត់ពីយេនឌ័រ និងអំណាចរឹតត្បិតរបៀបដែលស្ត្រីប្រាស្រ័យទាក់ទង។

## កិច្ចការក្នុងថ្នាក់

**កិច្ចការក្នុងថ្នាក់ ៖**

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៧៨។

☞ អានសេចក្ដីណែនាំ។ ឱ្យសិស្សឆ្លុះបញ្ចាំងពីអ្វីដែលពួកគេសម្គាល់ឃើញទាក់ទងនឹងរបៀបប្រាស្រ័យទាក់ទងនីមួយៗសម្រាប់ស្ត្រី និងបុរសក្នុងស្ថានភាពខុសៗគ្នាក្នុងជីវិតប្រចាំរបស់ពួកគេដែលគេផ្ដល់ឱ្យនៅក្នុងកូឡោនទី១ បន្ទាប់មកបំពេញក្នុងកូឡោនទី២ និងទី៣ទៅតាមការយល់ឃើញរបស់ពួកគេ។ ផ្ដល់រយៈពេល ៧-១០នាទីដល់ពួកគេសម្រាប់សកម្មភាពនេះ។

## ៣. ការពង្រឹងចំណេះដឹង

### 🗣 ចំណុចសម្រាប់ការពិភាក្សា

☞ ប្រមូលផ្តុំគ្នានៅក្នុងក្រុមធំដើម្បីចែករំលែក និងពិភាក្សាពីចម្លើយនៅក្នុងសន្លឹកកិច្ចការរបស់ពួកគេម្នាក់ៗ។

☞ សួរសំណួរដូចខាងក្រោម ៖

- តាមរយៈការសង្កេតរបស់ប្អូនពីជីវិតប្រចាំថ្ងៃ តើចំណុចខុសគ្នាអ្វីខ្លះដែលប្អូនកត់សម្គាល់ឃើញចំពោះរបៀបដែលស្ត្រី និងបុរសប្រាស្រ័យទាក់ទងក្នុងផ្នែកដូចខាងក្រោម?
  - ការលើកដាក់សំឡេងនៅពេលប្រាស្រ័យទាក់ទង។
  - ភាសាកាយវិការនៅពេលប្រាស្រ័យទាក់ទង។
  - ការសួរសំណួរនៅពេលសន្ទនា *(ប្រភេទសំណួរ ឬចំនួនសំណួរ)*។
  - ឥរិយាបថនៅពេលប្រាស្រ័យទាក់ទង។
  - ប្រធានបទដែលគេចូលចិត្តនៅពេលប្រាស្រ័យទាក់ទង *(តើបញ្ហាអ្វីខ្លះដែលគេនិយាយ)*។

☞ នៅពេលសិស្សឆ្លើយសំណួរនីមួយៗ សូមកត់ត្រាចម្លើយដាក់ទៅក្នុងកូឡោននៅក្នុងតារាងនៅលើក្តារខៀន។

☞ ឱ្យសិស្សបំពេញចំណុចណាមួយដែលពួកគេអាចខ្វះចន្លោះនៅក្នុងសន្លឹកកិច្ចការរបស់ពួកគេ។

**🔑 គន្លឹះសម្រាប់គ្រូបង្រៀន**

សួរសំណួរដូចខាងក្រោម ៖

- ឱ្យសិស្សមើលសន្លឹកកិច្ចការរបស់ខ្លួន បន្ទាប់មកឆ្លើយសំណួរ។
- តារាងគំរូ (ឯកសារអំណានទី៩) ផ្តល់ឱ្យលោកគ្រូ អ្នកគ្រូនូវសញ្ញាបង្ហាញមួយចំនួនចំពោះប្រភេទចម្លើយរបស់សិស្សដែលរំពឹងទុក។ ប្រសិនបើសិស្សមិនមានចម្លើយនេះទេ ត្រូវសួរពួកគេ។

☞ សួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីប្អូនគិតថា មានភាពខុសគ្នាមួយចំពោះលក្ខណៈនៃការនិយាយរវាងបុរស និងស្ត្រី និងប្រធានបទដែលពួកគេនិយាយ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– យើងមានទំនាក់ទំនងសង្គមទៅតាមតួនាទី និងការរំពឹងទុកផ្នែកយេនឌ័ររបស់យើង ដែលជាញឹកញាប់មានឥទ្ធិពលលើការប្រាស្រ័យទាក់ទងរបស់យើង។ ចំណុចនេះកើតឡើងទាំង

ចំពោះអ្វីដែលយើងមានអារម្មណ៍ជឿជាក់ (អ្វីដែលអាច ឬមិនអាចនិយាយ) និងរបៀបដែលយើងអាចប្រាស្រ័យទាក់ទង (ពោលគឺ ទាំងពាក្យសម្តី និងកាយវិការ)។

- គេបង្រៀនស្ត្រីឱ្យលាក់បាំងនូវការជឿជាក់និងទំនាក់ទំនងសង្គមរបស់ខ្លួននៅពេលនិយាយអ្វីមួយ។ ចំណុចនេះគឺមានជាក់ស្តែងណាស់ជាពិសេសនៅក្នុងបរិបទនៃប្រទេសកម្ពុជា និងនៅក្នុងសង្គមបិតាធិបតេយ្យដែលមានការយល់ឃើញជាទូទៅថាបុរសត្រូវជានិច្ច។
- ដំណើរការនៃទំនាក់ទំនងសង្គមរំពឹងទុកថា បុរសនឹងមានអាកប្បកិរិយាក្នុងលក្ខណៈមួយចំនួនដែលជារឿយៗបង្ហាញពីរបៀបដែលពួកគេប្រាស្រ័យទាក់ទង។ ឧទាហរណ៍ គេបង្រៀនបុរសឱ្យមានភាពបើកចំហ និងប្រាកដប្រជាក្នុងពេលដែលគេរំពឹងទុកជាទូទៅថាស្ត្រីនឹងរក្សាភាពស្ងៀមស្ងាត់ និងស្តាប់បង្គាប់។
- គេចាត់ទុកការខ្វះជំនាញប្រាស្រ័យទាក់ទងនៅក្នុងចំណោមស្ត្រីគឺជារឿងល្អមួយ។ ប្រសិនបើស្ត្រីនិយាយច្រើន ជាទូទៅគេចាត់ទុកពួកគាត់ថាជាស្ត្រី «មិនល្អ»។ ប្រសិនបើពួកគាត់ខ្មាសអៀន និងស្តាប់ឱវាទនោះគេគិតថាគាត់ជាស្ត្រី «ល្អ»។ល។ ស្ថានភាពនេះក៏មានការពង្រីកចាប់ពីគ្រួសាររហូតដល់កន្លែងធ្វើការ សហគមន៍ និងស្ថាប័នដែរ។
- ទំនាក់ទំនងសង្គមក៏មានន័យដែរថា បុរស និងស្ត្រីមានរបៀបនៃការប្រាស្រ័យទាក់ទងមិនមែនជាពាក្យសម្តី និងដោយកាយវិការខុសៗគ្នាដែរ (ឧទាហរណ៍ បុរសតែងតែឈរត្រង់ខ្លួន និងមានភាពជឿជាក់ដោយការឈរពើងទ្រូង និងប្រើក្រសែភ្នែកជាប់ជានិច្ច។ ចំណែកស្ត្រីត្រូវឱនបន្តិច ហើយជារឿយៗត្រូវឱនក្បាលចុះនៅពេលសន្ទនាជាមួយនរណាម្នាក់ដែលមានអំណាចច្រើនជាង)។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើប្អូនគិតដូចម្តេចចំពោះសមត្ថភាពរបស់ស្ត្រីក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចខាងក្រោម ៖

- ទំនាក់ទំនងសង្គមរបស់យើងទាក់ទងនឹងតួនាទីយេនឌ័រ ជារឿយៗ បញ្ជាក់ពីសេរីភាព ចំពោះលទ្ធភាពក្នុងការបង្ហាញពីការគិត និងអារម្មណ៍របស់យើង។ ជានិច្ចកាល ស្ត្រីមិនទទួលបានសេរីភាពក្នុងការប្រាស្រ័យទាក់ទង ឬបង្ហាញពីតម្រូវការផ្សេងៗរបស់ខ្លួនចំពោះការសម្រេចចិត្តសំខាន់ៗនៅក្នុងជីវិតរបស់ពួកគាត់ទេ។ ទោះជាយ៉ាងណាក៏ដោយ វិសមភាពទាំងនេះអាចផ្លាស់ប្តូរបានដើម្បីឱ្យស្ត្រីទទួលបានឱកាសច្រើនថែមទៀត។
- ជំនាញប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពអាចជួយស្ត្រីឱ្យបង្ហាញពីគំនិត តម្រូវការ និងទស្សនៈរបស់ពួកគេដោយសេរី។ ដូច្នេះ ការពង្រឹងនូវការឱ្យតម្លៃ និងការជឿជាក់លើខ្លួន

ឯងរបស់គាត់ធ្វើឱ្យគាត់មានលទ្ធភាពបង្ហាញពីតម្រូវការរបស់ខ្លួននៅក្នុងគ្រួសារ និងសហគមន៍បាន។

☞ សួរសំណួរដូចខាងក្រោម ៖

- នៅក្នុងស្ថានភាពមួយដែលមានផ្ទត់គំនិតផ្នែកយេនឌ័រ ឬឥទ្ធិពលនៃអំណាចដែលមានស្រាប់ តើគេធានាបាននូវការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពបានយ៉ាងដូចម្តេច?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

- វាមានសារៈសំខាន់បំផុតក្នុងការយល់ថា ក្នុងនាមជាក្មេងស្រី ប្អូនពិតជាមានសិទ្ធិ និងអំណាច ក្នុងការបង្ហាញពីរបៀបដែលប្អូនគិត និងមានអារម្មណ៍ ទោះបីជាគេបង្រៀនប្អូនឱ្យគិត ឬជឿតាមរបៀបផ្សេងក៏ដោយ។ ប្អូនអាចកសាងជំនាញ និងការលើកទឹកចិត្តរបស់ប្អូនដើម្បីមានលទ្ធភាពបង្ហាញពីគំនិតរបស់ប្អូនឱ្យបានច្បាស់លាស់ និងជាក់លាក់ព្រមទាំងបង្កើនភាពជឿជាក់របស់ប្អូនដើម្បីអាចធ្វើបែបនោះបាន។
- ចំពោះស្ថានភាពឥទ្ធិពលនៃអំណាចដែលមានស្រាប់ដូចនេះ វាមានសារៈសំខាន់ក្នុងការវិនិច្ឆ័យពីស្ថានភាពមុនពេលនិយាយដើម្បីឱ្យមានភាពច្បាស់លាស់ និងប្រសិទ្ធភាពចំពោះសារមួយដែលគេកំពុងព្យាយាមបង្ហាញ។ ចូរចងចាំចំពោះចំណុចខាងក្រោម ៖
  - យល់ពីតួនាទីនៃអំណាចរបស់ប្អូន និងការលម្អៀងផ្នែកយេនឌ័រដែលមានផលប៉ះពាល់ទៅលើស្ថានភាពជាក់លាក់របស់ប្អូន។ ការណ៍នេះជួយប្អូនឱ្យមានយុទ្ធសាស្ត្រចំពោះអ្វីដែលប្អូនចង់និយាយ របៀបដែលប្អូនត្រូវចរចា និងអនុវត្តវាបន្តិចម្តងៗជាបន្តបន្ទាប់។
  - ត្រូវចងចាំពីទីកន្លែង ពេលវេលា និងស្ថានភាពដែលមាននៅក្នុងដៃ។
  - កំណត់គោលបំណងសម្រាប់ការប្រាស្រ័យទាក់ទងជានិច្ច។
  - និយាយឱ្យបានច្បាស់លាស់ និងជឿជាក់ ព្រមទាំងតាំងចិត្តឱ្យស្ងប់ និងមានភាពអត់ធ្មត់ពេលកំពុងប្រាស្រ័យទាក់ទង។
  - យល់ពាក្យថា «ទេ» គឺជាប្រយោគពេញលេញមួយ។ ប្អូនមានអំណាច និងសិទ្ធិក្នុងការនិយាយថា «ទេ» ក្នុងស្ថានភាពមួយដែលប្អូនមិនមានអារម្មណ៍ស្រួលក្នុងចិត្ត។

☞ ប្រាប់សិស្សរួមថា ទោះបីជាត្រូវចំណាយពេលច្រើនដើម្បីលុបបំបាត់ផ្ទត់គំនិតទាំងនោះក្តី ក៏ស្ត្រី ឬក្មេងស្រីត្រូវពង្រឹងភាពក្លាហានដើម្បីបង្ហាញពីគំនិតរបស់ខ្លួន និងប្រាស្រ័យទាក់ទងប្រកបដោយភាពជឿជាក់ដើម្បីសម្រេចបានគោលដៅរបស់ខ្លួន។

កិច្ចការផ្ទះ

**កិច្ចការផ្ទះ**

- មុនពេលសិស្សបំបែកគ្នា ចំណាយពេល៥នាទីពន្យល់កិច្ចការផ្ទះដល់ពួកគេ។
- ឱ្យពួកគេបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៧៩ និងទី៨០។
- ឱ្យសិស្សអានសេចក្តីណែនាំពី «ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព» បន្ទាប់មកបំពេញសន្លឹកកិច្ចការស្តីពី «ឧបសគ្គក្នុងការនិយាយ»។ អានសេចក្តីណែនាំ បន្ទាប់មកពន្យល់ពីលំហាត់នៅក្នុងសន្លឹកកិច្ចការ។
- រំឭកសិស្សពីសារៈសំខាន់នៃការយកសន្លឹកកិច្ចការរបស់ខ្លួនមកវិញនៅម៉ោងក្រោយ។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី៨ ៖ ឯកសារ អំណានសម្រាប់គ្រូបង្រៀន

### បរិបទចំណេះដឹង ៖ ការប្រាស្រ័យទាក់ទង

- ការប្រាស្រ័យទាក់ទង គឺជាផ្នែករួមមួយនៃជីវិតរបស់យើង។ ការបង្កើតក្រុមសង្គមដូចជា គ្រួសារ កន្លែងការងារ អ្នកជិតខាង និងរដ្ឋអាស្រ័យលើសមត្ថភាពរបស់មនុស្សក្នុងការប្រាស័យទាក់ទងពីទស្សនៈ គំនិត និងអារម្មណ៍។ ជំនាញប្រាស្រ័យទាក់ទង គឺជាចំណុចស្នូលសម្រាប់ការអភិវឌ្ឍន៍ ការបង្ហាញ បុគ្គលិកលក្ខណៈ និងសក្ដានុពលភាពរបស់មនុស្ស។ ការប្រាស្រ័យទាក់ទងល្អនាំទៅរកការយល់ដឹងពីគ្នាបានល្អរវាងសមាជិកនៅក្នុងក្រុមសង្គមណាមួយ។ បន្ទាប់មក ការយល់ដឹងពីគ្នាបានល្អធានាបាននូវការបំពេញតួនាទីបានត្រឹមត្រូវរបស់ក្រុមនោះ។
- ឱកាស និងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពអាស្រ័យលើកត្តាមួយចំនួន ៖ បរិបទរបស់បុគ្គលម្នាក់ៗ ឋានៈរបស់គេនៅក្នុងសង្គម ឥទ្ធិពលដែលមនុស្សម្នាក់ប្រើ និងកត្តាមួយចំនួនទៀតដូចជាការអប់រំ និងឋានានុក្រមនៅក្នុងគ្រួសារ កន្លែងធ្វើការ សហគមន៍ និងទីកន្លែងដែលបង្កើតបរិយាកាសសង្គមរបស់មនុស្ស។ ដូច្នេះ នៅពេលមនុស្សរៀបចំកសាងជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព បច្ចេកទេសល្អតែមួយមុខនឹងមិនគ្រប់គ្រាន់ឡើយ។ វាមានសារៈសំខាន់ក្នុងការយល់ពីបរិយាកាសដែលមនុស្សម្នាក់ត្រូវការដើម្បីប្រាស្រ័យទាក់ទង និងអភិវឌ្ឍជំនាញដែលសមស្របជាមួយបរិយាកាសនោះ។
- សរុបមក ការប្រាស្រ័យទាក់ទងគឺជាដំណើរការនៃការបញ្ជូន និងការទទួលព័ត៌មាន ឬគំនិតតាមរយៈពាក្យសម្ដី កម្មភាព ឬសញ្ញា។

**គំរូនៃការប្រាស្រ័យទាក់ទង**

១. **គំរូឯកទិស** ៖ ការប្រាស្រ័យទាក់ទងឯកទិស(តែម្ខាង)។ នៅពេលដែលបុគ្គល «ក» ប្រាស្រ័យទាក់ទងអ្វីមួយទៅកាន់បុគ្គល «ខ»។

ក - - - - - - - - - - - - - - - - - - - - - - - - ► ខ

២. **គំរូទ្វេទិស** ៖ ការផ្ដល់ព័ត៌មានត្រលប់ *(មានពន្យល់ក្នុងសកម្មភាពទី១)*។ នៅពេលបុគ្គល «ក» ប្រាស្រ័យទាក់ទងអ្វីមួយទៅកាន់បុគ្គល «ខ» ហើយបុគ្គល «ខ» បានប្រាស្រ័យទាក់ទង ឬផ្ដល់ព័ត៌មានត្រលប់មកឱ្យបុគ្គល «ក» វិញ ។

**៣. គំរូពហុទិស ៖** នៅក្នុងគំរូនេះ មនុស្សម្នាក់ៗកំពុងប្រាស្រ័យទាក់ទងជាមួយមនុស្សផ្សេងទៀតក្នុងពេលតែមួយ។ គំរូនេះឆ្លុះបញ្ចាំងកាន់តែត្រឹមត្រូវថែមទៀតពីការប្រាស្រ័យទាក់ទងនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ហើយតាមធម្មតា វាជាការរួមបញ្ចូលគ្នានូវគំរូផ្សេងៗជាច្រើន។




## ឯកសារអំណានសម្រាប់គ្រូបង្រៀន

**បរិបទចំណេះដឹង ៖ ការប្រាស្រ័យទាក់ទង (ត)**

- មនុស្សប្រាស្រ័យទាក់ទងដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍។ ការប្រាស្រ័យទាក់ទងគឺជាបំណិនមួយ ហើយវាបង្កើតឱ្យមានមូលដ្ឋាននៃទំនាក់ទំនងទាំងអស់។ គុណភាពនៃការប្រាស្រ័យទាក់ទងជាទូទៅកំណត់ពីគុណភាពរបស់ទំនាក់ទំនង។

- ការប្រាស្រ័យទាក់ទងមិនមែនពាក្យសម្ដី ឬភាសាកាយវិការផ្ដល់អត្ថន័យចំពោះអ្វីដែលគេនិយាយ ហើយវារាប់បញ្ចូលនូវ ៖ ការលើកដាក់សំឡេង ការបង្ហាញទឹកមុខ *(ការញញឹម ការជ្រួញចិញ្ចើម ។ល។)* ការប្រាស្រ័យទាក់ទងដោយប្រើក្រសែភ្នែក ចលនារាងកាយ *(ការអង្គុយ ការឈរ ការបោះជំហាន ការឱនទៅមុខ ឬផ្អែកមកក្រោយ)* ការស្ទាបស្ទង់ និងសកម្មភាពផ្សេងៗ។ ភាសាកាយវិការអាចមានឥទ្ធិពលលើការប្រាស្រ័យទាក់ទងជាវិជ្ជមាន ឬអវិជ្ជមាន។

- ការប្រាស្រ័យទាក់ទងដោយពាក្យសម្ដីកើតឡើងនៅពេលមនុស្សម្នាក់និយាយ ចំណែកអ្នកផ្សេងទៀតស្ដាប់ និងមានប្រតិកម្ម។ ចំពោះទំនាក់ទំនងនានា ជាទូទៅ ការប្រាស្រ័យទាក់ទងគឺមានលក្ខណៈមិនផ្លូវការ។ ការយល់ខុស និងបញ្ហានៃការប្រាស្រ័យទាក់ទងអាចកើតមានឡើងនៅពេលដែលមនុស្សម្នាក់និយាយវែងពេក និយាយស្រទន់ពេក រំខានអ្នកនិយាយ មិនស្ដាប់ដោយប្រុងប្រយ័ត្ន ឬនៅពេលមានសំឡេងឡូឡានៅខាងក្រោយ ឬការបង្វែរការចាប់អារម្មណ៍ផ្សេងទៀត។

- ការស្តាប់ដោយប្រុងប្រយ័ត្នមានសារៈសំខាន់ចំពោះការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ មានពេលវេលាជាច្រើនដែលអ្នកស្តាប់រវល់គិតពីអ្វីផ្សេងទៀតដែលពួកគេនឹងនិយាយ និងមិនបានយកចិត្តទុកដាក់ច្រើនចំពោះអ្វីដែលអ្នកនិយាយកំពុងនិយាយទេ។ ការណ៍នេះអាចនាំឱ្យមានការយល់ខុស និងមានការភាន់ច្រឡំ។ វាមានសារៈសំខាន់ក្នុងការស្តាប់ដោយប្រុងប្រយ័ត្នចំពោះគ្រប់ចំណុចទាំងអស់ដែលគេនិយាយដោយមិនបង្កការរំខាន ហើយបន្ទាប់មកចាំមានប្រតិកម្មនៅពេលក្រោយ។
- កត្តាសំខាន់ផ្សេងៗទៀតដែលមានផលប៉ះពាល់លើការប្រាស្រ័យទាក់ទងរួមមាន ៖ ពេលវេលា ស្ថានភាព បរិបទ ឬកាលៈទេសៈ កត្តាផ្ទាល់ខ្លួន ដូចជាការធុញថប់អារម្មណ៍ និងការអន្ទះសា ព្រមទាំងកត្តាខាងក្រៅដូចជាសំឡេងឡូឡា ទីកន្លែង វត្តមានរបស់មនុស្សផ្សេងទៀត ការឆ្លើយតបរបស់អ្នកទទួលសារ ។ល។
- របៀប និងសមត្ថភាពប្រាស្រ័យទាក់ទងរបស់យើងក៏មានលក្ខណៈទៅតាមដំណើរការនៃការទំនាក់ទំនងក្នុងសង្គម បទដ្ឋានយេនឌ័រ និងផ្នត់គំនិតរបស់យើងដែរ។ ទោះជាយ៉ាងនេះក្តី ជំនាញប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពអាចជួយយើងឱ្យបង្ហាញពីគំនិត តម្រូវការ និងយោបល់របស់យើងដោយសេរីបានដែរ។ ចំណុចនេះលើកកម្ពស់ការផ្តល់តម្លៃ និងការជឿជាក់លើខ្លួនឯង ដើម្បីមានលទ្ធភាពបង្ហាញឱ្យច្បាស់ពីតម្រូវការរបស់យើងនៅក្នុងគ្រួសារ និងសហគមន៍របស់យើងបាន។

សន្ទានុក្រមពាក្យបច្ចេកទេស

**ការប្រាស្រ័យទាក់ទង** ៖ ដំណើរការនៃការបញ្ជូន និងទទួលព័ត៌មាន ឬគំនិតតាមរយៈពាក្យសម្តី សកម្មភាព ឬសញ្ញា។

**ការប្រាស្រ័យទាក់ទងមិនមែនពាក្យសម្តី** ៖ ការបង្ហាញទឹកមុខ ការប្រាស្រ័យទាក់ទងដោយប្រើ ក្រសែភ្នែក ចលនារាងកាយ ការស្ទាបឬប៉ះ និងសកម្មភាពផ្សេងៗដែលផ្តល់អត្ថន័យចំពោះអ្វីដែលគេនិយាយ។

**ភាសាកាយវិការ** ៖ សំដៅដល់ការប្រាស្រ័យទាក់ទងមិនមែនពាក្យសម្តី។

**ការប្រាស្រ័យទាក់ទងដោយពាក្យសម្តី** ៖ នៅពេលមនុស្សម្នាក់និយាយ ហើយមនុស្សផ្សេងទៀតស្តាប់ និងមានប្រតិកម្ម។

**ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព** ៖ ការប្រាស្រ័យទាក់ទងដែលបញ្ចៀសការយល់ខុស និងកែលម្អការទំនាក់ទំនង។

## ឯកសារអំណានទី៩ ៖ ការកំណត់របៀបប្រាស្រ័យទាក់ទង ៖ ស្ត្រី និងបុរស

| ផ្នែកសម្រាប់ការសង្កេត | ស្ត្រី | បុរស |
|---|---|---|
| ភាពខុសគ្នាចំពោះការលើកដាក់សំឡេងក្នុងការប្រាស្រ័យទាក់ទង | ស្រទន់ គួរសម មិនច្បាស់ | ជឿជាក់ ឮ គំរោះគំរើយ |
| ភាពខុសគ្នាចំពោះភាសាកាយវិការ | ខ្មាសអៀន ភ័យខ្លាច ស្រគត់ស្រគំ | ក្លាហាន បំពាន |
| ការសួរសំណួរ | ផ្តល់តែចម្លើយប៉ុណ្ណោះ មិនសួរសំណួរ | មានសំណួរច្រើន |
| ឥរិយាបថ | ការយកចិត្តទុកដាក់ ស្តាប់បង្គាប់ | គ្របសង្កត់ មិនយកចិត្តទុកដាក់ |
| ការពេញចិត្តទៅលើប្រធានបទផ្សេងៗក្នុងការប្រាស្រ័យទាក់ទង | ពីគ្រួសារ ឪពុកម្តាយ ការអប់រំរបស់កូន សុខភាព ការងារផ្ទះ | ពីខ្លួនឯង ប្រាក់ នយោបាយ មិត្តភក្តិ |

**សេចក្តីណែនាំ ៖**

- ថតចម្លងសន្លឹកកិច្ចការនេះមួយច្បាប់ និងប្រើវាជាឯកសារយោងនៅពេលគូសតារាងនេះនៅលើក្តារខៀន ក៏ដូចជានៅពេលអនុវត្តសកម្មភាព។ លោកគ្រូ អ្នកគ្រូអាចកាន់សៀវភៅមេរៀននេះ និងយោងទៅលើទំព័រនេះក៏បាន។
- គូរតារាងនេះនៅលើក្តារខៀន។ ធានាថាតា ងនេះមានកូឡោនចំនួន៣ និងជួរដេកចំនួន៦។
- សរសេរចំណងជើងនៅក្នុងជួរដេកទី១នៅក្នុងកូឡោននីមួយៗ។
- សរសេរឃ្លានៅក្នុងជួរដេកនីមួយៗ ពោលគឺ សម្រាប់តែក្នុងកូឡោនទី១ប៉ុណ្ណោះ។
- ត្រូវបំពេញជួរដេកនីមួយៗនៅក្នុងកូឡោនទី២ និងទី៣នៅពេលអនុវត្តសកម្មភាព។

# ជំពូកទី២ ៖ ទំនាក់ទំនងល្អ



### ទិដ្ឋភាពទូទៅ

នៅក្នុងម៉ូឌុលទី១ ៖ «ខ្លួនឯង» សិស្សបានសិក្សាពីជំពូកមួយស្ដីពីការយល់ដឹងពីទំនាក់ទំនង និងអារម្មណ៍។ ជំពូកទី២ នៅក្នុងម៉ូឌុលទី២នេះ ៖ ទំនាក់ទំនងល្អផ្ដោតលើការជួយសិស្សឱ្យយល់ពីរបៀបដែលយេនឌ័រ និងអំណាចអាចមានឥទ្ធិពលលើការប្រាស្រ័យទាក់ទងរវាងបុគ្គលនានា។

សិស្សនឹងសិក្សាពីរបៀបចូលរួមបង្កើតទំនាក់ទំនងល្អ និងដោយការគោរពជាមួយមនុស្សផ្សេងៗទៀត។ ពួកគេនឹងរៀនកំណត់ពីរបៀបដែលអំណាចមានឥទ្ធិពលលើទំនាក់ទំនងរបស់ពួកគេ ព្រមទាំងរបៀបស្វែងយល់ និងចរចានៅពីទំនាក់ទំនងនោះ។

រយៈពេលរួមរបស់ជំពូក ៖ ៤៥ នាទី

ចំនួនលំនាំបង្រៀនសរុប ៖ ១មេរៀន

| វត្ថុបំណង៖ |
| --- |
| ១. ដើម្បីយល់ពីរបៀបដែលយេនឌ័រ និងអំណាចដើរតួជាផ្នែកមួយនៅក្នុងទំនាក់ទំនងរបស់យើង |
| ២. ដើម្បីយល់ពីអ្វីដែលធ្វើឱ្យមានទំនាក់ទំនងល្អមួយ។ |

# មេរៀនទី៤ ៖ តើនរណាជាអ្នកមានអំណាច?[2]

➲ **វត្ថុបំណងមេរៀន** ៖ ដើម្បីយល់ដឹងពីរបៀបដែលអំណាចដំណើរការនៅក្នុងទំនាក់ទំនងនានា និងដើម្បីមានលទ្ធភាពកំណត់ពីអ្វីដែលរួមចំណែកដល់ទំនាក់ទំនងល្អ និងមិនល្អ។

**រយៈពេលមេរៀន** ៖ ៤៥ នាទី

**សារសំខាន់ៗ** ៖

១. ការបែងចែកអំណាចមិនស្មើគ្នារវាងបុគ្គលពីរនាក់ជារឿយៗនាំឱ្យមានទំនាក់ទំនងមិនល្អ។ នេះគឺជាការពិតសម្រាប់ទំនាក់ទំនងភាគច្រើនដែលដំណើរការនៅក្នុងប្រព័ន្ធបិតាធិបតេយ្យ។

២. សម្រាប់ទំនាក់ទំនងល្អ វាមានសារៈសំខាន់ដែលបុគ្គល២នាក់ធ្វើការរួមគ្នា ហើយដែលអំណាចមិនមែនជាកម្មសិទ្ធិ ឬក្ដោបក្ដាប់ដោយបុគ្គលតែម្នាក់ *(ជាទូទៅបុរស)*។

៣. សម្រាប់ទំនាក់ទំនងល្អ វាមានសារៈសំខាន់ដែលដៃគូទាំង២ ឬបុគ្គលម្នាក់ៗរួមគ្នាដោះស្រាយបញ្ហារបស់ខ្លួន និងធ្វើការសម្រេចចិត្តរួមគ្នា។ ពួកគេត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នាប្រកបដោយប្រសិទ្ធភាព ព្រមទាំងគោរព និងគាំទ្រគ្នាទៅវិញទៅមក។

## ១. ការរៀបចំ

**សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាស A4 ចំនួន៤សន្លឹក ក្ដារខៀនហ្វឺត ឬដីស និងកន្ត្រៃ។

☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការក្នុងថ្នាក់ទំព័រទី៨២-៨៣ និងសម្ភារៈសរសេរ។

**ការរៀបចំទុកជាមុន** ៖

☞ អានទិដ្ឋភាពទូទៅនៅក្នុងជំពូកទី២ ៖ ទំនាក់ទំនងល្អ។

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ សរសេរស្ថានភាពសម្រាប់ការសម្ដែងតួនៅលើក្រដាសតូច (សូមមើលឯកសារអំណានទី១០ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។

☞ ប្រមូលសម្ភារៈផ្សេងទៀតដែលត្រូវការទាំងអស់។

☞ សរសេរចំណងជើងមេរៀននៅលើក្ដារខៀន។

---

[2] ដកស្រង់ពីអ្នកបង្កើតការផ្លាស់ប្ដូរ សំណុំឯកសារសម្រាប់សកម្មជនវ័យក្មេងសម្រាប់ការបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី - សូមមើល ៖ http://asiapacific.unwomen.org/en/digital-library/publications/2014/9/the-changemaker#sthash.Ac9tDT4q.dpuf

**⊶ គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សឱ្យចុះវត្តមាន នៅពេលពួកគេចូលមកក្នុងថ្នាក់រៀន។
- ពិនិត្យមើលថាតើសិស្សយកសន្លឹកកិច្ចការមកដែរឬទេ។
- សួរសិស្សថាតើពួកគេបានអានគន្លឹះផ្សេងៗស្ដីពី «ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព» បន្ទាប់មកធ្វើកិច្ចការផ្ទះរបស់ខ្លួនដែរឬទេ។
- ឱ្យសិស្សម្នាក់ៗប្រមូលសម្ភារៈសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

### សេចក្ដីណែនាំ

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបពីអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- ណែនាំជំពូកទី២ នៅក្នុងម៉ូឌុលទី២។
- អាន និងចង្អុលចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយថាតើមេរៀនអ្វីដែលត្រូវរៀននៅថ្ងៃនេះ។ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកគំនិតរបស់ពួកគេជាមួយក្រុម។
- ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះនឹងផ្ដោតលើចំណុចដូចខាងក្រោម ៖
  - របៀបដែលទំនាក់ទំនងនៅក្នុងជីវិតយើងតែងឆ្លងកាត់វិសមភាពដោយសារសង្គមបូនីយកម្ម និងការរំពឹងទុកនៃប្រព័ន្ធបិតាធិបតេយ្យ។
  - របៀបដែលគំនិតនៅក្នុងប្រព័ន្ធបិតាធិបតេយ្យដែលថាបុរសអាចគ្រប់គ្រងលើស្ត្រី និងរាងកាយរបស់ពួកគេ ជារឿយៗជ្រួតជ្រាបចូលទៅក្នុងទំនាក់ទំនងរវាងបុរស និងស្ត្រី ឬប្ដី និងប្រពន្ធដែលបង្កឱ្យមានមូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់ៗនានានៃអំពើហិង្សាទៅលើស្ត្រី។
- ប្រាប់សិស្សថា ដើម្បីយល់ពីរឿងនេះ ពួកគេជាបឋមត្រូវមានការយល់ដឹងមួយថាតើអំណាចមានលក្ខណៈដូចម្ដេចនៅក្នុងទំនាក់ទំនងនានា។
- ឱ្យសិស្សចាប់ដៃគូគ្នា។

**ជុំទី១**

☞ ចែកក្រដាសតូចៗដែលមានសរសេរស្ថានភាពឱ្យដៃគូនីមួយៗ បន្ទាប់មកផ្តល់ការណែនាំដូចខាងក្រោម ៖

- ដៃគូនីមួយៗគឺជាប្តីប្រពន្ធ *(ប្តីនិងប្រពន្ធ)*។ កំណត់ថាតើនរណានឹងសម្តែងតួអ្វី។
- ប្តីប្រពន្ធចាំបាច់ត្រូវពិភាក្សាពីស្ថានភាពណាមួយដែលជាទូទៅ ពួកគេត្រូវដោះស្រាយជារៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់ពួកគេ។ អត្ថបទនៅក្នុងក្រដាសតូចដែលចែកឱ្យគឺជាស្ថានភាពមួយ។
- ប្អូនមានពេល៥នាទីដើម្បីពិភាក្សាពីរបៀបដែលប្អូនដោះស្រាយស្ថានភាពនេះនៅក្នុងលក្ខណៈមួយដែល «**មិនល្អ**»។

☞ ប្រាប់សិស្សនៅក្នុងថ្នាក់ថា ដៃគូមួយចំនួនត្រូវឡើងមកសម្តែងស្ថានភាពនេះនៅក្នុងទម្រង់ជាការសម្តែងតួសម្រាប់ថ្នាក់ទាំងមូល។

☞ ដោយអាស្រ័យលើពេលវេលា ឱ្យសិស្សមួយគូ ឬ២គូឡើងមកសម្តែងតួពីស្ថានភាពរបស់ខ្លួនបង្ហាញដល់សិស្សនៅក្នុងថ្នាក់។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- យកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន នៅពេលសិស្សសម្តែងតួនៅជុំទី១ដែលពួកគេត្រូវពិភាក្សា និងសម្តែងពីស្ថានភាពដែលឆ្លុះបញ្ចាំងពីការទំនាក់ទំនង និងការមានអាកប្បកិរិយាមិនល្អរវាងប្តីប្រពន្ធ។ អាចមានសិស្សមួយចំនួនពិភាក្សា និងសម្តែងពីអាកប្បកិរិយាដែលពួកគេបានឃើញផ្ទាល់ភ្នែកនៅផ្ទះរបស់គេផ្ទាល់ (ឧទាហរណ៍ ស្ថានភាពស្តីពីការសម្រេចចិត្តជុំវិញប្រាក់ដែលឪពុករបស់កុមារីធ្វើការសម្រេចចិត្តទាំងអស់ និងមានអំណាចចំណែកម្តាយមិននិយាយអ្វីសោះពីបញ្ហានេះ)។
- សកម្មភាពនេះលើកទឹកចិត្តសិស្ស ឱ្យស្គាល់ពីរបៀបដែលអំណាចដើរតួនៅក្នុងការទំនាក់ទំនង។
- រង់ចាំពួកគេឆ្លើយសំណួរមុនពេលសួរសំណួរបន្ទាប់ទៀត។

**ជុំទី២**

☞ ឱ្យសិស្សរក្សាដៃគូរបស់ខ្លួនដដែល។ ប្រមូលក្រដាសស្ថានភាពមកវិញ។ ច្របល់ក្រដាសចូលគ្នា បន្ទាប់មកចែកទៅឱ្យដៃគូនីមួយៗវិញ។

☞ ផ្តល់ការណែនាំដូចខាងក្រោម ៖

– អនុវត្តដំណើរការដូចគ្នាក្នុងជុំទី១ ប៉ុន្តែ ឥឡូវត្រូវពិភាក្សាពីរបៀបដែលប្តីប្រពន្ធនីមួយៗនឹងដោះស្រាយស្ថានភាពនៅក្នុងក្រដាសតូចតាមវិធី «ល្អ»។

– ប្រាប់ពួកគេថា ពួកគេមានពេល៥នាទីដើម្បីធ្វើកិច្ចការនេះ។

☞ ដោយអាស្រ័យលើពេលវេលា ឱ្យសិស្សមួយគូ ឬពីរគូសម្តែងពីស្ថានភាពរបស់ខ្លួនដល់សិស្សនៅក្នុងថ្នាក់។

## ៣. ការពង្រឹងចំណេះដឹង

### ចំណុចសម្រាប់ការពិភាក្សា

☞ ចូលមកក្រុមធំវិញ។ ប្រើចំណុចខាងក្រោម នៅពេលសម្របសម្រួលការពិភាក្សាក្រុម ៖

- តើប្អូនមានអារម្មណ៍យ៉ាងណាក្រោយពីអនុវត្តសកម្មភាពនេះ? តើប្អូនចូលចិត្តអ្វីខ្លះពីសកម្មភាពនេះ?

- តើនរណាជាអ្នកមានអំណាចក្នុងជុំទី១នៃការពិភាក្សា និងការសម្តែង?

  *ចម្លើយអាចមាន ៖ ដៃគូដែលសម្តែងជាបុរស ឬប្តីជាអ្នកមានអំណាច។*

- តើគូ *(ប្តីប្រពន្ធ)* បានពិភាក្សាពីស្ថានភាពនៅក្នុងលក្ខណៈល្អ និងដោយមានការគោរពដោយរបៀបណានៅជុំទី២? តើវាខុសគ្នាយ៉ាងដូចម្តេចពីជុំទី១? តើមានការផ្លាស់ប្តូរអ្វីខ្លះ?

– *ចម្លើយអាចមាន ៖ ក្នុងជុំទី២ ដៃគូទាំង២ជាអ្នកធ្វើការសម្រេចចិត្តរួមគ្នា ហើយបង្ហាញពីគំនិតរបស់ខ្លួនចំពោះស្ថានភាពនោះ។ ដូច្នេះគេបែងចែកអំណាចកាន់តែស្មើគ្នារវាងប្តីប្រពន្ធ។*

- តើឧទាហរណ៍មួយចំនួនពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដែលគេប្រើមានអ្វីខ្លះ?

  *ចម្លើយអាចមាន ៖ ដៃគូទាំង២បើកចិត្តកាន់តែច្រើនក្នុងការស្តាប់គ្នាទៅវិញទៅមក។ ស្ត្រីនិយាយច្រើនពីការសម្រេចចិត្តលើស្ថានភាព។ ម្នាក់ៗគិតពីអ្វីដែលពួកគេត្រូវនិយាយ ព្រមទាំងមានភាពច្បាស់លាស់ និងដោយគោរពចំពោះការប្រាស្រ័យទាក់ទងរបស់គេទៅវិញទៅមក។*

- តើដៃគូនីមួយៗប្រព្រឹត្តិខុសគ្នាដូចម្តេចរវាងការសម្តែងនៅជុំទី១ និងជុំទី២?

  *ចម្លើយអាចមាន ៖ ក្នុងជុំទី១ ប្តីប្រពន្ធកំពុងពិភាក្សា ឬកំពុងដោះស្រាយបញ្ហាតាមវិធី «មិនល្អ»។ បុរសនៅក្នុងការសម្តែងមានអំណាច។ ក្នុងជុំទី២ អំណាចត្រូវបានបែងចែក (ពោលគឺប្តីប្រពន្ធបានពិភាក្សាពីស្ថានភាព និងធ្វើការសម្រេចចិត្តរួមគ្នា)។*

☞ ប្រាប់សិស្សនូវចំណុចដូចខាងក្រោម ៖

- ទំនាក់ទំនងល្អគឺជាទំនាក់ទំនងដែលភាគីទាំង២អាចស្តាប់គ្នាទៅវិញទៅមក និងប្រព្រឹត្តិចំពោះគ្នាដោយគោរព និងថ្លៃថ្នូរ។ នៅពេលមនុស្សម្នាក់មានអំណាចច្រើនជាងមនុស្សម្នាក់ទៀត ឬគេមិនផ្តល់តម្លៃ ឬការគោរពដោយសារតែយេនឌ័ររបស់គេ ការណ៍នេះអាចនាំឱ្យមានភាពតានតឹង ការគាបសង្កត់ និងពេលខ្លះមានអំពើហិង្សាជាដើម។
- រាល់ការប្រាស្រ័យទាក់ទងតែងតែជួបវិវាទ។ មិនថាទំនាក់ទំនងនៅក្នុងគ្រួសាររវាងឪពុកម្តាយ បងប្អូនបង្កើត មិត្តភក្តិ ឬដៃគូទេ វានឹងមានពេលវេលាមួយដែលប្អូនមិនយល់ស្របជាមួយគ្នាទៅវិញទៅមក ឬនរណាម្នាក់នៅក្នុងចំណោមប្អូនមិនសប្បាយចិត្ត។ នៅក្នុងទំនាក់ទំនងល្អ វិវាទនេះត្រូវបានដោះស្រាយតាមរយៈការប្រាស្រ័យទាក់ទង និងការប្រើប្រាស់ការគាំទ្ររបស់បណ្តាញនៅជុំវិញយើង។ គេមិនអាចដោះស្រាយវិវាទតាមទម្រង់ណាមួយនៃអំពើហិង្សា មិនថាលើផ្នែករូបរាងកាយ អារម្មណ៍ ផ្លូវភេទ ឬសេដ្ឋកិច្ចបានទេ។
- ក្នុងនាមជាមនុស្សដែលនៅវ័យក្មេង យើងក៏ត្រូវមានលទ្ធភាពយល់ថាតើវាមានន័យដូចម្តេចតាមរយៈពាក្យថាយល់ព្រមនិងការចរចា។ នៅក្នុងទំនាក់ទំនងដែលមានភាពផ្អែមល្ហែម មានការពិភាក្សាសំខាន់ៗមួយចំនួនដែលគេត្រូវធ្វើជុំវិញបញ្ហាសន្តិសុខ និងសុវត្ថិភាព។ វាជាទំនួលខុសត្រូវរបស់ដៃគូទាំង២ក្នុងការធានាថា សកម្មភាពណាមួយដែលកើតឡើងគឺមានការឯកភាព និងទទួលយកដែលនេះគឺជាអ្វីដែលមានន័យថា ការយល់ព្រមនោះ។ នៅពេលភាគីទាំង២យល់ព្រម វាបង្កើតបានបរិយាកាសសុវត្ថិភាពមួយដែលគេអាចមានភាពរីករាយជាមួយគ្នា។ នៅពេលមានការមិនឯកភាពគ្នាចំពោះផ្នែកផ្សេងៗនៃសកម្មភាពផ្លូវភេទដូចជាថាតើត្រូវប្រើថ្នាំពន្យារកំណើតដែរឬអត់ ដៃគូទាំង២ត្រូវស្តាប់គ្នាទៅវិញទៅមក ហើយយោបល់របស់គេត្រូវទទួលបានការគោរពនៅពេលដែលប្តីប្រពន្ធចរចាគ្នាពីរបៀបនៃការបន្តសកម្មភាពទៅមុខទៀត។ ក្នុងទំនាក់ទំនងល្អមួយ ពុំមានអ្នកណាមានអារម្មណ៍ថាទទួលរងការបង្ខំឱ្យចូលរួមក្នុងសកម្មភាពមួយដែលគេមានអារម្មណ៍មិនស្រួលក្នុងការចូលរួម។

☞ ពន្យល់ និងភ្ជាប់ទៅនឹងសកម្មភាព ៖

- សកម្មភាពនៃការសម្តែងតួធ្វើឱ្យយើងយល់ស៊ីជម្រៅពីរបៀបដែលមនុស្សមានទំនាក់ទំនងនានាធ្វើការជាមួយគ្នាដើម្បីដោះស្រាយស្ថានការណ៍ និងបញ្ហាផ្សេងៗ។ ដើម្បីឱ្យមានទំនាក់ទំនងល្អមួយ វាមានសារៈសំខាន់ ដែលបុគ្គលទាំង២ធ្វើការរួមគ្នា និងមានការបែងចែងអំណាចស្មើគ្នា។
- នៅក្នុងប្រព័ន្ធបិតាធិបតេយ្យ ជាទូទៅគេសន្មតថាវាជាការពិតដែលបុរសត្រូវគ្រប់គ្រង និងជាអ្នកដែលធ្វើការសម្រេចចិត្តសំខាន់ៗចំពោះទំនាក់ទំនងមួយ។ ទោះជាយ៉ាងណាក៏ដោយ

ការគ្រប់គ្រងប្រភេទនេះ និងអតុល្យភាពនៃអំណាចបង្កើតឱ្យមានទំនាក់ទំនងមិនល្អ មិនសប្បាយចិត្ត និងជាញឹកញាប់មានដំណើរការមិនល្អ។

- តាមរយៈការសម្តែងតួទាំង២លើក យើងបានដឹងថា វាពិតជាមានវិធីល្អៗដែលត្រូវនិយាយ និងដោះស្រាយស្ថានភាពនានានៅក្នុងទំនាក់ទំនងមួយដែលដៃគូទាំង២មានអារម្មណ៍ថាបានស្តាប់យោបល់គ្នា គោរពគ្នា និងធ្វើការសម្រេចចិត្តរួមគ្នា។
- គន្លឹះក្នុងការធ្វើឱ្យមានទំនាក់ទំនងល្អគឺការធានាថា គេប្រើប្រាស់ការប្រាស្រ័យទាក់ទងប្រកបដោយការគោរព និងការគិតគូរពិចារណាដោយស្មើភាពគ្នាទៅវិញទៅមកជានិច្ច ទោះបីជានៅពេលភាគីទាំងពីរមិនយល់ស្របគ្នាក៏ដោយ។

**កិច្ចការក្នុងថ្នាក់ ៖**

- ☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៨២ និង៨៣។
- ☞ អានសេចក្តីណែនាំ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេចាំបាច់ត្រូវធ្វើ។
- ☞ ប្រាប់ពួកគេថា ពួកគេមានពេល ១០នាទីដើម្បីធ្វើសកម្មភាពនេះ។
- ☞ សរុបមេរៀនដោយចែករំលែកចំណុចដូចខាងក្រោម ៖
  - មានប្រភេទទំនាក់ទំនងជាច្រើននៅក្នុងជីវិតរបស់យើង។ មិនមែនការប្រាស្រ័យទាក់ទងទាំងអស់សុទ្ធតែមានអំណាចស្មើគ្នានោះទេ (ឧទាហរណ៍ ឪពុកម្តាយ ឬគ្រូរបស់ប្អូននៅតែមានសិទ្ធិអំណាចច្រើនមកលើប្អូន)។
  - វាមានសារៈសំខាន់ក្នុងការចងចាំថា ទំនាក់ទំនងនីមួយៗដែលយើងមានចាំបាច់ត្រូវតែកសាងឱ្យបាននូវការគោរពគ្នាទៅវិញទៅមក និងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ នៅពេលដែលគេមិនស្តាប់នរណាម្នាក់ វាបង្កើតឱ្យមានតុល្យភាពអំណាចមិនល្អ ដូចដែលយើងបានឃើញតាមរយៈការឆ្លុះបញ្ចាំងនៅក្នុងសន្លឹកកិច្ចការ។ យើងក៏បានឃើញពីរបៀបដែលគេអាចប្រើប្រាស់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងការស្វែងរកមធ្យោបាយដែលត្រឹមត្រូវសម្រាប់ដោះស្រាយស្ថានភាពនៃតុល្យភាពអំណាចដែលលំបាកចំពោះប្រភេទខុសៗគ្នានៃទំនាក់ទំនងនៅក្នុងជីវិតរបស់យើង។
- ☞ ប្រសិនបើមានពេល ឱ្យសិស្សស្ម័គ្រចិត្តចែករំលែកអ្វីដែលពួកគេបានរៀនពីមេរៀននៅថ្ងៃនេះ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ប្រមូលសន្លឹកកិច្ចការទាំងអស់មុនពេលសិស្សបំបែកគ្នា។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី១០ ៖ ក្រដាសស្ថានភាព ៖ ការសម្តែងតួ

| |
|---|
| ការសម្រេចចិត្តពីប្រាក់នៅក្នុងគ្រួសារ ៖ ដើម្បីសន្សំ ចំណាយ និងការទិញ ឬវិនិយោគធំៗ។ |
| ការអប់រំថ្នាក់ឧត្តមសិក្សា។ ការបន្តការសិក្សា។ |
| ការចាប់ផ្តើមបង្កើតគ្រួសារ ៖ ការសម្រេចចិត្តថាត្រូវយក ឬមិនយកកូន ហើយកូនចំនួនប៉ុន្មានដែលត្រូវយក។ |
| ការប្រើប្រាស់ទូរសព្ទដៃជាឯកជន។ |
| ប្រភេទសម្លៀកបំពាក់អ្វីដែលត្រូវស្លៀកពាក់។ |
| ការចេញពីផ្ទះទៅធ្វើការ។ |
| ការចេញទៅជួបមិត្តភក្តិ។ |

**សេចក្តីណែនាំ ៖**

- ចតចម្លងក្រដាសនេះចំនួន៣ទៅ៤ច្បាប់ដូចបង្ហាញខាងលើដោយអាស្រ័យលើចំនួនសិស្សនៅក្នុងថ្នាក់របស់លោកគ្រូ អ្នកគ្រូ ។
- ចងចាំថា ដៃគូនីមួយៗត្រូវមានសន្លឹកស្ថានភាពមួយ។
- កាត់ក្រដាសស្ថានភាពតាមបន្ទាត់ចុចៗ។
- យកក្រដាសស្ថានភាពតាមខ្លួនសម្រាប់អនុវត្តសកម្មភាពនេះ។

# ជំពូកទី៣ ៖ ការយល់ដឹងពីអំពើហិង្សា



## ទិដ្ឋភាពទូទៅ

អង្គការសហប្រជាជាតិកំណត់និយមន័យអំពើហិង្សាប្រឆាំងនឹងស្ត្រី (VAW) ថាជា «ទង្វើណាមួយនៃអំពើហិង្សាតាមយេនឌ័រដែលនាំឱ្យ ឬអាចនាំឱ្យមានគ្រោះថ្នាក់លើរូបរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ឬរងគ្រោះដល់ស្ត្រីរួមមាន ការគំរាមកំហែងនូវសកម្មភាពនានាដូចជា ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមអំពើចិត្តមិនថាកើតឡើងនៅតាមទីសាធារណៈ ឬនៅក្នុងជីវិតឯកជនឡើយ»។ (UN ឆ្នាំ១៩៩៣) និយាយម្យ៉ាងទៀត អំពើហិង្សាអាចមានន័យច្រើន។ វាអាចជាអំពើហិង្សាលើរូបរាងកាយ ផ្លូវចិត្ត ផ្លូវភេទ ឬសេដ្ឋកិច្ច។ អំពើហិង្សាកើតឡើងនៅពេលណាដែលមនុស្សម្នាក់បង្កឱ្យមនុស្សម្នាក់ទៀតឈឺចាប់ ឬមានរបួស។ ច្បាប់អន្តរជាតិទទួលស្គាល់ថាអំពើហិង្សាប្រឆាំងនឹងស្ត្រី ថាជា  ការរំលោភបំពានលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ស្ត្រី និងថាជាទម្រង់ច្បាស់លាស់មួយនៃការរើសអើងផ្អែកយេនឌ័រ។ ការបែងចែកអំណាចមិនស្មើភាពគ្នារវាងបុរសនិងស្ត្រីបង្កើតឱ្យមានប្រព័ន្ធនៃបិតាធិបតេយ្យដែលសិទ្ធិរបស់ស្ត្រីទទួលរងការកៀបសង្កត់ ហើយពួកគេក្លាយជាជនងាយរងគ្រោះពីការកេងប្រវ័ញ្ច និងការរើសអើង។ ដោយវាបានចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងវិសមភាពយេនឌ័រ ប្រព័ន្ធទាំងនេះអនុញ្ញាតឱ្យបុរសគ្រប់គ្រងលើស្ត្រី។ ការណ៍នេះបង្កើតឱ្យមានឱកាសមួយចំពោះការប្រព្រឹត្តអំពើហិង្សាទោះបីជាលើរូបរាងកាយ អារម្មណ៍ ផ្លូវចិត្ត ឬសេដ្ឋកិច្ចក្តី។

ជាញឹកញាប់ ស្ត្រីប្រឈមមុខនឹងការជំទាស់ចំពោះសិទ្ធិរបស់ខ្លួនក្នុងការគ្រប់គ្រង ត្រួតត្រា និងសិទ្ធិទទួលបានសិទ្ធិមូលដ្ឋានផ្សេងៗដូចជា ការអប់រំ ប្រព័ន្ធថែទាំសុខភាព ហិរញ្ញវត្ថុជាដើម។

ជំពូកទី៣នៅក្នុងម៉ូឌុលទី២ ជួយក្មេងស្រីឱ្យយល់កាន់តែទូលំទូលាយពីអំពើហិង្សា និងទម្រង់ខុសៗគ្នានៃអំពើហិង្សា កំណត់ពីអំពើហិង្សានៅជុំវិញខ្លួនរបស់គេ និងអាចឱ្យពួកគេប្រមើលមើលការផ្លាស់ប្តូរដែលអាចមាននៅក្នុងរចនាសម្ព័ន្ធមូលដ្ឋានរបស់សង្គមបច្ចុប្បន្ន។

🕘 **រយៈពេលជំពូក ៖ ២ ម៉ោង ២៥ នាទី**

**ចំនួនលំនាំបង្រៀនសរុប ៖ ៣ មេរៀន**

| 🏆 **វត្ថុបំណង៖** |
| --- |
| ១. ដើម្បីមានលទ្ធភាពកំណត់ទង្វើខុសៗគ្នានៃអំពើហិង្សានៅក្នុងបរិយាកាសជុំវិញ និងជីវិតប្រចាំថ្ងៃរបស់គេ។ |
| ២. ដើម្បីមានការយល់ដឹងមួយពីទម្រង់ខុសៗគ្នានៃអំពើហិង្សា និងកត្តាទូទៅដែលស្ថិតនៅពីក្រោយអំពើហិង្សា។ |
| ៣. ដើម្បីមានលទ្ធភាពប្រមើលមើលការផ្លាស់ប្តូរដែលអាចកើតមាននៅក្នុងរចនាសម្ព័ន្ធមូលដ្ឋានរបស់សង្គមបច្ចុប្បន្ន។ |

# មេរៀនទី៥ ៖ តើអំពើហិង្សាជាអ្វី?[3]

➲ **វត្ថុបំណងមេរៀន** ៖ ដើម្បីកំណត់ និងយល់ពីទម្រង់ខុសៗគ្នានៃអំពើហិង្សាដែលគេជួបប្រទះ និងកត្តាទូទៅដែលស្ថិតនៅពីក្រោយអំពើហិង្សា។

🕘 **រយៈពេល** ៖ ៤៥ នាទី

✉ **សារសំខាន់ៗ** ៖

១. អំពើហិង្សាលើស្ត្រីរួមមានទង្វើណាមួយនៃអំពើហិង្សាផ្អែកយេនឌ័រដែលនាំឱ្យ ឬអាចនាំឱ្យមានរបួស ឬការឈឺចាប់លើរូបរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តរបស់ស្ត្រី។ អំពើហិង្សាទាំងនោះរួមមានការគំរាមកំហែងដូចជាទង្វើ ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមអំពើចិត្តមិនថាតើវាកើតមានក្នុងទីសាធារណៈ ឬនៅក្នុងជីវិតឯកជនឡើយ»។

២. អំពើហិង្សាអាចកើតមានតាមទម្រង់ណាមួយដូចជាលើរូបរាងកាយ អារម្មណ៍ ហិរញ្ញវត្ថុ ឬផ្លូវភេទ។

៣. អំពើហិង្សាមិនអាចមានភាពស្របច្បាប់ទេទោះបីស្ថិតក្រោមកាលៈទេសៈណាមួយក៏ដោយ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាសA4មួយសន្លឹក ម៉ាស៊ីនថតចម្លង ក្រដាសផ្ទាំងធំមួយសន្លឹក ក្តារខៀន ហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះ ស្កុត និងកន្ត្រៃ។

☞ សម្រាប់សិស្ស ៖ គ្មាន។

**ការរៀបចំទុកជាមុន** ៖

☞ អានទិដ្ឋភាពទូទៅនៅក្នុងជំពូកទី៣ ៖ ការយល់ដឹងពីអំពើហិង្សា និង ឯកសារអំណានទី១១ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

---

[3] ដកស្រង់ពីកម្មវិធីសិក្សា GEMS (ICRW)

- ☞ រៀបចំបណ្ណចម្លើយចំនួន៣សន្លឹកដោយប្រើក្រដាសផ្ទាំងធំ (សូមមើល ឯកសារអំណានទី១២ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ ថតចម្លង «រឿងទាំង៣ តើវាជាអំពើហិង្សាឬ?» មួយច្បាប់ (សូមមើលឯកសារអំណានទី១៣ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ ប្រមូលសម្ភារៈដែលត្រូវការទាំងអស់ផ្សេងទៀត។
- ☞ បិទបណ្ណចម្លើយទាំង៣នៅលើជញ្ជាំងខុសៗគ្នាក្នុងថ្នាក់រៀន *(ប្រសិនបើអាចធ្វើទៅបាន)*។
- ☞ សរសេរចំណងជើងមេរៀននៅលើក្ដារខៀន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្ស ឱ្យចុះវត្តមានរបស់ពួកគេនៅពេលពួកគេចូលថ្នាក់រៀន ។
- មុនពេលចាប់ផ្ដើមធ្វើសកម្មភាព សូមពិនិត្យឡើងវិញ និងសង្កត់ធ្ងន់ទៅលើបទបញ្ញាផ្ទៃក្នុងដែលបានបង្កើត «**តំបន់របស់យើង**» ដែលរួមមានការរក្សាការសម្ងាត់ ការគោរព និងការទុកចិត្តចំពោះគ្នាទៅវិញទៅមក។

## ២. ដំណើរការបង្រៀន

### សេចក្ដីណែនាំ

- ☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ☞ ឱ្យសិស្សស្ម័គ្រចិត្ត២- ៣នាក់សង្ខេបអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- ☞ ណែនាំជំពូកទី៣នៅក្នុងម៉ូឌុលទី២ (សូមមើលឯកសារអំណានទី១១ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ អាន និងចង្អុលចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយថា តើមេរៀនថ្ងៃនេះរៀនពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុម។
- ☞ ប្រាប់សិស្សថា មេរៀនថ្ងៃនេះនឹងមានរឿងចំនួន៣ដែលនឹងជួយពួកគេឱ្យយល់កាន់តែទូលំទូលាយ និងកំណត់ទម្រង់នៃអំពើហិង្សាក្នុងស្ថានភាព និងកាលៈទេសៈខុសៗគ្នា។
- ☞ អានរឿងនីមួយៗឮៗម្ដងមួយៗ (សូមមើលឯកសារអំណានទី១៣ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។ បន្ទាប់ពីអានរឿងនីមួយៗ រួចហើយ សួរសិស្សនូវសំណួរដូចខាងក្រោម ៖
  - តើនេះជាអំពើហិង្សាឬ?

☞ លើកទឹកចិត្តសិស្សឱ្យឆ្លុះបញ្ចាំងពីរឿងនីមួយៗ បន្ទាប់មកបង្ហាញចម្លើយរបស់ខ្លួនដោយឈរនៅក្បែរបណ្ណចម្លើយណាមួយក្នុងចំណោមបណ្ណចម្លើយទាំង៣នៅលើជញ្ជាំង។ បណ្ណមានចម្លើយមួយក្នុងចំណោមចម្លើយនានាដែលមានសរសេរដូចខាងក្រោម ៖

– បាទ/ចាំ! វាជាអំពើហិង្សា។
– ទេ! វាមិនមែនជាអំពើហិង្សាទេ។
– ខ្ញុំមិនប្រាកដទេ។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ធ្វើការសង្កេត និងប្រុងប្រយ័ត្នខ្ពស់នៅពេលរៀនមេរៀននេះ ដោយសារប្រធានបទមួយចំនួនអាចបង្ហាញឱ្យឃើញនូវការរំខានអារម្មណ៍របស់សិស្សមួយចំនួន។ វាក៏អាចមានលទ្ធភាពដែរដែលសិស្សមួយចំនួនជ្រើសរើសចែករំលែករឿងផ្ទាល់ខ្លួនរបស់គេ។ ប្រសិនបើមានជួបប្រទះរឿងនេះនៅពេលកំពុងបង្រៀនជំពូកនេះ ចូរដោះស្រាយរឿងនេះជាលក្ខណៈបុគ្គលនៅវគ្គ «មួយទល់មួយ» ដែលបង្កើតឱកាសមួយឱ្យសិស្សនិយាយដោយបន្ទាប់មកលោកគ្រូ អ្នកគ្រូអាចជួយផ្តល់ជំនួយ និងការគាំទ្រដល់ពួកគេ។

## ៣. ការពង្រឹងចំណេះដឹង

### 🗣 ចំណុចសម្រាប់ការពិភាក្សា

☞ ឱ្យសិស្សចូលក្រុមធំវិញដើម្បីធ្វើការពិភាក្សា។

☞ សួរសិស្សនូវសំណួរដូចខាងក្រោម ៖

- តើមានរឿងណាមួយក្នុងចំណោមរឿងទាំងនេះដូចគ្នានឹងរឿងពិតរបស់ប្អូនដែរឬទេ?
- តើមាននរណាម្នាក់បានឃើញ ឬស្តាប់ឮពីឧប្បត្តិហេតុដូចគ្នាចំពោះអ្នកជិតខាងរបស់ខ្លួនដែរឬទេ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– យើងទាំងអស់គ្នាបានឃើញទម្រង់ខុសៗគ្នានៃអំពើហិង្សានៅជុំវិញយើង។
– ជារឿយៗ យើងមានអារម្មណ៍ថា អំពើហិង្សាលើស្ត្រីកើតឡើងតែនៅក្នុងសហគមន៍មួយចំនួន និងស្ថិតក្រោមកាលៈទេសៈមួយចំនួនប៉ុណ្ណោះ។ ប៉ុន្តែ ការសិក្សាមួយចំនួនទាំងថ្នាក់ជាតិ និងអន្តរជាតិបានបង្ហាញថា អំពើហិង្សាផ្អែកយេនឌ័រកើតមានយ៉ាងទូលំទូលាយ។ មាន

ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីបីនាក់នៅទូទាំងសកលលោកបានជួបប្រទះទម្រង់មួយចំនួននៃអំពើហិង្សាពេញមួយជីវិតរបស់ពួកគេ។

– យោងតាមរបាយការណ៍របស់ធនាគារពិភពលោកស្តីពីការកំណត់(ផែនទី)ស្ថាប័នដែលធ្វើការផ្តែកអំពើហិង្សាយេនឌ័រ[4]ចេញផ្សាយថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ស្ត្រីកម្ពុជាចំនួន២១% បានរាយការណ៍ឧប្បត្តិហេតុនៃអំពើហិង្សាផ្នែករាងកាយ ឬផ្លូវភេទ ឬទាំង២ពីសំណាក់ដៃគូរបស់ខ្លួន។

☞ សួរសំណួរដូចខាងក្រោម ៖

 ◈ សិស្សដែលបានឆ្លើយថា «បាទ/ចាំ! វាជាអំពើហិង្សា» សម្រាប់ករណីក្នុងរឿងទី២ ៖ សូមលើកដៃរបស់ប្អូនឡើង។
 ◈ ហេតុអ្វីបានជាប្អូនគិតថាទម្រង់ទាំងនោះគឺជាអំពើហិង្សា? សូមប្អូនភ្ជាប់ទម្រង់ទាំងនេះទៅនឹងឧប្បត្តិហេតុដែលបានរៀបរាប់នៅក្នុងសាច់រឿងវិញដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយរបស់ប្អូន។

☞ កត់ទុកចម្លើយនៅលើក្តារខៀន នៅពេលដែលសិស្សនិយាយ។

☞ បន្ទាប់មកសួរសិស្សទាំងអស់នូវសំណួរដូចខាងក្រោម ៖

 ◈ តើប្អូនមានបានកត់សម្គាល់ឃើញពីទម្រង់ខុសគ្នានៃអំពើហិង្សានៅក្នុងរឿងដែលបានអានដែរឬទេ?

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ប្រើប្រាស់សំណួរបើកដើម្បីសម្របសម្រួលការពិភាក្សាក្នុងការជួយក្រុមឱ្យកំណត់ពីទម្រង់ខុសគ្នានៃអំពើហិង្សា។

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចខាងក្រោម ៖

– អំពើហិង្សាអាចមានទម្រង់ខុសៗគ្នាជាច្រើន។ វាអាចជាអំពើហិង្សាលើរូបរាងកាយ ផ្លូវចិត្ត ផ្លូវភេទ ឬសេដ្ឋកិច្ច។ អំពើហិង្សាកើតមានឡើង នៅពេលដែលមនុស្សម្នាក់បង្កឱ្យមនុស្សម្នាក់ទៀតឈឺចាប់ ឬរងរបួស។

[4] http://documents1.worldbank.org/curated/en/644691594091820996/pdf/Cambodia-Gender-Based-Violence-Institutional-Mapping-Report.pdf

- គេទទួលស្គាល់អំពើហិង្សាប្រឆាំងនឹងស្ត្រី (VAW) ថាជាការរំលោភបំពានលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ស្ត្រី និងថាជាទម្រង់ច្បាស់លាស់មួយនៃការរើសអើងផ្នែកយេនឌ័រ។
- ជារឿយៗ យើងទទួលស្គាល់ពីអំពើហិង្សាថាជាទម្រង់នៃការបំពានលើរូបរាងកាយ។ ទោះជាយ៉ាងណាក៏ដោយ ទម្រង់នៃអំពើហិង្សាដែលមានលក្ខណៈគំរាមកំហែងកាន់តែខ្លាំងអាចមានដូចខាងក្រោម ៖
  - អំពើហិង្សាផ្នែកសេដ្ឋកិច្ច ៖ ការបដិសេធមិនឱ្យដៃគូគ្រប់គ្រងលើធនធានមូលដ្ឋាន។ អំពើហិង្សានេះរួមមាន ទង្វើនានាដូចជាការបដិសេធមិនឱ្យគ្រប់គ្រប់លើថវិកា ការបដិសេធមិនចែករំលែកហិរញ្ញវត្ថុ ការបដិសេធមិនឱ្យទទួលទានម្ហូបអាហារ និងតម្រូវការជាមូលដ្ឋានផ្សេងៗ ឬការគ្រប់គ្រងលើសិទ្ធិទទួលបានការថែទាំសុខភាព ការងារជាដើម។
  - អំពើហិង្សាលើរូបរាងកាយ ៖ ការប្រើកម្លាំងលើរូបរាងកាយដោយចេតនាដែលអាចបង្កឱ្យស្លាប់ របួស ឬឈឺចាប់។
  - អំពើហិង្សាផ្នែកអារម្មណ៍ ៖ ទង្វើ ឬការបំភ្លេចចោលណាមួយដែលធ្វើឱ្យខូចដល់ការឱ្យតម្លៃលើខ្លួនឯង អត្តសញ្ញាណ ឬការអភិវឌ្ឍរបស់បុគ្គលណាម្នាក់។ អំពើហិង្សានេះរួមមាន ការបំបាក់មុខ ការគំរាមកំហែង ការបង្ខំឱ្យនៅឯកោ ឬការបន្ទាបបន្ថោកម្តងហើយម្តងទៀត។
  - អំពើហិង្សាផ្លូវភេទ ៖ ទង្វើណាមួយដែលមនុស្សម្នាក់ស្ថិតក្នុងទំនាក់ទំនងមួយប្រើកម្លាំង ការបង្ខិតបង្ខំ ឬការបំភិតបំភ័យផ្លូវចិត្តដើម្បីបង្ខំឱ្យមនុស្សម្នាក់ទៀតអនុវត្តទង្វើផ្លូវភេទណាមួយប្រឆាំងនឹងឆន្ទៈរបស់គេ។ អំពើហិង្សានេះអាចមានចាប់ពីការបង្ខំឱ្យមើលសម្ភារៈដែលមានលក្ខណៈអាសអាភាស រហូតដល់ការប៉ះរាងកាយដូចជាការស្ទាបមិនសមស្រប ឬការបំពានផ្លូវភេទ។

☞ សួរសិស្សនូវសំណួរដូចខាងក្រោម ៖

  ◈ តើនរណាប្រឈមនឹងអំពើហិង្សា? ហេតុអ្វី?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកនូវចំណុចដូចខាងក្រោម ៖

- អំពើហិង្សាមិនមានភាពរើសអើងទេ ហើយអាចប៉ះពាល់ដល់ស្ត្រីដោយមិនគិតពីប្រទេស ជាតិពន្ធុ ប្រាក់ចំណូល ឬសាសនារបស់ពួកគេឡើយ។
- ស្ត្រីទោះនៅអាយុណាក៏ដោយក៏អាចជួបអំពើហិង្សាដែរពោលគឺចាប់តាំងពីមុនកើតរហូតដល់ចាស់។

- មានប្រភេទខុសៗគ្នានៃអំពើហិង្សាដែលទាក់ទងនឹងយេនឌ័ររបស់មនុស្ស។ អំពើហិង្សាមិនចាំបាច់តែជាអ្វីមួយដែលមានតែបុរសធ្វើមកលើស្ត្រីនោះទេ។ អំពើហិង្សាផ្អែកយេនឌ័រសំដៅលើទម្រង់នានានៃអំពើហិង្សាទៅលើមនុស្សណាម្នាក់ដែលប្រឈមនឹងអំពើហិង្សាដោយសារយេនឌ័ររបស់ពួកគេ។ អ្នកទាំងនេះរួមមានស្ត្រី មនុស្សក្រុមភេទទីបី និងបុរស។ នៅពេលដែលពួកគេនៅក្មេង ក្មេងប្រុស និងក្មេងស្រីជួបទម្រង់ដូចគ្នានៃអំពើហិង្សា (ការដាក់ពិន័យលើរាងកាយ ការបំពានផ្លូវភេទ) ទោះបីក្មេងស្រីជួបប្រទះអំពើហិង្សាច្រើនជាងក្នុងទម្រង់មួយចំនួនក៏ដោយ (ឧទាហរណ៍ ការបញ្ចប់ការមានផ្ទៃពោះ ប្រសិនបើកូនក្នុងផ្ទៃជាទារិកា ការមិនផ្តល់អាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ ការទទួលបន្ទុកលើការទទួលខុសត្រូវក្នុងគ្រួសារច្រើន ខ្វះសិទ្ធិទទួលបានការអប់រំ ។ល។) ហើយក្មេងប្រុសពេលខ្លះទទួលរងការដាក់ពិន័យលើរាងកាយច្រើននៅសាលារៀន និងនៅផ្ទះ។
- នៅពេលពួកគេធំឡើង ទម្រង់នៃអំពើហិង្សាចាប់ផ្តើមមានភាពខុសគ្នា។ បុរស និងក្មេងប្រុសពេញវ័យអាចជាជនរងគ្រោះនៃអំពើហិង្សានៅខាងក្រៅផ្ទះ (ឧទាហរណ៍ សង្គ្រាម អំពើហិង្សាផ្អែកជាតិពន្ធ ក្រុមបងធំជាដើម) ចំណែកស្ត្រី និងក្មេងស្រីពេញវ័យអាចជាជនរងគ្រោះនៃអំពើហិង្សានៅក្នុងផ្ទះ (អំពើហិង្សាក្នុងគ្រួសារ ការបំពានផ្លូវភេទ ការត្រួតត្រាអារម្មណ៍ជាដើម)។ បុរសហាក់មានការគ្រប់គ្រងច្រើនលើប្រភេទនៃអំពើហិង្សាដែលពួកគេជួប ឬជាប់ពាក់ព័ន្ធ (ឧទាហរណ៍ មិនមែនបុរសទាំងអស់សុទ្ធតែជាផ្នែកនៃក្រុមបងធំ ឬចូលទៅក្នុងសង្គ្រាមនោះទេ) ចំណែកស្ត្រីមានការគ្រប់គ្រងតិចលើអំពើហិង្សាដែលពួកគេជួបប្រទះ (ឧទាហរណ៍ ពួកគេមិនជ្រើសរើសយកប្តីប្រើហិង្សា ឬឪពុកម្តាយប្រើហិង្សាទេ)។ មនុស្សក្រុមភេទទីបី និងក្រុមមនុស្សប្តូរភេទជារឿយៗប្រឈមនឹងអំពើហិង្សាពីមនុស្សផ្សេងទៀតដោយសារតែស្លាកស្នាមទុយសដែលនៅជុំវិញអត្តសញ្ញាណយេនឌ័ររបស់ខ្លួន។

☞ សួរសំណួរដូចខាងក្រោម ៖

- ◈ សិស្សដែលបានឆ្លើយថា «ទេ មិនមែនជាអំពើហិង្សាទេ» ចំពោះរឿងទី២ ៖ សូមលើកដៃរបស់ប្អូន។
- ◈ ភ្ជាប់សាច់រឿងទៅនឹងចម្លើយរបស់ប្អូនវិញដើម្បីផ្តល់សុពលភាពដល់ចម្លើយរបស់ប្អូន។

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកនូវចំណុចដូចខាងក្រោម ៖

- នៅទូទាំងសហគមន៍ គេមើលឃើញថាអំពើហិង្សាគឺជាទម្រង់សមហេតុផលនៃការបង្ខិតបង្ខំដើម្បីបង្កើតឱ្យមាន «សណ្តាប់ធ្នាប់» និងការធានាថា រចនាសម្ព័ន្ធមូលដ្ឋានរបស់សង្គមមិនមានបញ្ហាប្រឈមទេ។

- ជាអកុសល មូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធសង្គមនេះគឺស្ថិតក្នុងរចនាសម្ព័ន្ធបិតាធិបតេយ្យដែលធ្វើឱ្យអាកប្បកិរិយានៃការបំពាន និងអំពើហិង្សាមានលក្ខណៈធម្មតា។
- ជារឿយៗអំពើហិង្សាផ្នែកយេនឌ័រពុំមានរបាយការណ៍គ្រប់គ្រាន់ទេដោយសារតែវាជាទម្រង់នៃអាកប្បកិរិយាដែលគេទទួលយកជាទូទៅ ប៉ុន្តែវាបង្ហាញពីការដាក់ឱ្យនៅក្រោមការត្រួតត្រា និងការគ្រប់គ្រង។ ការរក្សាភាពស្ងៀមស្ងាត់ជុំវិញអំពើហិង្សាគឺជាហេតុផលមួយក្នុងចំណោមហេតុផលនានាដែលធ្វើឱ្យមានរបាយការណ៍មិនគ្រប់គ្រាន់ ទោះបីជាវាមានផលប៉ះពាល់យ៉ាងទូលំទូលាយទៅលើស្ត្រីក៏ដោយ។
- មានមធ្យោបាយដ៏ច្បាស់លាស់ និងអាចមើលឃើញយ៉ាងច្រើននៃការគ្រប់គ្រង និងអំណាចដែលគេអនុវត្តចំពោះទំនាក់ទំនងខុសៗគ្នា ហើយពេលខ្លះគេចាត់ទុកថាជាមធ្យោបាយត្រឹមត្រូវមួយក្នុងការគ្រប់គ្រង និង «បង្រៀន» ជនរងគ្រោះពី «មេរៀនស្តីពីអាកប្បកិរិយាដែលត្រូវទទួលយករបស់គេ»។ ឧទាហរណ៍ គេចាត់ទុកអំពើហិង្សានៅក្នុងគ្រួសារលើស្ត្រីថាជារឿងធម្មតាដែលជាទង្វើមួយរបស់ប្តីដែលបញ្ចេញកំហឹងរបស់ខ្លួនដើម្បីឱ្យប្រាកដថា ប្រពន្ធរបស់ខ្លួន «ស្តាប់បង្គាប់» និង «ស្មោះត្រង់»។ បងៗនៅក្នុងគ្រួសារចាត់ទុកអំពើហិង្សាទៅលើប្អូនៗថាជារឿងត្រឹមត្រូវដោយសារតែគេមើលឃើញរឿងនេះថាជាវិធីរបស់ខ្លួនក្នុងការ «បង្រៀន» មេរៀនផ្សេងៗដល់ប្អូន។

☞ សួរសំណួរដូចខាងក្រោម ៖

  ◈ តាមការយល់របស់ប្អូន តើប្អូនយល់ដូចម្តេចចំពោះអំពើហិង្សា? តើប្អូនគិតថាវាជាអ្វី?

☞ សម្របសម្រួលការពិភាក្សាដើម្បីជួយក្រុមឱ្យសម្រេចបាននិយមន័យផ្ទាល់របស់ពួកគេ។ សម្របសម្រួលការពិភាក្សារបស់សិស្សជុំវិញខ្លឹមសារដែលបានផ្តល់ឱ្យនៅក្នុងឯកសារអំណានទី១១ ៖ ការយល់ពីអំពើហិង្សា ៖ តើវាជាអ្វី?

☞ សរុបមេរៀនដោយសួរសិស្សនូវសំណួរចុងក្រោយមួយ ៖

  ◈ តើអំពើហិង្សាជារឿងត្រឹមត្រូវដែរឬទេ?

☞ ទទួលយកចម្លើយ បន្ទាប់មកមើលខ្លឹមសារនៅក្នុងឯកសារអំណានទី១១ ៖ តើអំពើហិង្សាជារឿងត្រឹមត្រូវដែរឬទេ? ដើម្បីពន្យល់ថា អំពើហិង្សាមិនមែនជារឿងត្រឹមត្រូវទេទោះស្ថិតក្រោមកាលៈទេសៈណាមួយក៏ដោយ។

☞ ប្រសិនបើមានពេល បូកសរុបពីអ្វីដែលបានរៀនសូត្រពីមេរៀននេះ។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី១១ ៖ ឯកសារអំណានសម្រាប់គ្រូបង្រៀន

**បរិបទចំណេះដឹង ៖ អំពើហិង្សា**

- **ការយល់ដឹងពីអំពើហិង្សា ៖ តើវាជាអ្វី?**
  - ទង្វើណាមួយនៃការប្រើអំណាចដែលមានបំណងធ្វើឱ្យនរណាម្នាក់ឈឺចាប់ *(ស្មារតី រាងកាយ ផ្លូវភេទ ឬអារម្មណ៍)* ដែលជាការប្រឆាំងនឹងអ្នកនោះដោយផ្ទាល់គឺជាអំពើហិង្សា។ វាមិនមែនជាទម្រង់នៃអាកប្បកិរិយាដែលមានការព្រមព្រៀងគ្នា ឬអាចទទួលយកបានទេ ដោយសារវាជាការរំលោភបំពានទាំងស្រុងទៅលើសិទ្ធិមូលដ្ឋានរបស់បុគ្គលម្នាក់ៗ។
  - ប្រព័ន្ធបិតាធិបតេយ្យគឺជាអ្នកបង្កើតឱ្យមានការបែងចែកអំណាចមិនស្មើភាពគ្នារវាងបុរស និងស្ត្រី ដែលសិទ្ធិរបស់ស្ត្រីត្រូវទទួលរងការកៀបសង្កត់ ហើយពួកគេក្លាយជាជនងាយរងគ្រោះពីការកេងប្រវ័ញ្ច និងការរើសអើង។ ដោយមានវាចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងវិសមភាពយេនឌ័រ ប្រព័ន្ធទាំងនេះអនុញ្ញាតឱ្យបុរសគ្រប់គ្រងលើស្ត្រី។ ការណ៍នេះបង្កើតបានជាឱកាសមួយដែលធ្វើឱ្យអំពើហិង្សាកើតឡើងមិនថាលើរូបរាងកាយ អារម្មណ៍ ផ្លូវចិត្ត ឬសេដ្ឋកិច្ចឡើយ។
  - អំពើហិង្សាប៉ះពាល់ដល់មនុស្សគ្រប់រូបនៅក្នុងសហគមន៍រួមមាន កុមារ ឪពុកម្តាយ គ្រូ មន្ត្រីរដ្ឋាភិបាល និងយុវជន។ នោះមានន័យថា មនុស្សគ្រប់គ្នាមានតួនាទីក្នុងការអនុវត្តដើម្បីទប់ស្កាត់អំពើហិង្សាបើទោះបីតាមរយៈការនិយាយពីអំពើហិង្សា ការលើកកម្ពស់ការយល់ដឹង ឬការតស៊ូមតិឱ្យមានការផ្លាស់ប្តូរនៅកម្រិតណាមួយក៏ដោយ។
- **តើអំពើហិង្សាជារឿងស្របច្បាប់ដែរឬទេ?**
  - អំពើហិង្សាមិនមែនជារឿងស្របច្បាប់ទេទោះបីជាវាស្ថិតនៅក្រោមកាលៈទេសៈណាមួយក៏ដោយ។
  - វាជាសិទ្ធិមូលដ្ឋានរបស់យើងក្នុងការរស់នៅក្នុងជីវិតប្រកបដោយភាពថ្លៃថ្នូរ ហើយទង្វើណាមួយនៃការដាក់សម្ពាធទៅលើជនរងគ្រោះដែលដកហូតសិទ្ធិទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេគឺជារឿងខុសច្បាប់។
  - ទង្វើណាមួយប្រឆាំងនឹងការឯកភាពរបស់នរណាម្នាក់ដែលប៉ះពាល់ដល់សុខុមាលភាពរាងកាយ និងអារម្មណ៍របស់គេគឺអាចចាត់ទុកថាជាអំពើហិង្សា។ វាមានសារៈសំខាន់ក្នុងការចងចាំថា អំពើហិង្សាមិនមែនជារឿងធម្មតាដែលមានចម្លើយយ៉ាងសាមញ្ញមួយទេ។ ការបញ្ចប់អំពើហិង្សាប្រឆាំងនឹងស្ត្រី(VAW)ទាមទារឱ្យមានការផ្លាស់ប្តូរជាមូលដ្ឋាន និង រយៈពេលវែងនៅគ្រប់កម្រិតទាំងអស់ដែលរួមមានបុគ្គលម្នាក់ៗ គ្រួសារ សហគមន៍ និងប្រទេសជាតិដែលដោះស្រាយនូវ ឫសគល់នៃការរើសអើង និងវិសមភាពយេនឌ័រ។

## ឯកសារអំណានទី១២ ៖ គំរូបណ្ណចម្លើយ

| | |
|---|---|
| បាទ/ចាស! វាជាអំពើហិង្សា។ | ទេ! វាមិនមែនជាអំពើហិង្សាទេ។ |
| ខ្ញុំមិនប្រាកដទេ។ | |

**សេចក្តីណែនាំ ៖**

- បត់ក្រដាសផ្ទាំងធំជាបួនផ្នែកស្មើៗគ្នា។
- លាក្រដាសមកវិញ បន្ទាប់មកកាត់ទៅតាមស្នាមបត់ដើម្បីបង្កើតបណ្ណចម្លើយ។
- ប្រើតែពាសន្លឹកប៉ុណ្ណោះ។
- សរសេរឃ្លានៅក្នុងក្រដាសនីមួយៗដូចបង្ហាញខាងលើ។
- ធានាថាឃ្លាសរសេរបានធំ ច្បាស់ និងជិតល្អ ។
- បិទក្រដាសនៅលើជញ្ជាំងដាច់ៗពីគ្នានៅកន្លែងដែលទូលាយ និងងាយស្រួលដល់សិស្សចូលទៅឈរជិតចម្លើយនោះនៅពេលធ្វើសកម្មភាពនេះ*(ប្រសិនបើអាចធ្វើទៅបាន)* ឬនៅចម្ងាយប្រមាណជាមួយម៉ែត្រពីគ្នានៅលើជញ្ជាំងតែមួយ។

## ឯកសារអំណានទី១៣ ៖ រឿងទាំងបី ៖ តើវាជាអំពើហិង្សាដែរឬទេ?



### រឿងទី១ ៖ តើវាជាអំពើហិង្សាឬ?

លីណា និងគឹមសេន ទើបតែបានរៀបការនឹងគ្នាប៉ុន្មានខែប៉ុណ្ណោះ។ គឹមសេនធ្វើការនៅក្រៅទីក្រុងក្នុងរោងចក្រមួយ។ គាត់មានកាលវិភាគធ្វើការ១២ម៉ោង និងចេញទៅធ្វើការជារៀងរាល់ថ្ងៃនៅពេលព្រឹក និងត្រលប់មកផ្ទះវិញយឺត និងអស់កម្លាំងនៅពេលល្ងាច។ ជីវិតមានភាពរវល់មែនទែនសម្រាប់គាត់។

ថ្ងៃមួយ គឹមសេនត្រលប់មកពីធ្វើការវិញយឺតជាងធម្មតា។ គាត់ឱ្យ លីណា រៀបចំអាហារពេលល្ងាចឱ្យគាត់ឱ្យលឿន។ លីណា ក៏ប្រញាប់ប្រញាលរៀបចំអាហារពេលល្ងាចឱ្យបានរួចរាល់ ហើយក៏ភ្លេចដាក់អំបិលក្នុងម្ហូប។

គឹមសេនចាប់ផ្តើមហូបអាហារពេលល្ងាចរបស់គាត់។ ដោយដឹងថា ម្ហូបអាហារមិនមានបង់អំបិល គាត់ក៏ក្រោកឈរឡើង ហើយបានទះកំផ្លៀង លីណា។

### រឿងទី២ ៖ តើវាជាអំពើហិង្សាឬ?

សុដាពូកែលេងបាល់បោះខ្លាំងណាស់។ នាងគ្រោងពង្រឹងអាជីពរបស់នាងក្នុងវិស័យនេះ។

ឆ្នាំនេះ សុដា មានអាយុ១៨ឆ្នាំហើយ ហើយម្តាយនាងបានប្រាប់នាងឱ្យឈប់ទៅហាត់បាល់បោះ និងចាប់ផ្តើមជួយការងារផ្ទះបន្ថែម។ សុដា មិនបានប្រកែកក្នុងការជួយការងារផ្ទះម្តាយរបស់នាងទេ ប៉ុន្តែគ្រូបាល់បោះរបស់នាងមិនសប្បាយចិត្តទាល់តែសោះដែល សុដា មកហាត់បាល់មិនបានទៀងទាត់។ គាត់បាននិយាយជាមួយនាង និងបានឱ្យនាងសម្រេចចិត្តថាតើនាងពិតជាចង់បន្តហាត់តទៅទៀតដែរឬទេ។

សុដា ពិតជាចង់ហាត់បន្ត ដោយសារនេះជាបំណង និងក្តីសុបិនរបស់នាង ប៉ុន្តែគ្រួសារនាងកំពុងបញ្ចុះបញ្ចូលនាងឱ្យឈប់។ ពួកគាត់ប្រាប់នាងថា កីឡាបាល់បោះជាមុខរបរមិនមានអនាគតទេ ហើយឥឡូវនេះថា នាងមានអាយុ១៨ឆ្នាំហើយ ដែលនាងចាំបាច់ត្រូវចាប់ផ្តើមនៅផ្ទះឱ្យបានច្រើនសម្រាប់សេចក្តីល្អដល់គ្រួសារ ដល់នាងផ្ទាល់ និងប្អូនៗរបស់នាងដែរ។

**រឿងទី៣ ៖ តើវាជាអំពើហិង្សាឬ?**

ជារៀងរាល់ថ្ងៃ សុខា ទៅសាលាជាមួយមិត្តរបស់នាងឈ្មោះសុជាតា។ សុជាតា មិនស្រួលខ្លួនអស់រយៈពេលប៉ុន្មានថ្ងៃមកហើយ ដូច្នេះ សុខា ក៏បានដើរទៅសាលាដោយខ្លួនឯង។

សុខា បានកត់សម្គាល់ឃើញថា មានបុរស២នាក់កំពុងជិះកង់តាមនាងជារៀងរាល់ថ្ងៃនៅពេលនាងដើរទៅសាលារៀន។ នាងមិនរវល់នឹងពួកគេទេ ហើយដើរទៅសាលារៀនយ៉ាងលឿនជារៀងរាល់ថ្ងៃ។ ប៉ុន្តែថ្ងៃនេះ ពួកគេបានជិះតម្រង់មករកនាង ចាប់ទាញ «មួក» របស់នាង និងស្ទាបថ្ពាល់របស់នាង។ សុខា ភ័យខ្លាំងណាស់ ហើយមិនដឹងថាត្រូវធ្វើអ្វីទេ។

**សេចក្តីណែនាំ ៖**

– ថតចម្លងរឿងទាំងនេះមួយច្បាប់ដើម្បីប្រើជាឯកសារយោងនៅពេលអនុវត្តសកម្មភាពនេះ។ លោកគ្រូ អ្នកគ្រូក៏អាចយកសៀវភៅណែនាំរបស់លោកគ្រូ អ្នកគ្រូជំនួសបានដែរដោយយោងទៅលើទំព័រនេះ។

# មេរៀនទី៦ ៖ តើវាពិតដែរឬទេ?[5]

➲ **វត្ថុបំណងមេរៀន ៖**

- ដើម្បីរៀនពីរបៀបដែលអំពើហិង្សាលើស្ត្រីកើតឡើងនៅគ្រប់វណ្ណៈ ត្រកូល សាសនា និងវប្បធម៌។
- ដើម្បីអាចកំណត់ពីជំនឿមិនត្រឹមត្រូវជុំវិញអំពើហិង្សាទៅលើស្ត្រី។

🕘 **រយៈពេលមេរៀន ៖** ៤៥ នាទី

✉ **សារសំខាន់ៗ ៖**

១. អំពើហិង្សាអាចប៉ះពាល់ដល់មនុស្សគ្រប់រូប។ វាមិនកំណត់ចំពោះវណ្ណៈសង្គម ត្រកូល សាសនា ឬទីតាំងភូមិសាស្ត្រឡើយ។

២. ស្លាកស្នាមទុយ៌សនៃអាកប្បកិរិយារបស់ស្ត្រីក្នុងសង្គម ជារឿយៗធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះចំពោះការមិនរាប់រក និងទម្រង់ខុសៗគ្នានៃអំពើហិង្សាដែលធ្វើឱ្យវដ្តនៃអំពើហិង្សាកើតមានជាប់ជានិច្ច។

៣. វាមានសារៈសំខាន់ណាស់ដែលត្រូវស្គាល់ពីទម្រង់ខុសៗគ្នានៃអំពើហិង្សា និងមិនត្រូវចាត់ទុកវាថាជារឿងមិនធ្ងន់ធ្ងរទេដើម្បីធានាថាអ្នករស់រានមានជីវិតពីអំពើហិង្សាអាចព្យាបាលបាន។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាសA4ចំនួន២សន្លឹក ម៉ាស៊ីនថតចម្លង ក្តារខៀន ឬហ្វីត ឬដីស និងបន្ទាត់។

☞ សម្រាប់សិស្ស ៖ សន្លឹកក្រដាស A4 ចំនួន៨សន្លឹក សន្លឹកកិច្ចការក្នុងថ្នាក់ទំព័រទី៨៥ និងសម្ភារៈសរសេរ។

---

[5] ដកស្រង់ពីអ្នកបង្កើតការផ្លាស់ប្តូរ សំណុំឯកសារសម្រាប់សកម្មជនវ័យក្មេងសម្រាប់ការបញ្ចប់អំពើហិង្សាទៅលើស្ត្រី និងក្មេងស្រី - សូមមើលបន្ថែមនៅវែបសាយត៍៖ http://asiapacific.unwomen.org/en/digital-library/publications/2014/9/the-changemaker#sthash.Ac9tDT4q.dpuf

**ការរៀបចំទុកជាមុន ៖**

- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- អានឯកសារអំណានទី១៤ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។
- ថតចម្លង «សេចក្តីថ្លែងនៅលើក្រដាសតូចៗ ៖ ជំនឿជុំវិញអំពើហិង្សា» មួយច្បាប់ (សូមមើលឯកសារអំណានទី១៥ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។ កាត់ក្រដាសតាមបន្ទាត់ចុចៗដើម្បីឱ្យបានក្រដាសតូចៗចំនួន៨សន្លឹក។
- ថតចម្លងសន្លឹកឯកសារការពិតមួយច្បាប់ស្តីពី«ប្រភេទនៃការរើសអើងផ្នែកយេនឌ័រទាំង៧ដែលនាំឱ្យមានអំពើហិង្សាលើសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី» (សូមមើលឯកសារអំណានទី១៦នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ប្រមូលធនធានដែលត្រូវការទាំងអស់ផ្សេងទៀត។
- គូរតារាង «ជំនឿ និងការពិត» នៅលើក្តារខៀន (សូមមើលឯកសារអំណានទី១៧ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- សរសេរចំណងជើងមេរៀនដាក់នៅលើក្តារខៀន។

> **គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - រំឭកសិស្សឱ្យចុះវត្តមានរបស់ពួកគេនៅពេលពួកគេចូលក្នុងថ្នាក់រៀន។
> - ឱ្យសិស្ស ម្នាក់ៗប្រមូលសន្លឹកកិច្ចការរបស់ខ្លួន និងសម្ភារៈសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

### សេចក្តីណែនាំ

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល«អារម្មណ៍»សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- អាន និងចង្អុលចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្សទាយថា តើពីមេរៀនថ្ងៃនេះនឹងរៀនពីអ្វី? ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់គេជាមួយក្រុម។
- ប្រាប់សិស្សថា នៅក្នុងមេរៀននៅថ្ងៃនេះ ពួកគេនឹងពិភាក្សាពីជំនឿមួយចំនួនក្នុងចំណោមជំនឿទូទៅនានានៃអំពើហិង្សាលើស្ត្រី។

- បែងចែកសិស្សជា៨ក្រុម។ ចែកសេចក្ដីថ្លែងមួយសន្លឹក និងក្រដាសទំហំ A4 មួយសន្លឹកដល់ក្រុមនីមួយៗ។
- ផ្ដល់ការណែនាំដូចខាងក្រោម ៖
  - ក្រដាសតូចនីមួយៗមានសេចក្ដីថ្លែងមួយ។ ពិភាក្សានៅក្នុងក្រុមរបស់ប្អូនថាតើសេចក្ដីថ្លែងនៅក្នុងក្រដាសនោះឆ្លុះបញ្ចាំងពីទម្រង់មួយចំនួននៃ «អំពើហិង្សាទៅលើស្ត្រី» ដែរឬទេ។
  - ប្រសិនបើមាន ត្រូវធ្វើការជាក្រុមដើម្បីកែតម្រូវ«ជំនឿ»នេះ បន្ទាប់មកសរសេរដំណោះស្រាយរបស់ប្អូនដាក់នៅលើក្រដាសទំហំA4។ ប្រសិនបើមិនមាន ចូលបញ្ជាក់ហេតុផលសម្រាប់ចម្លើយរបស់ប្អូន។
  - ប្រាប់ពួកគេថា ពួកគេមានពេល ១០នាទីដើម្បីអនុវត្តសកម្មភាពនេះ។

## ៣. ការពង្រឹងចំណេះដឹង

- ក្រោយពីពិភាក្សាក្រុមតូចរួចហើយ ឱ្យក្រុមនីមួយៗបង្ហាញពី «ជំនឿដែលបានកែតម្រូវការពិតរបស់ខ្លួន» របស់ពួកគេ ឬចម្លើយផ្សេងទៀតដែលឆ្លុះបញ្ចាំងពីចម្លើយខុសគ្នា។
- ប្រាប់សិស្សឱ្យអានសេចក្ដីថ្លែងនៅលើក្រដាសជាមុនសិន ហើយបន្ទាប់មកចែករំលែកចម្លើយរបស់គេ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូ៖

- នៅពេលក្រុមនីមួយៗបង្ហាញ ប្រើតារាងដែលបានគូរនៅលើក្ដារខៀនដើម្បីកត់ទុក «ការពិត» ដោយធៀបជាមួយនឹង«ជំនឿ» ដែលត្រូវគ្នានីមួយៗ។
- ឱ្យសិស្សធ្វើតាមលោកគ្រូ អ្នកគ្រូ និងកត់ចម្លើយនៅក្នុងសន្លឹកកិច្ចការផ្ទាល់របស់គេម្នាក់ៗ ទំព័រទី១០។ សូមមើល «កិច្ចការក្នុងថ្នាក់» ដែលគេផ្ដល់ឱ្យខាងក្រោមសម្រាប់ជាការណែនាំ។

**កិច្ចការក្នុងថ្នាក់ ៖**

- មុនពេលចាប់ផ្ដើមធ្វើការបង្ហាញ ចូរផ្ដល់ការណែនាំដូចខាងក្រោម។
  - ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៨៥។
  - អានសេចក្ដីណែនាំនៅក្នុងសន្លឹកកិច្ចការ។ ឱ្យសិស្សធ្វើតាមលោកគ្រូ អ្នកគ្រូដើម្បីបំពេញ «ការពិត» ដោយប្រៀបធៀបនឹង «ជំនឿ» ដែលសមស្របដែលត្រូវគ្នានៅពេលលោកគ្រូ អ្នកគ្រូកត់ត្រាទុកការពិតទាំងនោះនៅលើក្ដារខៀន។

☞ ចាប់ការបង្ហាញ និងអនុវត្តតាមការណែនាំខាងក្រោម។
  - នៅពេលក្រុមនីមួយៗធ្វើបទបង្ហាញ កត់ត្រាទុក «ការពិត» ដោយប្រៀបធៀបជាមួយនឹង «ជំនឿ» នីមួយៗនៅលើក្តារខៀន។
  - ក្រោយពីក្រុមនីមួយៗ ធ្វើបទបង្ហាញរួចហើយ សួរក្រុមផ្សេងទៀតថាតើពួកគេមានសំណួរ ឬចំណុចបន្ថែមដែលពួកគេមានដែរឬទេ។ កត់បញ្ចូលចំណុចទាំងនោះទៅក្នុងតារាង ប្រសិនបើមាន។
  - ឱ្យសិស្សសរសេរចម្លើយដែលសមស្របដោយធៀបទៅនឹងជំនឿនីមួយៗដែលត្រូវគ្នានៅក្នុងសន្លឹកកិច្ចការរបស់ពួកគេ។

☞ ក្រោយពីធ្វើបទបង្ហាញទាំងអស់រួចហើយ ចែករំលែកដូចខាងក្រោម ៖
  - នៅពេលធ្វើបទបង្ហាញ ក្រុមចែករំលែកគំនិតរបស់ខ្លួនដោយផ្អែកលើការកំណត់របស់សង្គមទៅលើតួនាទីយេនឌ័រ និងផលប៉ះពាល់របស់វាលើតួនាទីរបស់ស្ត្រី និងការសម្រេចចិត្តដោយឯករាជ្យ។ ចំណុចទាំងនេះគឺជា «ជំនឿ» ទូទៅបំផុតដែលគេជឿជាក់ដែលធ្វើឱ្យតួនាទីនៃការរើសអើង និងអំពើហិង្សាផ្អែកយេនឌ័រមានជាប់ជានិច្ច។
  - គេអាចយល់ពីសេចក្តីថ្លែងនីមួយៗទៅតាមហេតុផល ប្រសិនបើយើងយល់ពីប្រយោគទាំងនោះថាជាលទ្ធផលនៃការបង្ខិតបង្ខំរបស់ប្រព័ន្ធបិតាធិបតេយ្យលើតួនាទីយេនឌ័រ។ ជារឿយៗគេបញ្ជាក់ថាសេចក្តីថ្លែងទាំងនោះមានលក្ខណៈសមស្របទៅនឹងអំពើហិង្សាផ្អែកយេនឌ័រ។

☞ អានឯកសារស្តីពីការពិតពីប្រភេទទាំង៧នៃការរើសអើងយេនឌ័រដែលនាំឱ្យមានការរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី (សូមមើលឯកសារអំណានទី១៦ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។

☞ សរុបមេរៀនដោយចែករំលែកចំណុចដូចខាងក្រោម ៖
  - ការពិតដាច់ខាតគឺថា អំពើហិង្សាអាចប៉ះពាល់ដល់មនុស្សគ្រប់រូប ហើយវាមិនមែនជារឿងស្របច្បាប់ទេ។
  - វាគឺជាបញ្ហាធ្ងន់ធ្ងរ ហើយគេអាច និងត្រូវតែបញ្ឈប់វាឱ្យបាន។
  - ទំនួលខុសត្រូវសម្រាប់ការបញ្ឈប់អំពើហិង្សាលើស្ត្រីគឺជាការទទួលខុសត្រូវរបស់មនុស្សគ្រប់រូប។
  - ជំនឿណាមួយដែលប្រាប់យើងពីអ្វីមួយដែលខុសចាំបាច់ត្រូវតែលុបបំបាត់ជំនឿនោះក្នុងសហគមន៍ និងប្រទេសនីមួយៗរបស់យើង។



# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី១៨ ៖ ឯកសារអំណានសម្រាប់គ្រូបង្រៀន

**បរិបទចំណេះដឹង**

- ការពិតដាច់ខាតគឺថា អំពើហិង្សាអាចប៉ះពាល់ដល់មនុស្សគ្រប់រូប ហើយវាមិនដែលស្របច្បាប់ទេ។ វាជាបញ្ហាធ្ងន់ធ្ងរដែលគេអាចនិងត្រូវតែបញ្ឈប់បាន ហើយការទទួលខុសត្រូវចំពោះការបញ្ចប់អំពើហិង្សាទៅលើស្ត្រី គឺជាកិច្ចការរបស់យើងគ្រប់គ្នា។
- បទដ្ឋានសង្គមដែលរងឥទ្ធិពលពីវប្បធម៌គួរតែត្រូវគិតគូរពិចារណាឡើងវិញចំពោះឥរិយាបថរើសអើងយេនឌ័រណាមួយដែលវាធ្វើឱ្យអំពើហិង្សានៅតែបន្តកើតឡើង។
- ការរើសអើងយេនឌ័រ និងអំពើហិង្សាលើស្ត្រី គឺជាបាតុភាពសកលមួយ។ ស្ត្រីម្នាក់ក្នុងចំណោមស្ត្រី៣នាក់បានរាយការណ៍ពីការឆ្លងកាត់ទម្រង់មួយចំនួននៃអំពើហិង្សានៅក្នុងជីវិតរបស់គេ។
- អំពើហិង្សាទៅលើស្ត្រីមិនត្រឹមតែប៉ះពាល់ដល់ស្ត្រីប៉ុណ្ណោះទេ វាក៏ប៉ះពាល់ដូចគ្នាទៅលើបុរសនិងតួនាទីរបស់គេនៅក្នុងសង្គមដែរ។
- ជំនឿទូទៅភាគច្រើនជុំវិញស្ត្រីបណ្ដាលឱ្យមានការខ្វះខាតការចូលរួមរបស់ស្ត្រីផ្នែកកម្លាំងពលកម្ម ការអប់រំ សុខភាព និងវិស័យផ្សេងៗទៀតដែលត្រូវចូលរួម។
- គេអាចកំណត់ពីភាពខុសគ្នាតែមួយគត់រវាងបុរស និងស្ត្រីបានតាមរយៈសរីរាង្គជីវសាស្ត្រដូចដែលយើងបានយល់នៅក្នុងម៉ូឌុលទី១។

## ឯកសារអំណានទី១៥ ៖ សេចក្តីថ្លែង ៖ ជំនឿជុំវិញអំពើហិង្សា

| | |
|---|---|
| **សេចក្តីថ្លែងទី១**<br>អំពើហិង្សា គឺជាបញ្ហាឯកជន ហើយគេមិនត្រូវពិភាក្សាវាជាមួយនរណាម្នាក់ក្រៅពីគ្រួសារឡើយ។ | **សេចក្តីថ្លែងទី២**<br>ស្ត្រីមិនពូកែគណិតវិទ្យាទេ ដូច្នេះគេមិនគួរសម្រេចចិត្តលើផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារឡើយ។ |
| **សេចក្តីថ្លែងទី៣**<br>បុរសដែលមានវណ្ណៈ និងកម្រិតអប់រំជាក់លាក់អាចប្រព្រឹត្តិអំពើហិង្សាបាន។ | **សេចក្តីថ្លែងទី៤**<br>ប្រសិនបើស្ត្រីផឹកស្រា ឬជក់បារី ពួកគេងាយទទួលរងការកេញចំណេញ និងការបៀតបៀនផ្លូវភេទ។ |
| **សេចក្តីថ្លែងទី៥**<br>អំពើហិង្សាទៅលើស្ត្រីកម្រមានណាស់ ហើយគ្មាននរណាម្នាក់ដែលខ្ញុំស្គាល់ទទួលរងផលប៉ះពាល់ពីអំពើហិង្សាទេ។ | **សេចក្តីថ្លែងទី៦**<br>ស្ត្រីគឺជាសត្រូវដ៏អាក្រក់បំផុតរបស់ស្ត្រីគ្នាឯង។ |
| **សេចក្តីថ្លែងទី៧**<br>អំពើហិង្សាលើស្ត្រីនៅក្នុងគ្រួសារមិនមានផលប៉ះពាល់ដល់កូនទេ។ | **សេចក្តីថ្លែងទី៨**<br>ជាធម្មជាតិ ស្ត្រីមានភាពទន់ខ្សោយ បើធៀបទៅនឹងបុរស។ |

**សេចក្តីណែនាំ ៖**

– ថតចម្លងឯកសារនេះមួយច្បាប់។
– កាត់សេចក្តីថ្លែងនីមួយៗតាមបន្ទាត់ចុចៗដើម្បីឱ្យបានសេចក្តីថ្លែងចំនួន៨សន្លឹក។
– យកវាតាមខ្លួនដើម្បីងាយស្រួលយកវាមកប្រើប្រាស់សម្រាប់សកម្មភាពនេះ។

## ឯកសារអំណានទី១៦ ៖ ឯកសារស្ដីពីការពិត

មានការរើសអើងផ្នែកយេនឌ័រចំនួន៧ប្រភេទដែលនាំឱ្យមានការរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី។ ការរើសអើងទាំងនោះមានដូចខាងក្រោម ៖

**វិសមភាពអត្រាមរណៈ** ៖ នៅក្នុងតំបន់មួយចំនួនក្នុងពិភពលោក វិសមភាពរវាងបុរស និងស្ត្រីមានពាក់ព័ន្ធដោយផ្ទាល់នឹងជីវិតរស់នៅ និងការស្លាប់ ព្រមទាំងមានទម្រង់ច្បាស់លាស់នៃអត្រាមរណៈខ្ពស់ខុសធម្មតារបស់ស្ត្រី និងផលវិបាកមួយដែលបុរសមានចំនួនច្រើនជាងស្ត្រីនៅក្នុងចំនួនប្រជាជនសរុប ដែលផ្ទុយពីការដែលស្ត្រីមានចំនួនច្រើនជាងដែលគេរកឃើញនៅក្នុងសង្គមជាច្រើនដែលមានភាពលម្អៀងយេនឌ័រតិចតួច ឬគ្មានសោះចំពោះការថែទាំសុខភាព និងអាហារូបត្ថម្ភ។ គេសង្កេតឃើញមានវិសមភាពអត្រាមរណៈយ៉ាងច្រើននៅអាហ្វ្រិកខាងជើង និងនៅទ្វីបអាស៊ីរួមមានប្រទេសចិន និងអាស៊ីខាងត្បូងដែរ។

**វិសមភាពអត្រាកំណើត** ៖ ដោយសារការចង់បានកូនប្រុសជាងកូនស្រីដែលសង្គមយកប្រុសជាធំជាច្រើនមាន វិសមភាពយេនឌ័រអាចបង្ហាញយ៉ាងច្បាស់ក្នុងទម្រង់ដែលមានឪពុកម្ដាយចង់បានកូនប្រុសជាងកូនស្រី។ ដោយសារមានបច្ចេកវិទ្យាទំនើបក្នុងការកំណត់យេនឌ័ររបស់គភ៌ ការជ្រើសរើសការរំលូតកូនតាមភេទបានក្លាយទៅជារឿងធម្មតានៅក្នុងប្រទេសជាច្រើន។ ជាពិសេសអត្រាទូទៅនៅក្នុងរដ្ឋ Haryana, Punjab និងផ្នែកផ្សេងទៀតនៃប្រទេសឥណ្ឌា។ នេះគឺជាភេទនិយមតាមបច្ចេកវិទ្យាទំនើប។

**វិសមភាពផ្នែកសិទ្ធិជាមូលដ្ឋាន** ៖ សូម្បីតែនៅពេលលក្ខណៈប្រជាសាស្ត្រមិនបានបង្ហាញច្រើន ឬការលម្អៀងប្រឆាំងនឹងស្ត្រីក៏ដោយ ក៏មានវិធីផ្សេងទៀតដែលស្ត្រីអាចប្រឈមនឹងវិសមភាពដែរ។ ប្រទេសអាហ្គានីស្ថានអាចជាប្រទេសតែមួយគត់ក្នុងពិភពលោកដែលរដ្ឋាភិបាលមានចេតនាមុតមាំក្នុងការមិនឱ្យក្មេងស្រីទៅសាលារៀន។ ទោះជាយ៉ាងនេះក្តី មានប្រទេសជាច្រើននៅអាស៊ី និងអាហ្វ្រិក ក៏ដូចជាអាមេរិកឡាទីនដែរដែលក្មេងស្រីមានឱកាសតិចជាងក្មេងប្រុសច្រើនណាស់ក្នុងការចុះឈ្មោះចូលរៀន។ នៅប្រទេសកម្ពុជា កង្វះហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗផ្នែកយេនឌ័រជាពិសេសសម្រាប់ក្មេងស្រីវ័យជំទង់នាំឱ្យមានអត្រាបោះបង់ការសិក្សាខ្ពស់ក្រោយពីក្មេងស្រីចូលដល់ភាពពេញវ័យគ្រប់ការ។ មានឱនភាពផ្សេងទៀតចំពោះសិទ្ធិមូលដ្ឋានដែលមានសម្រាប់ស្ត្រី ដែលមានចាប់ពីការលើកទឹកចិត្តរហូតដល់ការអភិវឌ្ឍទេពកោសល្យពីធម្មជាតិរបស់ស្ត្រីក្នុងការចូលរួមប្រកបដោយយុត្តិធម៌នៅក្នុងការផ្តល់រង្វាន់ចំពោះតួនាទីក្នុងសង្គមនៅក្នុងសហគមន៍។

**វិសមភាពឱកាសពិសេស** ៖ ទោះបីជាមានភាពខុសគ្នាតិចតួចបំផុតក៏ដោយចំពោះសិទ្ធិមូលដ្ឋាននានារួមទាំងការចុះឈ្មោះចូលរៀន ឱកាសទទួលបានការអប់រំខ្ពស់អាចមានតិចសម្រាប់ស្ត្រីវ័យក្មេងជាងបុរស

វ័យក្មេង។ សិទ្ធិទទួលបានវគ្គបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ស្ត្រីក៏មានកម្រិតខ្លាំងដែរ ហើយក៏មានការខ្វះខាតនូវលទ្ធភាពធ្វើឱ្យមានការរីកចម្រើននៅថ្ងៃអនាគតចំពោះផ្នែកនីមួយៗដែរ។

**វិសមភាពវិជ្ជាជីវៈ** ៖ ចំពោះការងារ និងការឡើងឋានៈនៅក្នុងការងារ និងមុខរបរ ជារឿយៗ ស្ត្រីប្រឈមនឹងឧបសគ្គច្រើនជាងបុរស។ ការចូលរួមជាកម្លាំងពលកម្មរបស់ស្ត្រីជាពិសេសនៅក្នុងវិស័យដែលមានលក្ខណៈរៀបរយមានកម្រិតក្នុងការទទួលបានការងារជួរមុខ ហើយគេរកឃើញថាលទ្ធភាពនៃការឡើងឋានៈមានភាពលម្អៀងខ្លាំងទៅរកបុរស។

**វិសមភាពភាពជាម្ចាស់** ៖ នៅក្នុងសង្គមជាច្រើន ភាពជាម្ចាស់លើទ្រព្យសម្បត្តិក៏អាចមានវិសមភាពច្រើនដែរ។ អចលនទ្រព្យដូចជាផ្ទះ និងដីមិនទទួលបានការបែងចែកស្មើគ្នាទេ។ ការមិនមានការទាមទារលើទ្រព្យសម្បត្តិមិនត្រឹមតែអាចកាត់បន្ថយសំឡេងស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យស្ត្រីមានការលំបាកកាន់តែច្រើនក្នុងការចូល និងការទទួលជោគជ័យលើសកម្មភាពផ្នែកពាណិជ្ជកម្ម សេដ្ឋកិច្ច និងសូម្បីតែសកម្មភាពសង្គមមួយចំនួន។[2] ប្រភេទនៃវិសមភាពនេះកើតមានឡើងក្នុងផ្នែកជាច្រើននៃពិភពលោក។

**វិសមភាពនៅក្នុងគ្រួសារ** ៖ ជារឿយៗ មានវិសមភាពមូលដ្ឋានចំពោះទំនាក់ទំនងយេនឌ័រនៅក្នុងគ្រួសារ ឬនៅក្នុងផ្ទះដែលអាចមានទម្រង់ខុសៗគ្នាជាច្រើន។ ទោះបីនៅក្នុងករណីផ្សេងៗដែលមិនមានសញ្ញាលាក់បាំងពីការលម្អៀងប្រឆាំងនឹងស្ត្រីក៏ដោយ ក៏ការរស់រាន ឬការចង់បានកូនប្រុស ឬការអប់រំ ឬសូម្បីនៅក្នុងការដំឡើងឋានៈលើមុខតំណែងផ្នែកប្រតិបត្តិកាន់តែខ្ពស់ ការរៀបចំក្នុងគ្រួសារអាចមិនស្មើគ្នាចំពោះការចែករំលែកបន្ទុកគ្រួសារ និងការថែទាំកូន។ ឧទាហរណ៍ វាមានលក្ខណៈទូទៅបំផុតនៅក្នុងសង្គមជាច្រើនក្នុងការគិតពិចារណាថានៅពេលដែលបុរសត្រូវចេញទៅធ្វើការនៅខាងក្រៅផ្ទះ ស្ត្រីអាចក៏អាចធ្វើបានដែរ ប្រសិនណាបើពួកគេអាចរួមបញ្ចូលការងារទាំងនោះជាមួយការងារផ្ទះដែលត្រូវតែធ្វើដោយមិនអាចចៀសផុតបាន។ ពេលខ្លះ គេហៅចំណុចនេះថា «ការបែងចែកការងារ» ទោះបីជាគេអាចលើកលែងទោសឱ្យស្ត្រី ដោយសារការមើលឃើញវាជា «ការងារបន្ថែម»។ ការមានវិសមភាពនេះមិនត្រឹមតែមានចំពោះការទំនាក់ទំនងមិនស្មើភាពគ្នានៅក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្កើតឱ្យមានវិសមភាពនៅក្នុងការងារ និងការទទួលស្គាល់នៅក្នុងពិភពខាងក្រៅដែរ។ ជាមួយគ្នានេះដែរ ការមិនប្រែប្រួលដែលបានបង្កើតចំពោះប្រភេទនៃ «ការបែងចែក» ឬ «ការបន្ថែម» ការងារនេះក៏អាចមានផលប៉ះពាល់ខ្លាំងលើចំណេះដឹង និងការយល់ពីប្រភេទខុសៗគ្នានៃការងារនៅក្នុងវដ្តវិជ្ជាជីវៈ។

ការប្រឈមជាច្រើននៃវិសមភាពយេនឌ័រ Amartya Sen; Frontline, Volume 18 – Issue ២២, តុលា២៧ -វិច្ឆិការ. ០៩, ២០០១

**សេចក្តីណែនាំ ៖**

- ថតចម្លងឯកសារនេះមួយច្បាប់ដើម្បីប្រើនៅពេលអនុវត្តសកម្មភាពនេះ។ ជាជម្រើស លោកគ្រូ អ្នកគ្រូ អាចយកសៀវភៅណែនាំរបស់លោគ្រូ អ្នកគ្រូជំនួសបានដែរ ដោយយោងទៅលើទំព័រនេះ។

## ឯកសារអំណានទី១៧ ៖ តំរូតារាង ៖ ជំនឿ និងការពិត

| កូឡោនទី១ ៖ ជំនឿ | កូឡោនទី២ ៖ ការពិត |
|---|---|
| ១. អំពើហិង្សា គឺជាបញ្ហាឯកជន ហើយគេមិនត្រូវពិភាក្សាវាជាមួយនរណាម្នាក់ក្រៅពីគ្រួសារឡើយ។ | |
| ២. ស្ត្រីមិនពូកែគណិតវិទ្យាទេ ដូច្នេះគេមិនគួរសម្រេចចិត្តលើផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារឡើយ។ | |
| ៣. បុរសដែលមានវណ្ណៈ និងកម្រិតអប់រំជាក់លាក់អាចប្រព្រឹត្តិអំពើហិង្សាបាន។ | |
| ៤. ប្រសិនបើស្ត្រីផឹកស្រា ឬជក់បារី ពួកគេងាយទទួលរងការកេញចំណេញ និងការបៀតបៀនផ្លូវភេទ។ | |
| ៥. អំពើហិង្សាទៅលើស្ត្រីកម្រមានណាស់ ហើយគ្មាននរណាម្នាក់ដែលខ្ញុំស្គាល់ទទួលរងផលប៉ះពាល់ពីអំពើហិង្សាទេ។ | |
| ៦. ស្ត្រីគឺជាសត្រូវដ៏អាក្រក់បំផុតរបស់ស្ត្រីគ្នាឯង។ | |
| ៧. អំពើហិង្សាលើស្ត្រីនៅក្នុងគ្រួសារមិនមានផលប៉ះពាល់ដល់កូនទេ។ | |
| ៨. ជាធម្មជាតិ ស្ត្រីមានភាពទន់ខ្សោយ បើធៀបទៅនឹងបុរស។ | |

**សេចក្ដីណែនាំ ៖**

- ប្រើក្ដារខៀននៅក្នុងថ្នាក់រៀន និងគូរតារាងដែលបង្ហាញខាងលើ។
- គូរកូឡោនចំនួន២ និងជួរដេកចំនួន៩ដូចដែលបានបង្ហាញខាងលើ។
- ធានាថាជួរដេកនីមួយៗមានទំហំធំល្មមសម្រាប់សរសេរចម្លើយមួយចំនួនពីក្រុមនីមួយៗនៅក្នុងកូឡោនទី២។
- សរសេរចំណងជើង «ជំនឿ» និង «ការពិត» នៅក្នុងជួរឈរទី១ក្នុងកូឡោននីមួយៗ។
- សរសេរជំនឿទាំង៨ក្នុងជួរដេកនីមួយៗក្នុងកូឡោនទី១១។
- ធានាថា អក្សរសរសេរបានធំ និងច្បាស់ល្អ។

**គន្លឹះសម្រាប់គ្រូបង្រៀន** ៖ កូឡោនទី២នឹងត្រូវបំពេញនៅពេលក្រុមឆ្លើយពេលអនុវត្តសកម្មភាពនេះ។

# មេរៀនទី៧ ៖ ការផ្លាស់ប្តូរដែលយើងចង់ឃើញ

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីឱ្យសិស្សមានលទ្ធភាពមើលឃើញពីយេនឌ័រ យុត្តិធម៌សង្គម និងសមភាពសង្គម។

**រយៈពេលមេរៀន ៖** ៤៥ នាទី

**សារសំខាន់ៗ ៖**

១. មនុស្សគ្រប់រូបមានការទទួលខុសត្រូវចំពោះការធ្វើឱ្យមានការផ្លាស់ប្តូរក្នុងសង្គម! មនុស្សគ្រប់រូបមានតួនាទីមួយដែលត្រូវអនុវត្តទោះបីជាតាមរយៈការនិយាយពីអំពើហិង្សា ការលើកកម្ពស់ការយល់ដឹង ឬការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរនៅកម្រិតណាមួយ។

២. ការផ្លាស់ប្តូរសង្គមគឺជាសរីរាង្គមួយ ប៉ុន្តែ វាជាដំណើរការដែលចាំបាច់សម្រាប់សង្គមណាមួយក្នុងការអភិវឌ្ឍ និងធ្វើឱ្យមានវឌ្ឍនៈភាព។ មនុស្សម្នាក់ចាំបាច់ត្រូវចាប់ផ្តើមផ្លាស់ប្តូរដោយទទួលស្គាល់អត្រាទូទៅនៃអំពើហិង្សាចំពោះខ្លួនគេ និងនៅជុំវិញខ្លួនគេ។

## ១. ការរៀបចំ

**សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូបង្រៀន ៖ ក្តារខៀនហ្វឺត ឬដីស និងក្រដាសពណ៌សម្រាប់បិទចំណាំខុសគ្នា ២-៣ ដុំ។

☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការ កិច្ចការផ្ទះទំព័រទី៨៦ សម្ភារៈសរសេរ*(មួយក្នុងមួយក្រុម)*។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ ប្រមូលសម្ភារៈដែលត្រូវការទាំងអស់ផ្សេងទៀត។

☞ សរសេរចំណងជើងមេរៀនដាក់នៅលើក្តារខៀន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សឱ្យចុះវត្តមាន នៅពេលពួកគេចូលថ្នាក់រៀន។
- ឱ្យសិស្សម្នាក់ៗប្រមូលសន្លឹកកិច្ចការរបស់ពួកគេ និងសម្ភារៈសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

### សេចក្តីណែនាំ

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល«អារម្មណ៍»សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះនឹងបញ្ចប់ម៉ូឌុលទី២ ៖ ស្វ័យប្រសិទ្ធភាព។
- អាន និងចង្អុលចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះនឹងរៀនពីអ្វី ហើយបន្ទាប់មកឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុម។
- ប្រាប់សិស្សថា ថ្ងៃនេះពួកគេនឹងចូលរួមក្នុងសកម្មភាពមួយដែលលើកទឹកចិត្តឱ្យមានការច្នៃប្រឌិត និងមានភាពរីករាយ នៅពេលបូកសរុបការសិក្សារៀនសូត្រ និងការយល់ដឹងរបស់គេចំពោះម៉ូឌុលទី២។
- បែងចែកសិស្សជាក្រុមដែលមួយក្រុមមានគ្នាចំនួន១០នាក់។ ចែកក្រដាសបិទចំណាំពណ៌ខុសគ្នាដល់ក្រុមនីមួយៗ។
- សួរក្រុមនូវសំណួរដូចខាងក្រោម ៖
  - ប្រសិនបើប្អូនមានឱកាស តើប្អូនចង់ផ្លាស់ប្តូរអ្វីមួយដែលមាននៅក្នុងរចនាសម្ព័ន្ធសង្គមដែលគ្រប់គ្រងស្ត្រី និងបុរស ព្រមទាំងទម្រង់អាកប្បកិរិយារបស់គេដែរឬទេ?
  - ផ្តល់ពេលវេលាចំនួន១០នាទីដើម្បីបំផុសគំនិតនៅក្នុងក្រុមរបស់គេ។ ប្រាប់សិស្សឱ្យសរសេរ«គំនិតសម្រាប់ការផ្លាស់ប្តូរ»មួយដាក់នៅក្នុងក្រដាសបិទចំណាំ។
- ឱ្យសិស្សចូលក្នុងក្រុមធំមួយវិញ បន្ទាប់មកឱ្យសិស្សម្នាក់មកពីក្រុមនីមួយៗឡើងមកចែករំលែកទស្សនៈ និងគំនិតរបស់ក្រុមខ្លួន។

> **គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - នៅពេលក្រុមចែករំលែកគំនិត ប្រមូលក្រដាសបិទចំណាំរបស់ពួកគេ។ ផ្តុំគំនិតដែលដូចគ្នារបស់ក្រុមទាំងអស់ជាមួយគ្នាដោយបិទក្រដាសបិទចំណាំនៅលើក្តារខៀន ឬនៅជញ្ជាំងខាងមុខរបស់ថ្នាក់រៀន។

- ប្រាប់សិស្សថា ពួកគេនឹងចូលរួមទាំងអស់គ្នានៅក្នុងសកម្មភាពនៃការច្នៃប្រឌិតមួយដែលគេហៅថា «រូបចម្លាក់មានជីវិត»។ ពន្យល់ដូចខាងក្រោម ៖

រូបចម្លាក់មានជីវិត - នេះគឺជាវិធីសាស្រ្តក្នុងការបង្ហាញពីគោលគំនិតណាមួយតាមវិធីដែលអាចមើលឃើញជាជាងការប្រើពាក្យសម្តី។ សិស្សម្នាក់ ឬច្រើននាក់ធ្វើជាជាងឆ្លាក់ និងរៀបចំអ្នកផ្សេងទៀតឱ្យតំណាងនូវគំនិតដែលមានលក្ខណៈជាទិដ្ឋភាពមួយ ឬរូបភាពមួយ។ បន្ទាប់មកឱ្យសិស្សប្តូរវេនគ្នាធ្វើជាជាងឆ្លាក់ និងផ្លាស់ប្តូររូបចម្លាក់រហូតទាល់តែវាតំណាងឱ្យគំនិតទាំងអស់។

**ជុំទី១**

☞ ឱ្យសិស្សស្ម័គ្រចិត្តពី៣-៥នាក់ដើម្បីចាប់ផ្តើមរៀបចំរូបចម្លាក់មនុស្សដែលបង្ហាញពីសង្គមបច្ចុប្បន្ន។

**ជុំទី២**

☞ នៅពេលធ្វើរួច ចាប់ផ្តើមជុំទី២។

☞ ឱ្យសិស្សនៅក្នុងថ្នាក់បន្ថែមសមាសធាតុថ្មីៗដែលពួកគេចង់ផ្លាស់ប្តូរនៅក្នុងសង្គម។ ប្រាប់ពួកគេថា ពួកគេអាចដាក់បញ្ចូលអារម្មណ៍ផ្សេងៗស្តីពីរបៀបដែលពួកគេមានអារម្មណ៍ចំពោះការផ្លាស់ប្តូរទាំងនោះដែរ។

☞ ឱ្យពេល ១០នាទីដល់ក្រុមដើម្បីបញ្ចប់ការរៀបចំ «រូបចម្លាក់មានជីវិត» របស់ពួកគេ។

> **គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - លើកទឹកចិត្តសិស្សនៅក្នុងថ្នាក់ឱ្យបន្ថែមទម្រង់ថ្មីទៀតទៅលើរូបចម្លាក់របស់សិស្សស្ម័គ្រចិត្ត។ ឱ្យសិស្សផ្សេងទៀតផ្តល់គំនិត និងជួយពួកគេតាមរយៈការផ្តល់ការគាំទ្រ។

☞ អបអរសាទរសិស្សនៅក្នុងថ្នាក់សម្រាប់ជាងឆ្លាក់ដែលពោរពេញទៅដោយភាពច្នៃប្រឌិតរបស់ខ្លួន បន្ទាប់មកនិយាយថា ពួកគេបានក្លាយជា «អ្នករៀបចំពិភពលោកថ្មីមួយ»។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា**

☞ ប្រមូលផ្តុំគ្នាវិញដើម្បីពិភាក្សាជាក្រុមរួម។

☞ សួរសំណួរដូចខាងក្រោម ៖

- តើប្អូនមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលធ្វើលំហាត់នេះ?
- តើនរណាដែលប្អូនគិតថា ទទួលខុសត្រូវចំពោះការនាំឱ្យមានការផ្លាស់ប្តូរទាំងនេះនៅក្នុងសង្គមរបស់យើង?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចខាងក្រោម ៖

- មនុស្សគ្រប់រូបមានការទទួលខុសត្រូវចំពោះការនាំមកនូវការផ្លាស់ប្តូរនានានៅក្នុងសង្គម!
- អំពើហិង្សាប៉ះពាល់ដល់មនុស្សគ្រប់រូបនៅក្នុងសហគមន៍រួមមានកុមារ ឪពុកម្តាយ គ្រូ មន្ត្រីរដ្ឋាភិបាល និងយុវជន។
- មនុស្សគ្រប់រូបមានតួនាទីដែលត្រូវអនុវត្តទោះបីជាតាមរយៈការនិយាយពីអំពើហិង្សា ការលើកកម្ពស់ការយល់ដឹង ឬការតស៊ូមតិឱ្យមានការផ្លាស់ប្តូរនៅកម្រិតណាមួយក្តី។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើប្អូនគិតថា ការផ្លាស់ប្តូរអាចធ្វើទៅបានដែរឬទេ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចខាងក្រោម ៖

- ការរើសអើងផ្នែកយេនឌ័រគឺជាបាតុភាពសកល។
- ការរើសអើងយេនឌ័រកាន់តែមានភាពច្បាស់លាស់តាមរយៈស្ថាប័នសង្គមខុសៗគ្នាទៅតាមបទដ្ឋាន និងការប្រតិបត្តិផ្នែករប្បធម៌។ ទោះជាយ៉ាងនេះក្តី ស្ថានភាពនៅក្នុងសង្គមបានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនបន្តិចម្តងៗអស់រយៈពេលជាច្រើនឆ្នាំ។ បច្ចុប្បន្ននេះ ស្ត្រីកំពុងបំបែកភាពស្ងៀមស្ងាត់របស់ខ្លួន។ ក្មេងស្រីកាន់តែច្រើនបានទទួលការអប់រំ ហើយស្ថិតិបានបង្ហាញយើងថា ចំនួនក្មេងស្រីយ៉ាងច្រើនកំពុងចុះឈ្មោះចូលរៀន។
- ឥឡូវនេះ ជម្រើសការងារនានាបានបើកចំហចំពោះគំនិតរបស់ស្ត្រីក្នុងការចូលរួមក្នុងវិស័យខុសៗគ្នា។
- ការផ្លាស់ប្តូរសង្គមគឺជាសរីរាង្គមួយ ប៉ុន្តែ វាជាដំណើរការចាំបាច់សម្រាប់សង្គមណាមួយក្នុងការអភិវឌ្ឍ និងវឌ្ឍនៈភាព។ មនុស្សចាំបាច់ត្រូវចាប់ផ្តើមផ្លាស់ប្តូរដោយការទទួលស្គាល់អត្រាទូទៅនៃអំពើហិង្សាចំពោះខ្លួន និងនៅជុំវិញខ្លួន។

☞ សួរសំណួរដូចខាងក្រោម ៖

◈ ហេតុអ្វីបានជាប្អូនគិតថា វាមានសារៈសំខាន់ដែលត្រូវផ្លាស់ប្តូរ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចខាងក្រោម ៖

- យើងទាំងអស់គ្នាមានតួនាទីមួយដែលត្រូវអនុវត្តឆ្ពោះទៅរកការផ្លាស់ប្តូរសង្គមនេះ។
- ពេលខ្លះ យើងស្ទាក់ស្ទើរក្នុងការទទួលស្គាល់ទង្វើនៃអំពើហិង្សានៅក្នុងជីវិត និងទំនាក់ទំនងផ្ទាល់របស់យើង ហើយវាធ្វើឱ្យមានភាពងាយរងគ្រោះបន្ថែមទៀតជាប់ជាប្រចាំ។
- សង្គមត្រូវធានាបរិយាកាសអនុគ្រោះមួយសម្រាប់ស្ត្រី និងក្មេងស្រីដើម្បីស្វែងរកសំណងនិងយុត្តិធម៌ក្នុងករណីអំពើហិង្សាទៅលើស្ត្រី។ ទោះជាយ៉ាងណាក៏ដោយគេត្រូវអនុវត្តវិធានការបង្ការមួយចំនួនលើសពីវិធានការនៃការមានប្រតិកម្មធម្មតាដែលគេផ្តល់ឱ្យជារឿយៗ

បន្ទាប់ពីកើតមានអំពើហិង្សាមក។ នៅក្នុងដំណើរការនៃការទាមទារឱ្យមានការផ្លាស់ប្តូរ និងសិទ្ធិផ្ទាល់របស់មនុស្សម្នាក់ មានហានិភ័យ និងការវិវាទជាច្រើនដែលមនុស្សម្នាក់អាចត្រូវប្រឈមមុខ និងដោះស្រាយវា។ ទោះជាយ៉ាងនេះក្តី ដោយមានការគ្រប់គ្រងប្រកបដោយភាពជឿជាក់ និងការជៀសវាងការក្លាយជាជនរងគ្រោះ មនុស្សម្នាក់អាចចេញមកធ្វើជាបុគ្គលដែលរឹងមាំដែលអាចទាមទារសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួនបាន។

- ប្រសិនបើមានពេល បូកសរុបសារសំខាន់ៗពីមេរៀននេះឱ្យបានឆាប់រហ័ស។

កិច្ចការផ្ទះ

**កិច្ចការផ្ទះ**

- មុនពេលសិស្សបំបែកគ្នា ចំណាយពេល៥នាទីពន្យល់ពីកិច្ចការផ្ទះដល់ពួកគេ។
- ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៨៦។
- ប្រាប់សិស្សថា ពួកគេត្រូវធ្វើសន្លឹកកិច្ចការនេះដោយខ្លួនឯងនៅផ្ទះ។
- អានសេចក្តីណែនាំ បន្ទាប់មកពន្យល់ពីអ្វីដែលសិស្សត្រូវធ្វើ។
- រំឭកសិស្សពីសារៈសំខាន់នៃការយកសន្លឹកកិច្ចការរបស់ខ្លួនមកវិញនៅម៉ោងរៀនក្រោយ។

# ឧបសម្ព័ន្ធទី១

## សន្លឹកកិច្ចការសិស្ស

# សន្លឹកកិច្ចការកម្មវិធីសិក្សា ៖ តើត្រូវស្វែងរកនៅកន្លែងណា?

| ផ្នែកនៃការផ្ដល់ភាពអង់អាចៈ ម៉ូឌុល២ ស្វ័យប្រសិទ្ធភាព | | | | |
|---|---|---|---|---|
| ជំពូក | កូដមេរៀន និងសន្លឹកកិច្ចការ | ចំណងជើងមេរៀន | ចំណងជើងសន្លឹកកិច្ចការ | ទំព័រ |
| 1. ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព | | | | 76-77 |
| | ជំពូកទី១៖ មេរៀនទី៣ | យេនឌ័រ និងការប្រាស្រ័យទាក់ទង | ការកំណត់ពីរបៀបនៃការប្រាស្រ័យទាក់ទង ៖ ស្ត្រី និង បុរស | 78 |
| | ជំពូកទី១៖ មេរៀនទី៣ | យេនឌ័រ និងការប្រាស្រ័យទាក់ទង | គន្លឹះស្ដីពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ៖ សន្លឹកកិច្ចការស្ដីពីចំណេះដឹងរបស់សិស្ស | 79 |
| | ជំពូកទី១៖ មេរៀនទី៣ | យេនឌ័រ និងការប្រាស្រ័យទាក់ទង | ឧបសគ្គក្នុងការនិយាយ | 80 |
| 2. ទំនាក់ទំនងល្អ | | | | 81 |
| | ជំពូកទី២៖ មេរៀនទី៤ | តើនរណាជាអ្នកមានអំណាច? | ក្រោកឈរដើម្បីខ្លួនឯង | 82-83 |
| 3. ការយល់ដឹងពីហិង្សា | | | | 84 |
| | ជំពូកទី៣៖ មេរៀនទី៦ | តើវាពិតដែរឬទេ? | ជំនឿ និងការពិត | 85 |
| | ជំពូកទី៣៖ មេរៀនទី៧ | ការផ្លាស់ប្ដូរដែលយើងចង់ឃើញ | គំនិតរបស់ខ្ញុំ | 86 |

# ជំពូកទី១ ៖ ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

**ទិដ្ឋភាពទូទៅ**

នៅពេលយើងគិតពិចារណាពីពាក្យថា "ការប្រាស្រ័យទាក់ទង" ជារឿយៗ យើងតែងតែគិតថា ពាក្យនេះសំដៅទៅលើសកម្មភាពនៃការនិយាយដើម្បីបញ្ជូនសារមួយទៅកាន់មនុស្សម្នាក់ ឬច្រើននាក់។ ប៉ុន្តែ ការប្រាស្រ័យទាក់ទងមានន័យលើសពីនេះទៅទៀត។ ការប្រាស្រ័យទាក់ទង គឺជាការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវការគិត គំនិត ឬអារម្មណ៍ ហើយគេអាចធ្វើការប្រាស្រ័យទាក់ទងបានតាមវិធីជាច្រើន (ដូចជា តាមរយៈពាក្យសម្តី ឬភាសាកាយវិកា ឬអត្ថបទជាដើម)។

ការប្រាស្រ័យទាក់ទងបង្កើតបានជាមូលដ្ឋាននៃការទំនាក់ទំនង(អន្តរកម្ម)ទាំងអស់របស់យើង ហើយវាគឺជាជំនាញដ៏សំខាន់មួយដែលកំណត់ពីរបៀបដែលយើងបង្ហាញពីខ្លួនឯង ការគិត អារម្មណ៍ តម្រូវការ និងបំណងប្រាថ្នារបស់យើងចំពោះពិភពខាងក្រៅ។ ការប្រាស្រ័យទាក់ទងក៏បង្កើតបានជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហា និងការចរចាប្រកបដោយប្រសិទ្ធភាពផងដែរ។ របៀបដែលយើងជ្រើសរើសការប្រាស្រ័យទាក់ទង ឬរបៀបដែលគេបង្រៀនយើងពីការប្រាស្រ័យទាក់ទង ជារឿយៗ ក៏ត្រូវបានកំណត់ដោយសង្គមភាវូបនីយកម្ម(ការរៀនពីសង្គម) បទដ្ឋានយេនឌ័រទូទៅ ព្រមទាំងបរិបទផ្នែកវប្បធម៌ និងសង្គមផ្ទាល់ខ្លួនរបស់យើងម្នាក់ៗដែរ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារគេអាចកំណត់ការប្រាស្រ័យទាក់ទងទៅតាមលក្ខណៈយេនឌ័រ យើងអាចអភិវឌ្ឍជំនាញឱ្យកាន់តែរឹងមាំថែមទៀតដើម្បីធ្វើឱ្យមធ្យោបាយដែលយើងប្រើប្រាស់ក្នុងការប្រាស្រ័យទាក់ទងកាន់តែមានប្រសិទ្ធភាព។

មេរៀនទី១ស្តីពី "ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព" ក្នុងម៉ូឌុល២ ៖ ស្វ័យប្រសិទ្ធភាពនេះ នឹងផ្តោតលើការជួយក្មេងស្រីពេញវ័យជំទង់ឱ្យកសាងនូវជំនាញនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមូលដ្ឋានដែលរាប់បញ្ចូលទាំងការរៀនសូត្រពី ៖

- មូលហេតុដែលការប្រាស្រ័យទាក់ទងមានសារៈសំខាន់ក្នុងជីវិតរស់នៅ។
- របៀបដែលការប្រាស្រ័យទាក់ទងតែងទទួលរងឥទ្ធិពលពីកត្តាផ្សេងៗរបស់សង្គម។
- របៀបដែលអំណាច និងយេនឌ័រដើរតួនាទីនៅក្នុងមធ្យោបាយដែលយើងប្រាស្រ័យទាក់ទង។

## ជំពូកទី១៖ លទ្ធផលសិក្សា

***ជំពូកនេះនឹងជួយសិស្សឱ្យ ៖***

| |
|---|
| ១. ទទួលបានការយល់ដឹងពីការសន្ទត់ និងសមាសធាតុនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ |
| ២. អាចយល់ដឹងពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងការរស់នៅប្រចាំថ្ងៃរបស់គេ។ |
| ៣. សិក្សារៀនសូត្រពីរបៀបដែលការកំណត់ផ្នែកយេនឌ័រ និងអំណាចពេលខ្លះអាចជះឥទ្ធិពល និងរាំងដល់ជំនាញប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងរបៀបដែលគេអាចជម្នះឧបសគ្គទាំងនេះបាន។ |
| ៤. អាចបង្ហាញ(ប្រាប់)គ្រួសារ និងសហគមន៍របស់ខ្លួនឱ្យដឹងច្បាស់លាស់ពីតម្រូវការ និងបំណងប្រាថ្នារបស់ខ្លួនក្នុងលក្ខណៈមួយដែលមានភាពច្បាស់លាស់ ជឿជាក់ និងពេញលេញ ។ |

# ការកំណត់របៀបទំនាក់ទំនង ៖ ស្ត្រី និងបុរស

## យេនឌ័រ និងការប្រាស្រ័យទាក់ទង

សេចក្តីណែនាំ ៖

- ចូរអានឃ្លានៅក្នុងកូឡោនទី១ដែលមានបញ្ជាក់ពីផ្នែកមួយចំនួនសម្រាប់ឱ្យប្អូនៗផ្តោតការយកចិត្តទុកដាក់
- ចូរភ្ជាប់ផ្នែកនៃការផ្តោតការយកចិត្តទុកដាក់ទាំងនេះទៅនឹងបទពិសោធន៍ក្នុងជីវិតប្រចាំថ្ងៃរបស់ប្អូន ហើយធ្វើការឆ្លុះបញ្ចាំងទៅលើរបៀបនៃការប្រាស្រ័យទាក់ទងនីមួយៗទាំងរបស់ស្ត្រី និងបុរសក្នុងស្ថានភាពខុសៗគ្នា។ តើប្អូនកត់សម្គាល់ឃើញអ្វីខ្លះ?
- ចូរប្អូនបំពេញកូឡោនទី២ និងទី៣ដើម្បីបង្ហាញពីចម្លើយរបស់ប្អូនទៅតាមការកត់សម្គាល់នោះ

| ផ្នែកដែលត្រូវផ្តោតសម្រាប់ការសង្កេតមើល | ស្ត្រី | បុរស |
|---|---|---|
| ភាពខុសគ្នានៃការលើកដាក់សំឡេងក្នុងការប្រាស្រ័យទាក់ទងគ្នា | | |
| ភាពខុសគ្នាចំពោះភាសាកាយវិការ | | |
| ការសួរសំណួរ | | |
| ឥរិយាបថ | | |
| ជម្រើសប្រធានបទដែលចូលចិត្តលើកឡើងក្នុងពេលប្រាស្រ័យទាក់ទងគ្នា | | |

កិច្ចការផ្ទះ

# គន្លឹះនៃទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

## សន្លឹកកិច្ចការទាក់ទងនឹងចំណេះដឹងរបស់សិស្ស

សេចក្តីណែនាំ ៖

- ចូរអានគន្លឹះនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព

**ការណែនាំអំពីទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព**

1. ការប្រាស្រ័យទាក់ទងច្បាស់លាស់កើតឡើងនៅពេលអ្នកបញ្ជូនយល់ច្បាស់ពីសារដែលអ្នកទទួលចង់បាន។
2. មនុស្សប្រាស្រ័យទាក់ទងគ្នាទាំងតាមពាក្យសម្តី និងមិនមែនពាក្យសម្តី។
3. វាមានសារៈសំខាន់ណាស់ក្នុងការពិនិត្យមើលថា តើគេយល់ពីសាររបស់ប្អូនបានច្បាស់លាស់ដែរ ឬទេ ជាពិសេសនៅពេលដែលសារនោះទាក់ទងនឹងប្រធានបទដែលពិបាក ឬអារម្មណ៍។
4. នៅគ្រប់ស្ថានភាពទាំងអស់ បច្ចេកទេសមួយក្នុងចំណោមបច្ចេកទេសសំខាន់ៗបំផុតសម្រាប់ការប្រាស្រ័យទាក់ទងល្អគឺការស្តាប់ឱ្យបានច្បាស់ និងប្រកបដោយការគោរព។ ទោះជាយ៉ាងណាក៏ដោយ បទដ្ឋានវប្បធម៌មានឥទ្ធិពលលើអ្វីដែលជាប្រភេទនៃការប្រាស្រ័យទាក់ទងដែលគេចាត់ទុកថាសមស្រប។
5. ការស្តាប់ដោយយកចិត្តទុកដាក់ និងដោយមិនវិនិច្ឆ័យជាមុនអាចជួយពង្រឹងការប្រាស្រ័យទាក់ទង។ នៅពេលដែលប្អូនកំពុងស្តាប់ ចូរប្អូនអនុវត្តតាមចំណុចខាងក្រោម ៖
   - ព្យាយាមយល់ពីអ្នកដទៃ និងមនុស្សទូទៅផ្សេងទៀត។
   - និយាយពីចំណុចផ្សេងៗដើម្បីបញ្ជាក់ពីអ្វីដែលគេកំពុងនិយាយ ឧ. "ខ្ញុំអាចយល់ពីអារម្មណ៍របស់អ្នក" ឬ "ចំណុចល្អ" ឬ "ការមើលភ្នែក និង ប្រើក្រសែភ្នែក" ។ល។
   - បង្ហាញកាយវិការជាវិជ្ជមាន ដូចជា ញញឹម ងក់ក្បាល និងការសួរបញ្ជាក់។
6. អាកប្បកិរិយាជាក់លាក់ផ្សេងៗអាចពង្រឹងការប្រាស្រ័យជាពាក្យសម្តី។ អាកប្បកិរិយាដែលមានលក្ខណៈស្ថាបនាទូទៅរួមមាន ៖ ការទទួលស្គាល់ថាមនុស្សគ្រប់រូបមានសិទ្ធិបង្ហាញពីអារម្មណ៍ និងមតិរបស់ខ្លួនឱ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាននូវអ្វីដែលគេចង់បាន និងអ្វីដែលខ្លួនមិនចង់ ការជួយរកដំណោះស្រាយដែលអាចធ្វើទៅបានសម្រាប់បញ្ហាផ្សេងៗ។
7. ជៀសវាងការណែនាំ ការវិនិច្ឆ័យ ឬការគ្រប់គ្រង(ត្រួតត្រា)ខ្លាំងពេក។

# ឧបសគ្គក្នុងការនិយាយ

## យេនឌ័រ និងការប្រាស្រ័យទាក់ទង

**សេចក្តីណែនាំ ៖**

- ចូរមើលដ្យាក្រាមដែលបានផ្តល់ជូនខាងក្រោម។
- ចូរកំណត់ពីកិច្ចសន្ទនាដែលពិបាកមួយដែលប្អូនត្រូវធ្វើជាមួយមនុស្សម្នាក់ ឬមនុស្សមួយក្រុម
- ឃ្លានៅក្នុងប្រអប់នីមួយៗអាចជាឧបសគ្គដែលអាចកើតមានដែលបញ្ឈប់ប្អូនពីការសន្ទនានេះ។ ចូរផាត់ពណ៌លើប្រអប់ណាមួយដែលត្រូវជាមួយអ្នក។

ខ្ញុំខ្លាច

ខ្ញុំអាចធ្វើឱ្យពួកគាត់មិនសប្បាយចិត្ត

ស្តាប់ទៅ ខ្ញុំអាចខ្សោយ

គេអាចយល់ច្រឡំពីខ្ញុំ។

ខ្ញុំគ្មានជំនឿចិត្ត

ខ្ញុំមិនមានសេចក្តីក្លាហានគ្រប់គ្រាន់ក្នុងការនិយាយទេ។

មិនដែលមាននរណាស្តាប់ខ្ញុំផង ហេតុអ្វីខ្ញុំត្រូវនិយាយ។

ខ្ញុំមិនដឹងថាត្រូវចាប់ផ្តើមពីចំណុចណា។

ខ្ញុំមិនមានសេចក្តីក្លាហានគ្រប់គ្រាន់ក្នុងការនិយាយទេ។

ពួកគាត់អាចសើចចំអកខ្ញុំ។

ខ្ញុំអាចធ្វើឱ្យពួកគាត់បារម្ភ។

ពួកគាត់អាចខឹងខ្ញុំ។

នេះគឺជាខ្ញុំ!

គូររូបរបស់ប្អូននៅទីនេះ

ខ្ញុំប្រហែលជាមិនអាចរៀបរាប់ពីខ្លួនឯងឱ្យបានច្បាស់លាស់ទេ

ពួកគាត់ប្រហែលជាមិនស្តាប់អ្វីដែលខ្ញុំត្រូវនិយាយទេ។

អ្វីដែលខ្ញុំត្រូវនិយាយគឺមិនសំខាន់នោះទេ។

អ្វីដែលខ្ញុំត្រូវនិយាយមានភាពស្មុគស្មាញពេក។

ប្អូនបានកំណត់ឧបសគ្គដែលរារាំងប្អូនពីការប្រាស្រ័យទាក់ទងរួចហើយ។
ចូរគិតពីរបៀបដែលប្អូនអាចជម្នះលើឧបសគ្គទាំងនេះបាន។
តើអ្នកត្រូវធ្វើអ្វីខ្លះ?

……………………………………………………………………………………………………



……………………………………………………………………………………………………

# ជំពូកទី២ ៖ ទំនាក់ទំនងល្អ



**ទិដ្ឋភាពទូទៅ**

ក្នុងម៉ូឌុល១ ៖ «ខ្លួនឯង» សិស្សបានសិក្សាពីជំពូកមួយស្តីពីការយល់ដឹងពីទំនាក់ទំនង និង អារម្មណ៍។ ជំពូកទី២ ក្នុងម៉ូឌុល២ ៖ ទំនាក់ទំនងល្អ ផ្តោតសំខាន់លើការជួយសិស្សឱ្យ យល់ពីរបៀបដែលយេនឌ័រ និងអំណាចអាចមានផលជះលើទំនាក់ទំនងអន្តរបុគ្គល។

សិស្សនឹងសិក្សាពីរបៀបភ្ជាប់ ឬចូលរួមក្នុងទំនាក់ទំនងជាមួយអ្នកដទៃបានយ៉ាងល្អ ប្រសើរ និងដោយការគោរព។ សិស្សនឹងរៀនកំណត់ពីរបៀបដែលអំណាចមានឥទ្ធិពល លើទំនាក់ទំនងរបស់ពួកគេ ព្រមទាំងរបៀបយល់ដឹង និងចរចាពីចំណុចនោះ។

## ជំពូកទី២ ៖ លទ្ធផលសិក្សា

*ជំពូកនេះនឹងជួយសិស្សឱ្យ ៖*

| |
|---|
| 1. យល់ដឹងពីរបៀបដែលយេនឌ័រ និងអំណាចដើរតួនាទីជាផ្នែកមួយក្នុងទំនាក់ទំនងរបស់យើង។ |
| 2. យល់ដឹងពីអ្វីដែលធ្វើឱ្យទំនាក់ទំនងមួយមានភាពល្អប្រសើរ។ |

# គ្រោគឈរដើម្បីខ្លួនឯង

## តើនរណាជាអ្នកមានអំណាច?

សេចក្ដីណែនាំ

- ឆ្លុះបញ្ចាំងពីជីវិតរបស់ប្អូន។ ចូរគិតពីស្ថានភាពចំនួន៣ដែលប្អូនធ្លាប់ឆ្លងកាត់ចំពោះការមានអារម្មណ៍មួយថាគ្មានអំណាច ឬមិនត្រូវបានគេស្ដាប់ ឬត្រូវបានគេប្រាប់មិនឱ្យនិយាយ។ ចូរសរសេរស្ថានភាពទាំងនោះនៅក្រោមកូឡោនទី១ដែលមានចំណងជើងថា "ស្ថានភាព"
- ចូរបំពេញកូឡោនទី២ និង ៣ទាក់ទងនឹងស្ថានភាពនីមួយៗដែលប្អូនបានជួបប្រទះ
- គេផ្ដល់ឧទាហរណ៍មួយដើម្បីជួយប្អូនឱ្យយល់កាន់តែច្បាស់។

| តារាងទី១ ៖ តើកត្តាអ្វីដែលធ្វើឱ្យប្អូនមានអារម្មណ៍បែបនេះ? | | |
|---|---|---|
| ស្ថានភាព | តើនរណាខ្លះដែលពាក់ព័ន្ធ? | តើលទ្ធផលខុសពីអ្វីដែលខ្ញុំចង់បានយ៉ាងដូចម្ដេច? |
| ឧទាហរណ៍ ៖ គ្រូស្ដីបន្ទោសខុសចំពោះការឡូឡាក្នុងថ្នាក់។ | គ្រូ | គ្រូមិនគួរស្ដីបន្ទោសខ្ញុំមុនគេទេ ពីព្រោះមិនមែនជាកំហុសរបស់ខ្ញុំឡើយ។ |
| 1. | | |
| 2. | | |
| 3. | | |

សេចក្ដីណែនាំ ៖

- ប្រើប្រាស់ស្ថានភាពទាំង៣ដដែល។ ចូរគិតពីចំណុចដែលប្អូនអាចធ្វើផ្សេងពីនេះ? សរសេរចម្លើយរបស់ប្អូនក្នុងតារាងទី២។ គេផ្ដល់ឧទាហរណ៍មួយដើម្បីជួយប្អូនឱ្យយល់កាន់តែច្បាស់។

| តារាងទី២ ៖ តើកត្តាអ្វីដែលធ្វើឱ្យប្អូនមានអារម្មណ៍បែបនេះ? | | |
|---|---|---|
| **ស្ថានភាព** | **តើខ្ញុំក្រោកឈរដើម្បីខ្លួនឯងដោយរបៀបណា?** | **តើលទ្ធផលខុសពីអ្វីដែលខ្ញុំចង់បានយ៉ាងដូចម្ដេច?** |
| **ឧទាហរណ៍ ៖** គ្រូស្ដីបន្ទោសខុសចំពោះការឡូឡាក្នុងថ្នាក់។ | ខ្ញុំអាចស្ដាប់គាត់សិន ហើយបន្ទាប់មកចាំទៅរកគាត់ដើម្បីពន្យល់ពីសាច់រឿងរបស់ខ្ញុំនៅពេលក្រោយ។ | មិនគួរមានអារម្មណ៍មិនសប្បាយចិត្តទេ។ ត្រូវបកស្រាយគំនិតរបស់ខ្ញុំដោយភាពអត់ធ្មត់។ ស្ដាប់ ហើយបន្ទាប់មក លើកឡើង ឬបញ្ជាក់ពីគំនិតរបស់ខ្ញុំ។ |
| ១. | | |
| ២. | | |
| ៣. | | |

## ជំពូកទី៣ ៖ ការយល់ដឹងពីអំពើហិង្សា

**ទិដ្ឋភាពទូទៅ**

អង្គការសហប្រជាជាតិកំណត់និយមន័យនៃអំពើហិង្សាលើស្ត្រី (VAW) ថាជា "សកម្មភាពហិង្សាលើយេនឌ័រណាមួយដែលបណ្តាលឱ្យ ឬទំនងជាបណ្តាលឱ្យមានការឈឺចាប់ដល់រូបរាងកាយ ផ្លូវភេទ ឬស្មារតី ឬការធ្វើបាបស្ត្រី ដូចជាសកម្មភាពគំរាមកំហែង ការបង្ខិតបង្ខំ ការដកហូតសិទ្ធិសេរីភាពតាមទំនើងចិត្ត មិនថាកើតឡើងក្នុងជីវិតសាធារណៈ ឬឯកជនក្តី"។ (UN ឆ្នាំ1993) និយាយម្យ៉ាងទៀត ហិង្សាអាចមានន័យច្រើន។ វាអាចជាហិង្សាលើរូបរាងកាយ ផ្លូវចិត្ត ផ្លូវភេទ ឬសេដ្ឋកិច្ច។ អំពើហិង្សាកើតឡើងនៅពេលដែលមនុស្សម្នាក់ធ្វើឱ្យបុគ្គលម្នាក់ទៀតឈឺចាប់ កើតទុក្ខ ឬវេទនា។ VAW ត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិថាជាអំពើហិង្សាលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ស្ត្រី និងជាទម្រង់ច្បាស់លាស់មួយនៃការរើសអើងផ្អែកយេនឌ័រផងដែរ។ ការបែងចែកអំណាចមិនស្មើគ្នារវាងបុរស និងស្ត្រីបង្កើតបានជាប្រព័ន្ធបិតាធិបតេយ្យដែលសិទ្ធិរបស់ស្ត្រីត្រូវបានគាបសង្កត់ ហើយពួកគេក្លាយជាជនងាយរងគ្រោះចំពោះការកេងប្រវ័ញ្ច និងការរើសអើង។ ដោយសារតែវាបានចាក់ឫសគល់យ៉ាងជ្រៅក្នុងវិសមភាពយេនឌ័រ ប្រព័ន្ធនេះអនុញ្ញាតឱ្យបុរសគ្រប់គ្រងលើស្ត្រី។ ប្រព័ន្ធនេះបានបង្កើតឱកាសឱ្យមានការប្រព្រឹត្តអំពើហិង្សាលើស្ត្រី ទោះបីវាជាអំពើហិង្សាលើរូបរាងកាយ ផ្លូវចិត្ត ចិត្តសាស្ត្រ ឬសេដ្ឋកិច្ចក្តី។

ជារឿយៗ ស្ត្រីតែងតែប្រឈមមុខនឹងការជំទាស់ចំពោះសិទ្ធិរបស់ខ្លួនក្នុងការគ្រប់គ្រង កាន់កាប់ និងសិទ្ធិទទួលបានសិទ្ធិជាមូលដ្ឋានដូចជា ការអប់រំ ប្រព័ន្ធសុខាភិបាល ហិរញ្ញវត្ថុ។ល។

ជំពូកទី៣ ក្នុងម៉ូឌុលទី២ នេះជួយក្មេងស្រីឱ្យយល់ដឹងច្បាស់លាស់ពីអំពើហិង្សា និងទម្រង់ខុសៗគ្នារបស់វា កំណត់ពីអំពើហិង្សានៅជុំវិញខ្លួនរបស់គេ និងធ្វើឱ្យពួកគេមើលឃើញពីការផ្លាស់ប្តូរដែលអាចធ្វើទៅបាននៅក្នុងរចនាសម្ព័ន្ធជាមូលដ្ឋានរបស់សង្គមបច្ចុប្បន្ន។

**ជំពូកទី៣ ៖ លទ្ធផលសិក្សា**

*ជំពូកនេះនឹងជួយសិស្សឱ្យ ៖*

| |
|---|
| ១. មានលទ្ធភាពកំណត់ពីសកម្មភាពខុសៗគ្នានៃអំពើហិង្សានៅជុំវិញខ្លួន និងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ |
| ២.មានការយល់ដឹងមួយពីទម្រង់ខុសគ្នានៃអំពើហិង្សា និងកត្តាទូទៅ។ |
| ៣.មានលទ្ធភាពមើលឃើញពីការផ្លាស់ប្តូរដែលអាចធ្វើទៅបាននៅក្នុងរចនាសម្ព័ន្ធជាមូលដ្ឋានរបស់សង្គមបច្ចុប្បន្ន។ |

# ជំនឿ និងការពិត

### តើវាពិតដែរឬទេ?

**សេចក្តីណែនាំ៖**

- ចូរអានប្រយោគនីមួយៗនៅក្នុងកូឡោនទី១។
- គូសសញ្ញាធីក(✓) ក្នុងកូឡោន "មែន" "មិនមែន" ឬ"មិនដឹង" ដោយប្រៀបធៀបនឹងប្រយោគនីមួយៗដើម្បីឆ្លុះបញ្ចាំងពីចម្លើយរបស់ប្អូន។
- សរសេរមូលហេតុផ្សេងៗសម្រាប់ការជ្រើសរើសចម្លើយរបស់ប្អូនក្នុងកូឡោនទី៣ដោយប្រៀបធៀបនឹងប្រយោគនីមួយៗ។

| ប្រយោគ | ចម្លើយរបស់ខ្ញុំ | | | មូលហេតុរបស់ខ្ញុំ |
|---|---|---|---|---|
| | មែន | មិនមែន | មិនដឹង | |
| 1. អំពើហិង្សាគឺជារឿងឯកជន និងមិនគួរយកមកពិភាក្សាជាមួយអ្នកដទៃក្រៅពីគ្រួសារឡើយ។ | | | | ១. |
| 2. ស្ត្រីមិនពូកែខាងគណិតវិទ្យាទេ ដូច្នេះពួកគេមិនគួរសម្រេចចិត្តលើបញ្ហាហិរញ្ញវត្ថុក្នុងគ្រួសារឡើយ។ | | | | ២. |
| 3. បុរសស្ថិតក្នុងក្រុម ឬវណ្ណៈ និងកម្រិតអប់រំជាក់លាក់ងាយនឹងប្រព្រឹត្តអំពើហិង្សា។ | | | | ៣. |
| 4. ប្រសិនបើស្ត្រីទទួលទានគ្រឿងស្រវឹង និងជក់បារីពួកគេកំពុងធ្វើឱ្យមានការកេងចំណេញ និងការបៀតបៀនផ្លូវភេទ។ | | | | ៤. |
| 5. អំពើហិង្សាលើស្ត្រីគឺជារឿងដែលកម្រកើតមានណាស់ ហើយពុំមាននរណាម្នាក់ដែលខ្ញុំស្គាល់ទទួលរងផលប៉ះពាល់ពីអំពើហិង្សាទេ។ | | | | ៥. |
| 6. ស្ត្រីគឺជាសត្រូវដ៏អាក្រក់បំផុតរបស់ស្ត្រី(គ្នាឯង)។ | | | | ៦. |
| 7. អំពើហិង្សាលើស្ត្រីនៅក្នុងគ្រួសារមិនមានផលប៉ះពាល់ដល់កូនទេ។ | | | | ៧. |
| 8. តាមធម្មតា ស្ត្រីមានភាពទន់ខ្សោយបើប្រៀបធៀបនឹងបុរស។ | | | | ៨. |

កិច្ចការផ្ទះ

# គំនិតរបស់ខ្ញុំ

## ការផ្លាស់ប្តូរដែលយើងចង់ឃើញ

សេចក្តីណែនាំ ៖

- ការរើសអើងផ្អែកយេនឌ័រគឺជាបញ្ហាសកល។
- ឆ្លុះបញ្ចាំងពីសង្គមដែលប្អូនរស់នៅក្នុងបរិបទនេះ ហើយបំពេញចម្លើយរបស់ប្អូនទៅតាមនោះ។

គំនិតរបស់ខ្ញុំ ...

តើត្រូវផ្លាស់ប្តូរអ្វីមួយនៅក្នុងរចនាសម្ព័ន្ធសង្គមដែលមានស្រាប់ដែលគ្រប់គ្រងលើស្ត្រី និង បុរស និងទម្រង់នៃអាកប្បកិរិយារបស់ពួកគេមែនដែរ ឬទេ?

ការឆ្លុះបញ្ចាំងរបស់ខ្ញុំ ...

តើការផ្លាស់ប្តូរនេះអាចធ្វើទៅបានដែរ ឬទេ? ប្រសិនបើអាច តើត្រូវផ្លាស់ប្តូរអ្វីខ្លះ? ប្រសិនបើ មិនអាច តើហេតុអ្វី? តើមានការប្រឈមមុខអ្វីខ្លះ?

ទំនួលខុសត្រូវរបស់ខ្ញុំ ...

តើនរណាជាអ្នកទទួលខុសត្រូវ? តើប្អូនអាចរួមចំណែកដល់ដំណើរការនៃការផ្លាស់ប្តូរនេះ ដោយរបៀបណា? ចូរសរសេរផែនការសកម្មភាពរបស់ប្អូន ....

# ឧបសម្ព័ន្ធទី២

## ទម្រង់វាយតម្លៃសិស្ស

ពិន្ទុសរុប
........../២៥

# កម្រងសំណួរការធ្វើតេស្តចំណេះដឹងសិស្ស
# សម្រាប់ក្មេងស្រី ពេញវ័យ (ម៉ូឌុល ២)

វិទ្យាល័យ/អនុវិទ្យាល័យ..............................ខេត្ត/ក្រុង.....................ស្រុក/ខណ្ឌ....................ឃុំ/សង្កាត់..................
ឈ្មោះគ្រូបង្រៀន...............................ភេទ.............ឈ្មោះសិស្ស...............................ភេទ...........ថ្នាក់ទី....................
កាលបរិច្ឆេទការធ្វើតេស្ត: ថ្ងៃទី................ខែ.........................ឆ្នាំ...............................

| **ខ្លឹមសារ** | **ពិពណ៌នាសកម្មភាព** | **ឥស្សុតាខ ផ្សេងៗ** |
|---|---|---|
| **ម៉ូឌុល២**: *ស្វ័យប្រសិទ្ធភាព* | | |
| ជំពូកទី១៖ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព | | |
| ១.១. ការប្រាស្រ័យទាក់ទង ដោយពាក្យសម្តី លទ្ធផល ☐ | ☐ក. ជាការប្រាស្រ័យទាក់ទងដោយប្រើពាក្យនិយាយ ភាសា និង ការបញ្ចេញសម្លេង និង ឥរិយាបថ ឬកាយវិការដែលតម្រូវឱ្យអ្នក ស្តាប់យល់ពីអ្វីដែលកំពុងនិយាយ។ | |
| | ☐ខ. ជាការផ្លាស់ប្តូរការគិត គំនិត ឬអារម្មណ៍ទៅវិញទៅមក។ | |
| | ☐គ. ជាវិធីដែលមនុស្សផ្តល់ និងទទួលព័ត៌មានពីគ្នាទៅវិញទៅមក នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ | |
| | ☐ឃ. ជាជំនាញមួយដែលមនុស្សម្នាក់ៗត្រូវតែមាន។ | |
| | ☐ង. មិនដឹង។ | |
| ១.២. ការប្រាស្រ័យទាក់ទង មិនមែនពាក្យសម្តី លទ្ធផល ☐ | ☐ក. ជាការបញ្ចេញអារម្មណ៍របស់មនុស្សក្នុងការបង្ហាញដល់ នរណាម្នាក់ដោយប្រើកាយវិការ។ | |
| | ☐ខ. ជាសកម្មភាពមួយដែលរួមបញ្ចូលនូវលទ្ធភាពជាច្រើនហួសពី ការបញ្ចូលគ្នានៃពាក្យ រួមនិងឥរិយាបថ ការបញ្ចេញទឹកមុខ សកម្មភាព សម្លេង ការបន្លំ ចលនារាងកាយ កាយវិការ និង សកម្មភាពជាច្រើនទៀត។ | |
| | ☐គ. ជាការទំនាក់ទំនងដោយប្រើកាយវិការជំនួសពាក្យសម្តី។ | |
| | ☐ឃ. ជាការទាក់ទងតាមរយៈការផ្ញើសំបុត្រ។ | |
| | ☐ង. មិនដឹង។ | |

| | | |
|---|---|---|
| ១.៣. យេនឌ័រ គឺជា ? | ☐ក. លទ្ធភាពដែលអាចធ្វើអ្វីមួយបានរបស់ក្មេងប្រុស និងក្មេងស្រី លើការសម្រេចចិត្ត។ | |
| លទ្ធផល | ☐ខ. ទំនួលខុសត្រូវ តួនាទី និងការងារដែលត្រូវធ្វើជាមួយគ្នារវាង ភេទប្រុស និងភេទស្រី។ | |
| ☐ | ☐គ. សិទ្ធនិងអំណាចឫឯកពាជ្យភាពរបស់ភេទទាំងពីរ ។ | |
| | ☐ឃ. ការរំពឹងទុកដែលផ្អែកលើការអនុវត្តតាមបែបសង្គមវប្បធម៌ ដែលអាចមានភាពមិនស្មើគ្នា និងអយុត្តិធម៌។<br>☐ង. មិនដឹង។ | |
| ជំពូកទី២៖ ទំនាក់ទំនងល្អ | | |
| ២.១. តាមគំនិតរបស់អ្នក រវាងបុរស និងស្ត្រី អ្នកណាមានអំណាចជាង? | ☐ក. បុរសមានអំណាចជាងស្ត្រី។ | |
| | ☐ខ. បុរសនិងស្ត្រីមានអំណាចស្មើគ្នាលើភារកិច្ចមួយចំនួនប៉ុណ្ណោះ។ | |
| លទ្ធផល | ☐គ. បុរស និងស្ត្រីមានអំណាចស្មើគ្នាលើគ្រប់ការងារទាំងអស់។ | |
| ☐ | ☐ឃ. ស្ត្រីមានអំណាចជាងបុរស។ | |
| | ☐ង. មិនដឹង។ | |
| ជំពូកទី៣៖ ការយល់ដឹងអំពីអំពើហិង្សា | | |
| ៣.១. អំពើហិង្សាគឺជា? | ☐ក. សកម្មភាពមួយដែលបង្ករបួសស្នាមលើរាងកាយ ផ្លូវភេទ និងផ្លូវចិត្ត។ | |
| លទ្ធផល | ☐ខ. ការវាយតប់គ្នា។ | |
| ☐ | ☐គ. ការឈ្លោះប្រកែកគ្នា។ | |
| | ☐ឃ. ការស្តីបន្ទោសគ្នា។ | |
| | ☐ង. មិនដឹង។ | |